FO/III

លេខយោង/ឈ្មោះ/ទីកន្លែង ២១១៤ ទំនាក់ទំនងរវាងសាធារណរដ្ឋសង្គមនិយមវៀតណាម - សាធារណរដ្ឋប្រជាមានិតកម្ពុជា - ZR 1470/81

ចំណងជើង:

ពី: ឆ្នាំ ១៩៧៧ រហូតដល់: [មិនច្បាស់] ឆ្នាំ ១៩៧៩ ឯកសារ: __________ ចងក្រងក្នុង: __________

## ក្រសួងការបរទេស

## GDR [សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់]

L [មិនច្បាស់]-21-L-78

27/L 78 G 5475

27/L189 នាយកដ្ឋានចុងបូព៌ា

ZK 1470/81 ទំនាក់ទំនងរវាងវៀតណាម និងកម្ពុជា

រួមបញ្ចូល: - ព័ត៌មានទាក់ទងនឹងបញ្ហាព្រំដែន

- សំណុំរឿងស្តីពីការវិវត្តន៍នៃទំនាក់ទំនងទ្វេរភាគី

ខែ មករា-ធ្នូ ឆ្នាំ ១៩៧៩

ឆ្នាំ ១៩៧៧ -១៩៧៩

000225

លេខលំដាប់ 42 427 ELN លេខ. 155 81 692 **robotron** ជំនួយអង្គភាព

1/4

<u>ប្រភព</u>:

បណ្ណសារនយោបាយរបស់ក្រសួងការបរទេស

ទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់

Original DE: 00537030-00537080

Note: This Khmer translation is based on the English version which was translated from the original German text.

ស្ថានទូត GDR (សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់) ប្រចាំនៅ DPRK (សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ)។

ទីក្រុងព្យុងយ៉ាង ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៧៧

[ត្រា:]

ចុងបូព៌ា

ថ្ងៃទី ១៦ ខែ កញ្ញា [មិនច្បាស់]

[មិនច្បាស់] លេខ VD366

[មិនច្បាស់] លេខ ______

[ត្រា:] ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៧៨

[ហត្ថលេខា]

| ឯកសារសម្ងាត់ | | | | |
|---|---|---|---|---|
| ផ្នែកភស្តុតាង | លេខលំដាប់ | ឆ្នាំ | ចំនួនច្បាប់ឯកសារ | ចំនួនទំព័រ |
| BO [ស្ថានទូត] | 58 | 77 | 3 | 3 |

## អនុស្សារណៈ

ស្ដីពីកិច្ចពិភាក្សាជាមួយឯកអគ្គរដ្ឋទូតនៃ SRV (សាធារណរដ្ឋសង្គមនិយមវៀតណាម) ប្រចាំសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ សមមិត្ត Le Trung Nam កាលពីថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ១៩៧៧ នៅស្ថានទូតសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់។

---

[ហត្ថលេខា]

កិច្ចពិភាក្សានេះត្រូវបានធ្វើឡើង ដោយយោងទៅតាមសំណើរបស់ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាម និងធ្វើឡើងជាភាសាបារាំង ហើយសមមិត្ត U.Steinhofer បានធ្វើជាអ្នកបកប្រែ។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

សមមិត្ត Le Trung Nam បានរាយការណ៍ពីទំនាក់ទំនងរវាង SRV និងប្រទេសកម្ពុជា។ ទំនាក់ទំនងទាំងនេះកំពុងមានភាពតានតឹងកាន់តែខ្លាំងឡើងដោយសារតែភាពទុំជោរនៃជម្លោះព្រំដែនរវាងប្រទេសទាំងពីរ។ SRV កំពុងជំរុញឲ្យមានកិច្ចព្រមព្រៀងព្រំដែនជាមួយប្រទេសកម្ពុជាតាំងពីខែ ឧសភា ឆ្នាំ ១៩៧៥ បន្ទាប់ពីកិច្ចចរចាដោយជោគជ័យរវាង SRV និងប្រទេសឡាវ។ យ៉ាងនេះក្តី កិច្ចខិតខំប្រឹងប្រែងទាំងនេះមិនទាន់ហុចផលជាផ្លែផ្កាអ្វីឡើយ។

កន្លងមក SRV បានប្រឈមនឹងបញ្ហាលំបាកស្រដៀងគ្នានេះជាមួយ PRC [សាធារណរដ្ឋប្រជាមានិតចិន] ដែលធ្លាប់មានជម្លោះប្រដាប់អាវុធផងដែរ។ ជាលើកដំបូង PRC បានប្រកាសនៅឆ្នាំនេះថា ប្រទេសចិនបានត្រៀមខ្លួនជាស្រេចដើម្បីរៀបចំកិច្ចចរចា “ថ្នាក់កណ្តាល” ជាមួយ SRV ដើម្បីឈានទៅរកកិច្ចព្រមព្រៀងព្រំដែនរួមរវាងប្រទេសទាំងពីរនៅកម្រិតខ្ពស់។

សមមិត្ត Le Trung Nam បានគូសបញ្ជាក់ជាថ្មីម្តងទៀតថា SRV ចាប់អារម្មណ៍លើដំណោះស្រាយដោយសន្តិវិធីសម្រាប់ជម្លោះព្រំដែនជាមួយប្រទេសកម្ពុជា។ យ៉ាងណាក៏ដោយ គេឃើញមានការបង្កហេតុកាន់តែញឹកញាប់ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ថ្មីៗនេះ តាមរយៈការវាយលុកដោយកងទ័ពក្នុងទ្រង់ទ្រាយធំពីភាគីកម្ពុជា ដែលប្រមូលផ្តុំកងវរសេនាធំដ៏ខ្លាំងក្លាមួយដើម្បីប្រតិបត្តិការចូលជ្រៅទៅក្នុងទឹកដីវៀតណាម។

Original DE: 00537030-00537080

Note: This Khmer translation is based on the English version which was translated from the original German text.

ដើម្បីទប់ស្កាត់ការរីករាលដាលនៃជម្លោះនេះ សមមិត្តវៀតណាមបានដកកងទ័ពរបស់ខ្លួនជាច្រើនគីឡូម៉ែត្រចេញពីព្រំដែនជាប់នឹងកម្ពុជា ដើម្បីបើកច្រកឲ្យមានកិច្ចចរចានេះ។

យ៉ាងនេះក្ដី សមមិត្ត Le Trung Nam សង្ស័យថា ចិន "បានលូកដៃក្នុងព្រឹត្តិការណ៍នេះ"។ ច្បាស់ណាស់ថា ចិនភ័យខ្លាចចំពោះចំណងទាក់ទងរវាងប្រទេសវៀតណាម ឡាវ និងកម្ពុជា និងព្យាយាមបង្កភាពប្រទាញប្រទង់គ្នាក្នុងចំណោមប្រជាជាតិទាំងបីនេះ។

សមមិត្ត Le Trung Nam បានបង្ហាញការយល់ឃើញរបស់ខ្លួនស្ដីពីស្ថានភាពក្នុងប្រទេសកម្ពុជាដូចខាងក្រោម ៖

រយៈពេលពីរឆ្នាំមកហើយដែលគេមិនឃើញមានសមាជបក្ស ឬកិច្ចប្រជុំរបស់គណៈកម្មាធិការមជ្ឈិមក្នុងប្រទេសកម្ពុជា ហើយរដ្ឋាភិបាលពេញលេញមួយក៏មិនទាន់ត្រូវបានបង្កើតឡើងដែរ។ មិនមានគោលនយោបាយក្នុងប្រទេស ឬគោលនយោបាយការបរទេសឡើយ។ ច្បាស់ណាស់ថា បក្សនេះកំពុងក្ដោបក្ដាប់ស្ថានការណ៍ក្នុងប្រទេស ប៉ុន្តែមធ្យោបាយដែលបក្សប្រើប្រាស់ដើម្បីបញ្ចូលមនោគមនយោបាយ និងសេដ្ឋកិច្ចរបស់ខ្លួននឹងបង្កើនភាពតានតឹងរវាងបក្សនេះ និងប្រជាជន។

ការបង្កបង្កើនផលកសិកម្មថ្មីៗនេះក្នុងប្រទេសកម្ពុជាបានផ្ដល់ផលគាប់ប្រសើរ។ ការអភិវឌ្ឍនៃវិស័យកម្មន្តសាលធុនស្រាលបានដើរថយក្រោយ។ មិនទាន់មានពាណិជ្ជកម្មលក់រាយ និងគ្មានការផ្ដល់ប្រាក់បៀវត្សរ៍ដល់កម្មករនិយោជិតឡើយ។ អ្វីៗគ្រប់យ៉ាងត្រូវបានផ្ដល់ឲ្យតាមរបប។ ប្រជាជនកម្ពុជាកំពុងរស់នៅដោយភាពខ្វះខាត។

នៅឆ្នាំនេះ កម្ពុជាបានលក់ស្រូវរបស់ខ្លួនជាលើកដំបូងឲ្យប្រទេសឡាវ និងជប៉ុនដើម្បីទិញគ្រឿងម៉ាស៊ីនសំខាន់ៗ ទោះបីជាមិនសូវមានព័ត៌មានស្ដីពីប្រធានបទនេះក៏ដោយ។

ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំទីក្រុងភ្នំពេញ នៅមិនទាន់បានដឹងពីអាសនៈរបស់រដ្ឋាភិបាលកម្ពុជានៅឡើយទេ។ ស្ថានទូតនីមួយៗសុទ្ធតែមានលេខាកម្ពុជាមួយរូបសម្រាប់រៀបចំកិច្ចពិភាក្សាដែលធ្វើឡើងក្នុងអគារខុសៗគ្នា។ សូម្បីតែការិយាល័យកុងស៊ុលបរទេស ក៏ទទួលបានរបបអាហារប្រចាំថ្ងៃដែរ។

មន្ត្រីស្ថានទូតបរទេសនៅតែមិនត្រូវបានអនុញ្ញាតឲ្យដើរហើរដោយសេរីក្នុងទីក្រុងភ្នំពេញ។

សមមិត្ត Le Trung Nam បានប្រាប់ខ្ញុំថា ខ្ញុំគឺជាឯកអគ្គរដ្ឋទូតតែម្នាក់គត់ ដែលគាត់បានចែករំលែកព័ត៌មាននេះ ប៉ុន្តែគាត់មិនបានជំទាស់មិនឲ្យខ្ញុំចែករំលែកព័ត៌មាននេះជាមួយឯកអគ្គរដ្ឋទូតផ្សេងទៀតដែលជិតស្និទ្ធនឹងខ្ញុំឡើយ។

បន្ទាប់ពីបានអរគុណគាត់សម្រាប់ព័ត៌មាននេះ ខ្ញុំបានបង្ហាញចំណាប់អារម្មណ៍ក្នុងការទទួលបានព័ត៌មានបន្ថែមស្តីពីស្ថានភាពស្រដៀងគ្នានេះពីឯកអគ្គរដ្ឋទូតវៀតណាមនៅថ្ងៃអនាគត។

សមមិត្តវៀតណាម និងសមមិត្តនៃស្ថានទូតរបស់យើងមានចំណងទាក់ទង និងមិត្តភាពយ៉ាងជិតស្និទ្ធបំផុត។

[ហត្ថលេខា]

Everhartz

ឯកអគ្គរដ្ឋទូត

<u>ចម្លងជូន</u>:

1x សមមិត្ត Markowski

1x សមមិត្ត Moldt

<u>1x ក្រសួងការបរទេស - FO</u> [ចុងបូព៌ា]

1x ក្រសួងការបរទេស - HAID [មិនស្គាល់អក្សរកាត់]

1x ឯកអគ្គរដ្ឋទូត

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

ស្ថានទូត GDR ប្រចាំ SRV

ទីក្រុងហាណូយ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៧៧
Bellm./Schn.

[ត្រា:] ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៧៨ [ត្រា:]

[ចំណារ] ចុងបូញ៉ា

ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៧៧

[មិនច្បាស់]: VD 381

[មិនច្បាស់]

| ឯកសារសម្ងាត់ | | | | |
|---|---|---|---|---|
| ផ្នែកភស្តុតាង | លេខលំដាប់ | ឆ្នាំ | ចំនួនច្បាប់ឯកសារ | ចំនួនទំព័រ |
| BO [ស្ថានទូត] ទីក្រុងហាណូយ | 163 | 77 | 2 | 11 |

[ហត្ថលេខា]

## កំណត់សម្គាល់

ស្តីពីកិច្ចពិភាក្សាជាមួយអនុប្រធាននាយកដ្ឋាន Europa I របស់ក្រសួងការបរទេស SRV លោក Dinh Thi Ngoc Tao កាលពីថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ១៩៧៧។

---

កិច្ចពិភាក្សានេះត្រូវបានធ្វើឡើង ដោយយោងតាមសំណើរបស់ស្ថានទូតសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់។

១. របាយការណ៍របស់សមមិត្ត Kuhrig VD 338 មានសំណើអនុម័តជំនួបរបស់បណ្ឌិត Nguyen Vihn Hoa ចំពោះគោលជំហររបស់សមាជិកបណ្ឌិតសភាកសិកម្មនៃ GDR ។

សមមិត្ត Tao បានសន្យាផ្តល់ការឆ្លើយតបឆាប់ៗនេះ។ បន្ទាប់មក គាត់បានសាកសួរថាតើជំនួបនេះផ្សារភ្ជាប់នឹងការអញ្ជើញ និងសិទ្ធិ ព្រមទាំងការទទួលខុសត្រូវដែរឬទេ។

<u>សម្គាល់ ៖</u>

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

យើងសូមស្នើឡើងថា ព័ត៌មានដែលស្នើឡើងទាំងនេះគួរត្រូវបានផ្សព្វផ្សាយដល់ភាគីវៀតណាម។

២. ក្រោយមក សមមិត្ត Tao បានពន្យល់ថា ភាគីវៀតណាមកំពុងត្រៀមខ្លួនយ៉ាងសកម្មសម្រាប់ដំណើរទស្សនកិច្ចរបស់បក្ស និងគណៈប្រតិភូរដ្ឋនៃ GDR។ កម្មវិធីនេះដែលជាមូលដ្ឋានសម្រាប់ការពន្លឿនកិច្ចចរចា និងសំណើសុំកិច្ចព្រមព្រៀងដោយមានខសន្យាដើម្បីធានាភាពជោគជ័យនៃដំណើរទស្សនកិច្ចនេះ។ <u>គេបានផ្តោតកិច្ចខិតខំប្រឹងប្រែងលើការចុះហត្ថលេខាឯកសារនយោបាយ និងសេដ្ឋកិច្ច។</u> សមមិត្ត Tao បានសាកសួរថាតើយើងអាចបញ្ជាក់ព័ត៌មានស្តីពីគោលបំណងនៃការបញ្ជូនរដ្ឋមន្ត្រីការបរទេសនៃ GDR និងក្រុមអ្នកជំនាញដើម្បីរៀបចំដំណើរទស្សនកិច្ចនេះឬទេ។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

ជាការឆ្លើយតប មានការបញ្ជាក់ថា គ្មានការផ្តល់ព័ត៌មានទាំងនេះឡើយ។ សមមិត្ត Tao បានស្នើសុំការផ្តល់ព័ត៌មាននេះឱ្យបានទាន់ពេលវេលា ប្រសិនបើមានគោលបំណងនេះ។

៣. ជាការឆ្លើយតបទៅនឹងសំណើពីខាងដើម និងលម្អិតមួយ សមមិត្ត Tao បានផ្តល់ការពន្យល់ស្តីពី
[មិនច្បាស់] 4.10 ទំនាក់ទំនងរវាង SRV និងប្រទេសកម្ពុជា ព្រមទាំងស្ថានភាពក្នុងប្រទេសកម្ពុជាដូចខាងក្រោម ៖

មានបញ្ហាជម្លោះព្រំដែន ដែលមិនទាន់បានដោះស្រាយរវាង SRV និងប្រទេសកម្ពុជា ដែលបណ្តាលមកពីបុព្វហេតុប្រវត្តិសាស្ត្រ។ នោះគឺប្រវត្តិសាស្ត្រសម័យសក្តិភូមិតាំងពី ២០០ ឆ្នាំមុន និងក្នុងសម័យនឹមអាណានិគមបារាំង។ វាគឺជាបញ្ហារវាងបងប្អូនរួមអារុធ។ "យើងជាពួកកុម្មុយនីស្ត និងព្យាយាមដោះស្រាយបញ្ហាទាំងនេះដោយឈរលើស្មារតីនោះ យោងតាមភាពជាបងប្អូន និងការគោរពអធិបតេយ្យភាព"។ ភាគីវៀតណាមចង់ដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសកម្ពុជាតាមរយៈកិច្ចចរចា ដូចដែលធ្លាប់ធ្វើកន្លងមកជាមួយប្រទេសឡាវ ប៉ុន្តែកម្ពុជាបានបដិសេធសំណើនេះ។ ក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ គេឃើញមានការបំពានបន្ទាត់ព្រំដែនដោយភាគីកម្ពុជាដែលធ្វើឱ្យមានអ្នករងរបួស និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិខាងភាគីវៀតណាម។

SRV បានការពារអធិបតេយ្យភាពរបស់ខ្លួនយ៉ាងខ្លាំងក្លា ទន្ទឹមនឹងការដាក់សំណើសុំឱ្យមានកិច្ចចរចាដោយសន្តិវិធីដោយផ្អែកលើស្មារតីសាមគ្គីភាព និងការគោរពឯករាជ្យភាពទៅវិញទៅមក។ SRV បានចាត់ទុកកម្ពុជាជាប្រទេសជិតខាង ដែលប្រកៀកស្មាគ្នាប្រយុទ្ធប្រឆាំងនឹងសត្រូវតែមួយ។

ស្ថានទូតរបស់ប្រទេសជាបងប្អូនមួយចំនួន បានស្នើសុំព័ត៌មានពីក្រសួងការបរទេសនៃ SRV ពាក់ព័ន្ធនឹងរបាយការណ៍ក្នុង x) ប្រព័ន្ធផ្សព្វផ្សាយបស្ចិមប្រទេសដែលបញ្ជាក់ថា ប្រទេសកម្ពុជាកំពុងប្រមូលផ្តុំកងទ័ពប្រឆាំងនឹង SRV។ មានការឆ្លើយតបទៅនឹងសំណើទាំងនេះ ប៉ុន្តែ SRV នឹងមិនផ្តល់ព័ត៌មានដល់បស្ចិមប្រទេសឡើយ។

\- - -

x) ក្នុង...

ចក្រពត្តិនិយមមិនត្រូវមានលេសណាមួយដើម្បីព្យាយាមលូកដៃក្នុងបញ្ហារវាង SRV និងកម្ពុជាឡើយ។ ពិតជាមាន "ការប្រមូលផ្តុំកងទ័ព" ក្នុងប្រទេសកម្ពុជា ប៉ុន្តែវាពាក់ព័ន្ធចម្បងនឹង "ការប្រមូលកងទ័ពសម្រាប់ផលិតកម្មប៉ុណ្ណោះ"។ យុវជនត្រូវបានបំបែកចេញពីគ្រួសារ និងដាក់បញ្ចូលទៅក្នុងកងការងារ ចំណែកកុមារត្រូវបានបំបែកចេញពីឪពុកម្តាយដើម្បីទទួលបានការអប់រំក្នុងសាលាមត្តេយ្យ។

គេមិនដឹងច្បាស់ពីគោលដៅពិតប្រាកដរបស់ប្រទេសកម្ពុជាឡើយ។ សមត្ថភាពរបស់ស្ថានទូត SRV ក្នុងការប្រមូលព័ត៌មាននៅមានកម្រិតទាប (សេរីភាពដើរហើរក្រៅស្ថានទូតស្ថិតក្នុងរង្វង់ ១០០ ម៉ែត្រ)។

?

មានតែមន្ត្រី និងសមាជិកកងកម្លាំងប្រដាប់អាវុធប៉ុណ្ណោះដែលរស់នៅក្នុងទីក្រុងភ្នំពេញ។ មិនមានទីផ្សារ ឬហាងបើកដំណើរការក្នុងប្រទេសឡើយ ហើយក៏គ្មានរូបិយវត្ថុដែរ។ ប្រជាជនត្រូវបានប្រមូលផ្តុំឱ្យទៅបង្កបង្កើនផល។ មានកិច្ចខិតខំប្រឹងប្រែងជាច្រើនក្នុងការបង្កបង្កើនផលកសិកម្មលើផ្ទៃដីដ៏ធំធេង ប៉ុន្តែមិនមានការស្តារប្រព័ន្ធធារាសាស្ត្រគួរឱ្យកត់សម្គាល់នោះទេ។ ប្រជាជនធ្វើការជាសហករណ៍ ប៉ុន្តែមិនចំជាសហករណ៍
[មិនច្បាស់] នោះទេ។ សហករណ៍ទាំងនេះគ្រប់គ្រងដោយមន្ត្រី។ របបអាហារត្រូវបានផ្តល់ឱ្យយ៉ាងតឹងរ៉ឹង និងមិនផ្អែកតាមប្រសិទ្ធភាពការងារនោះទេ។ ស្បៀងអាហារដែលផលិតបាន មិនមែនជាកម្មសិទ្ធិរបស់សហករណ៍ទេ ប៉ុន្តែត្រូវដាក់បញ្ចូលជារបស់រដ្ឋ។ មានការរាយការណ៍ថា ស្ថានភាពនៃការផ្គត់ផ្គង់មានលក្ខណៈស្មុគស្មាញបំផុត។ ច្បាស់ណាស់ថា ស្រូវអង្ករត្រូវបាននាំចេញ ប៉ុន្តែអ្វីៗគ្រប់យ៉ាងស្ថិតក្រោមការផ្គត់ផ្គង់យ៉ាងត្បិតត្បៀត សូម្បីតែឱសថ។ កម្ពុជាទទួលយកតែសំណើផ្តល់ជំនួយមួយចំនួនប៉ុណ្ណោះពី SRV ។ មកទល់បច្ចុប្បន្ននេះ មិនមានទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសទាំងពីរឡើយ។

គេមិនទាន់កំណត់បានផលវិបាកអវិជ្ជមានសម្រាប់ស្ថានភាពផ្ទៃក្នុងនៅ SRV ឡើយ។ ជនជាតិខ្មែរភាគតិចដែលរស់នៅភាគខាងត្បូង ស្មោះត្រង់នឹង SRV ។

[ហត្ថលេខា]

Bellmann

I. លេខា

ចម្លងជូន ៖

1. ZK (គណៈកម្មាធិការមជ្ឈិម) នៃ SED [បក្សសម្ព័ន្ធសង្គមនិយមអាល្លឺម៉ង់] នាយកដ្ឋានទី ៤

2. ក្រសួងការបរទេស នាយកដ្ឋានចុងបូព៌ា

3. ស្ថានទូតប្រចាំទីក្រុងហាណូយ

នាយកដ្ឋានចុងបូព៌ា

ទីក្រុងប៊ែរឡាំង ថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៧៨

[កាលបរិច្ឆេទត្រា មិនច្បាស់]

[ចំណារ]

| ឯកសារសម្ងាត់ | | | | |
|---|---|---|---|---|
| ផ្នែកភស្តុតាង | លេខលំដាប់ | ឆ្នាំ | ចំនួនច្បាប់ឯកសារ | ចំនួនទំព័រ |
| ក្រសួងការបរទេសចុងបូព៌ា | ✓ 4 | 78 | 5 | 3 |

+5, [មិនច្បាស់]

កំណត់សម្គាល់ស្ដីពីកិច្ចពិភាក្សារវាងអនុរដ្ឋមន្ត្រី សមមិត្ត Moldt និងភារធារីបណ្ដោះអាសន្ននៃ SRV ប្រចាំ GDR សមមិត្ត Le Trung Nghia កាលពីថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៧៨។

---

សមមិត្ត Nghia បានបង្ហាញដល់សមមិត្ត Moldt ពីសេចក្ដីប្រកាសរបស់ SRV កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ពាក់ព័ន្ធនឹងបញ្ហាព្រំដែនរវាងប្រទេសវៀតណាម និងកម្ពុជា ព្រមទាំងបានផ្ដល់សេចក្ដីអង្កេតដូចខាងក្រោម ៖

បញ្ហាព្រំដែនរវាង SRV និងប្រទេសកម្ពុជាគឺជាបញ្ហាប្រវត្តិសាស្ត្រ និងអាណានិគមពីមុន។ បញ្ហាព្រំដែនរវាងប្រទេសជិតខាងតែងតែបង្កជាជម្លោះ និងការប្រឈមមុខដោយប្រដាប់អាវុធ។ ពាក់ព័ន្ធនឹងបញ្ហាព្រំដែន និងទឹកដីរវាងប្រទេសវៀតណាម និងកម្ពុជា SRV យល់ឃើញថា ខ្លួនអាចដោះស្រាយបញ្ហាទាំងនេះបានជាមួយកម្ពុជាប្រជាធិបតេយ្យ ដោយឈរលើមូលដ្ឋាននៃការគោរពអធិបតេយ្យភាពទឹកដីទៅវិញទៅមក និងទំនាក់ទំនងល្អប្រសើរក្នុងនាមជាប្រទេសជិតខាង។ SRV នៅតែយល់ថា បញ្ហាព្រំដែនបច្ចុប្បន្នអាចដោះស្រាយបានតាមរយៈកិច្ចចរចាបិទទ្វាររវាងភាគីទាំងពីរ។ គ្មានភាគីណាមួយ នឹងទទួលបានប្រយោជន៍ពីការដាក់បញ្ហាទាំងនេះឲ្យអន្តរជាតិជួយដោះស្រាយឡើយ។ ផ្ទុយទៅវិញ វាត្រឹមតែផ្ដល់ប្រយោជន៍ដល់ពួកចក្រពត្តិ

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

និយម ដែលកំពុងព្យាយាមញុះញង់ឱ្យមានបញ្ហារវាងប្រទេសទាំងពីរប៉ុណ្ណោះ។ បន្ទាប់ពីរដ្ឋាភិបាល DK [កម្ពុជាប្រជាធិបតេយ្យ] បានបង្ហាញបញ្ហាជម្លោះព្រំដែននេះជាសាធារណៈតាមរយៈសេចក្តីប្រកាសរបស់ខ្លួនកាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ រដ្ឋាភិបាល SRV ត្រូវបង្ខំចិត្តបង្ហាញពីគោលជំហររបស់ខ្លួនជាសាធារណៈ។ សមមិត្ត Nghia បានគូសបញ្ជាក់ថា កងកម្លាំងប្រដាប់អាវុធរបស់ DK បានបំពានលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ SRV ជាច្រើនលើកច្រើនសា និងកំពុងប្រព្រឹត្តអំពើព្រៃផ្សៃលើប្រជាជនវៀតណាមក្នុងតំបន់ព្រំដែន ដូចជា ការបង្ករបួសធ្ងន់ធ្ងរលើពួកគេ។ ខណៈដែលមេដឹកនាំ DK ចាត់ទុក SRV ថាជាសត្រូវដ៏ចម្បង ដោយបង្ខំឱ្យមន្ត្រីស្ថានទូត SRV ប្រចាំទីក្រុងភ្នំពេញចាកចេញពីប្រទេសកម្ពុជា SRV បានបន្តចាត់ទុក

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

កម្ពុជាប្រជាធិបតេយ្យជាប្រទេសជាបងប្អូន និងប្ដេជ្ញារក្សាចំណងមិត្តភាព។ ដូច្នេះ SRV គ្មានបំណងបង្កបញ្ហាដល់ចំណងការទូតឡើយ។ មេដឹកនាំកម្ពុជាជាអ្នកទទួលខុសត្រូវទាំងស្រុងលើការដកបុគ្គលិកស្ថានទូតរបស់កម្ពុជាប្រជាធិបតេយ្យចេញពីទីក្រុងហាណូយ។

សមមិត្ត Nghia បានស្នើសុំឱ្យមានការបន្តគាំទ្រយ៉ាងរឹងមាំពីពួកយើងលើសេចក្ដីប្រកាសរបស់រដ្ឋាភិបាល SRV កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ជាពិសេសគោលជំហររបស់ SRV ស្ដីពីដំណោះស្រាយបញ្ហាព្រំដែននេះ។ ទន្ទឹមនឹងនេះ គាត់បានសំដែងការដឹងគុណចំពោះការចុះផ្សាយសេចក្ដីប្រកាសនេះក្នុង ND (មិនស្គាល់អក្សរកាត់) កាលពីថ្ងៃទី ២ ខែ មករា ឆ្នាំ ១៩៧៨ និងការផ្សព្វផ្សាយព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយរបស់ GDR ។

សមមិត្ត Moldt បានអរគុណ [សមមិត្ត Nghia] ដែលបានផ្ដល់សេចក្ដីប្រកាសនេះ និងបានបញ្ជាក់ច្បាស់ថា GDR នឹងគាំទ្រយ៉ាងពេញទំហឹងលើសេចក្ដីប្រកាសរបស់ SRV។ ក្រៅពីនេះ GDR ជឿជាក់ថាបញ្ហាព្រំដែនរវាង SRV និង DK អាចដោះស្រាយបានតាមរយៈកិច្ចចរចាបិទទ្វារ។ សមមិត្ត Moldt បានស្នើសុំរបាយការណ៍តាមដំណាក់កាលពីសមមិត្ត Nghia ស្ដីពីស្ថានភាពបច្ចុប្បន្នក្នុងតំបន់ដែលរងផលប៉ះពាល់ដោយសារការប្រឈមមុខដោយយោធា។

ជាបន្តបន្ទាប់ សមមិត្ត Nghia បានផ្ដល់ការពន្យល់ដូចខាងក្រោម ៖

ការប្រឈមមុខដោយយោធាបច្ចុប្បន្នរវាងវៀតណាម និងកម្ពុជាបានចាប់ផ្ដើមនៅរយៈពេលដ៏ខ្លីក្នុងពេលដែលមានការខ្វែងគំនិតគ្នាក្នុងចំណោមមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ កម្ពុជាប្រជាធិបតេយ្យស្ទើរតែផ្ដាច់ខ្លួនទាំងស្រុងចេញពីសហគមន៍អន្តរជាតិ។ ចាប់តាំងពីថ្ងៃរំដោះនៅឆ្នាំ ១៩៧៥ មក កម្ពុជាស្ទើរតែគ្មានភាពប្រសើរឡើងសោះលើការអភិវឌ្ឍសេដ្ឋកិច្ច។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានបង្កជម្លោះព្រំដែនដើម្បីបង្វែរចំណាប់អារម្មណ៍ចេញពីបញ្ហានយោបាយក្នុង និងក្រៅប្រទេស។ មេដឹកនាំទាំងនេះ បានដាក់ការស្ដីបន្ទោសលើ SRV ថាជាអ្នកធ្វើឱ្យអន្តរជាតិដាក់កម្ពុជាប្រជាធិបតេយ្យឱ្យនៅឯកោរ។ ដើម្បីបង្ខូចកេរ្ដិ៍ឈ្មោះរបស់ SRV មេដឹកនាំកម្ពុជាបានបង្កជម្លោះនៅក្នុងពេលដែលរដ្ឋមន្ត្រីការបរទេស SRV កំពុងធ្វើដំណើរទស្សនកិច្ចតាមបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ជាច្រើន។

សមមិត្ត Nghia បានគូសបញ្ជាក់ថា សាធារណរដ្ឋប្រជាមានិតចិន បានចុះផ្សាយសេចក្តីប្រកាសរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យស្ទើរតែដោយខ្លួនឯងទាំងស្រុង ប៉ុន្តែផ្នែកសំខាន់ៗបំផុតនៃសេចក្តីប្រកាសរបស់ SRV មិនត្រូវបានចុះផ្សាយឡើយ។

SRV យល់ថា ការចាកចេញនៃមន្ត្រីស្ថានទូតរបស់កម្ពុជាប្រជាធិបតេយ្យពីទីក្រុងហាណូយ គឺជារឿងដ៏គួរឲ្យសោកស្តាយ។ អនុរដ្ឋមន្ត្រីការបរទេស Nguyen Xhan បានអញ្ជើញឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យឲ្យចូលរួមជំនួបមិត្តភាពមុនពេលការចាកចេញនេះ។ សមមិត្តពាក់ព័ន្ធមកពីនាយកដ្ឋានទទួលបន្ទុកតំបន់អាស៊ីនៃក្រសួងការបរទេស SRV បានមកជូនដំណើរការចាកចេញនៃបុគ្គលិកស្ថានទូតរបស់កម្ពុជាប្រជាធិបតេយ្យនៅព្រលានយន្តហោះ។

[ហត្ថលេខា: Thummel]

Thummel

ប្រធានផ្នែក

<u>ចម្លងជូន ៖</u>

1. សមមិត្ត Moldt
2. ZK (គណៈកម្មាធិការមជ្ឈិម) នាយកដ្ឋានទី ៤
3. ស្ថានទូតប្រចាំទីក្រុងហាណូយ
4. HA I D [មិនស្គាល់អក្សរកាត់]
5. FO [ចុងបូព៌ា]

<u>ឧបសម្ព័ន្ធ</u>

[ប្រភព ៖ "ការពិត និងឯកសារស្តីពីការបំពានធ្ងន់ធ្ងររបស់កម្ពុជាប្រជាធិបតេយ្យមកលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម នាយកដ្ឋានបោះពុម្ពផ្សាយ និងព័ត៌មាននៃក្រសួងការបរទេស សាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨"]

## សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

## ស្តីពីបញ្ហាព្រំដែនរវាងប្រទេសវៀតណាម និងកម្ពុជា

ប្រទេសវៀតណាម និងកម្ពុជាគឺជាប្រទេសជិតខាងគ្នា និងជាប្រទេសជាបងប្អូន។ មិត្តភាពដ៏រឹងមាំដែលបានកសាងឡើង និងបន្តជំរុញក្នុងការតស៊ូដ៏យូរអង្វែងរយៈពេលជិតមួយសតវត្សរ៍ប្រឆាំងនឹងពួកអាណានិគម និងការប្រយុទ្ធតតាំងនឹងពួកឈ្លានពានចក្រពត្តិនិយមអាមេរិក និងបក្សពួក បានធ្វើឲ្យប្រជាជននៃប្រទេសទាំងពីរ និងបក្សកុម្មុយនីស្តទាំងពីររបស់វៀតណាម និងកម្ពុជាមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួត។ ទំនាក់ទំនងដ៏ពិសេសនេះគឺជាកត្តាកំណត់ជោគជ័យពេញលេញនៃបដិវត្តន៍វៀតណាម និងបដិវត្តន៍កម្ពុជា ដូចដែលគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាបានគូសបញ្ជាក់ក្នុងខ្លឹមសាររបស់ខ្លួនកាលពីថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៧៥ ជូនចំពោះគណៈកម្មាធិការមជ្ឈិមនៃបក្សពលករវៀតណាម ៖ "............បក្សកុម្មុយនីស្តកម្ពុជា និងប្រជាជនកម្ពុជា ព្រមទាំងបក្សពលករវៀតណាម និងប្រជាជនវៀតណាមបានរួមសាច់រួមឈាម និងបង្កើតចំណងសាមគ្គីដែលមិនអាចកាត់ផ្តាច់បានក្នុងការប្រយុទ្ធ និងទំនាក់ទំនងភាតរភាព"។

បក្សកុម្មុយនីស្តវៀតណាម រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម និងប្រជាជនវៀតណាមបានបង្កើតទំនាក់ទំនងជាបងប្អូនដ៏ល្អប្រសើរនេះ និងកម្មាធិវូបនីយកម្មរវាងប្រជាជននៃប្រទេសទាំងពីរ និងរវាងបក្សទាំងពីរ។ យើងបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការផ្សះផ្សារ និងពង្រឹងទំនុកចិត្តគ្នាទៅវិញទៅមក កិច្ចសហការដ៏ស្មោះត្រង់យូរអង្វែងរបស់យើង និងការជួយទំនុកបម្រុងគ្នាទៅវិញទៅមក ដោយផ្អែកលើគោលការណ៍សមភាពពេញលេញ ការគោរពអធិបតេយ្យភាព និងទឹកដី និងការមិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក។ បក្សកម្មុយនីស្តវៀតណាម រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម និងប្រជាជនវៀតណាមតែងតែគោរពឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី និងសេរីភាពរបស់ប្រទេសដទៃ ដោយពិចារណាថា វាជាគោលនយោបាយត្រឹមត្រូវដើម្បីការពារឯករាជ្យភាពជាតិរបស់យើង។

វាជាគោលនយោបាយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមដែលកំណត់ថា បញ្ហាព្រំដែន និងទឹកដីរវាងប្រទេសវៀតណាម និងកម្ពុជា គួរត្រូវបានដោះស្រាយ

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

ជាមួយកម្ពុជាប្រជាធិបតេយ្យដោយឈរលើមូលដ្ឋាននៃការគោរពអធិបតេយ្យភាពទឹកដីរបស់គ្នាទៅវិញទៅមក និងតាមរយៈការសម្របសម្រួល និងលើកកម្ពស់ទំនាក់ទំនងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការភាតរភាព រវាងប្រទេសទាំងពីរ តាមរយៈការកសាងទំនាក់ទំនងតាមព្រំដែនជាអចិន្ត្រៃយ៍រវាងប្រទេសវៀតណាម និង កម្ពុជា ដោយយោងតាមគោលការណ៍ស្មើភាព និងមានហេតុផល។

បក្ស និងរដ្ឋាភិបាលវៀតណាមតែងតែបន្តអនុវត្តគោលនយោបាយនេះ ប៉ុន្តែគួរឲ្យសោកស្តាយដែល កម្ពុជាបានបង្កើនភាពតានតឹងកាន់តែខ្លាំងឡើងតាមបន្ទាត់ព្រំដែន ដែលធ្វើឲ្យទំនាក់ទំនងរវាងប្រទេសទាំងពីរ កាន់តែអាក្រក់ឡើង។

នៅដើមខែ ឧសភា ឆ្នាំ ១៩៧៥ ប្រទេសកម្ពុជាបានដាក់ពង្រាយកងកម្លាំងរបស់ខ្លួនដើម្បីវាយលុកកោះ Phu Quoc និង Tho Chu និងបានធ្វើឲ្យពលរដ្ឋ ៥០០ នាក់បាត់បង់ជីវិត ព្រមទាំងបានវាយប្រហារចូលទៅក្នុង ទឹកដីវៀតណាមនៅតាមទីកន្លែងផ្សេងៗ ចាប់ពីខេត្ត Ha Tien រហូតដល់ខេត្ត Tay Ninh។ នៅខែ ធ្នូ ឆ្នាំ ១៩៧៥ កងកម្លាំងកម្ពុជាបានវាយលុកជាថ្មីម្តងទៀត និងគ្រប់គ្រងទឹកដីវៀតណាមក្នុងខេត្ត Gia Kontum និងខេត្ត Darlac។

ហេតុការណ៍នេះមានសភាពធ្ងន់ធ្ងរបំផុតចាប់តាំងពីខែ មេសា ឆ្នាំ ១៩៧៧ នៅពេលដែលកម្ពុជាបាន ប្រមូលផ្តុំកងទ័ពជាច្រើនកងពលធំ។ ដោយមានការបាញ់គាំទ្រទ្រង់ទ្រាយធំដោយកាំភ្លើងធំ និងកាំភ្លើងត្បាល់ ជាច្រើនដែលមានមូលដ្ឋានក្នុងទឹកដីកម្ពុជា កងកម្លាំងទាំងនេះបានវាយសង្រ្គប់លើតំបន់ព្រំដែនស្ទើរតែទាំងអស់ ចាប់ពីខេត្ត Ha Tien រហូតដល់ខេត្ត Tay Ninh។ កងកម្លាំងកម្ពុជាបានឆ្លោងគ្រាប់លើតំបន់ដែលមានប្រជាជន រស់នៅច្រើន និងតំបន់សេដ្ឋកិច្ចថ្មីៗ ដូចជា តំបន់ដែលនៅឆ្ងាយពីព្រំដែន ដូចជា ទីក្រុង Chau Doc និងតំបន់ប្រជុំ ជននៃខេត្ត Ha Tien និង Tinh Bien។ ក្នុងការវាយប្រហារទាំងនេះ កងកម្លាំងកម្ពុជាបានលួចឆក់ប្លន់ ដុតបំផ្លាញ និងកំទេចវត្តអារ៉ាម សាលារៀន និងមន្ទីរពេទ្យ។ នៅតាមទីកន្លែងជាច្រើន កងទ័ពកម្ពុជាបានប្រព្រឹត្ត ឧក្រិដ្ឋកម្មដ៏ឃោរឃៅ ចាប់រំលោភ ចាប់ហែកទារកចេញពីស្បូនម្តាយ វះពោះរូងយកពោះវៀនមនុស្សពេញវ័យ និងដុតកុមារទាំងរស់។ គ្រួសារជាច្រើនត្រូវបានសម្លាប់ទាំងគ្រួសារ។ កងកម្លាំងកម្ពុជាបានបង្កការខូចខាតយ៉ាង ច្រើនលើទ្រព្យសម្បត្តិ និងសម្លាប់ប្រជាជនជាច្រើនក្នុងមូលដ្ឋាន។ នៅតាមទីកន្លែងខ្លះ ពលរដ្ឋរាប់ពាន់នាក់ត្រូវ បានសម្លាប់ ឬបង្ករបួស ផ្ទះសម្បែងរាប់ពាន់ខ្នង និងទ្រព្យសម្បត្តិគ្រប់ប្រភេទត្រូវបានបំផ្លិចបំផ្លាញ ហើយ ពលរដ្ឋវៀតណាមរាប់សិបពាន់នាក់ត្រូវបានជម្លៀសចេញឆ្ងាយពីតំបន់ព្រំដែនដើម្បីរក្សាសន្តិសុខ។ ប្រជាជន វៀតណាមដែលរស់នៅដោយសន្តិភាពតាមបណ្តោយព្រំដែនបានទទួលរងការបំផ្លិចបំផ្លាញយ៉ាងដំណំ។

Original DE: 00537030-00537080

Note: This Khmer translation is based on the English version which was translated from the original German text.

កម្ពុជាបានរៀបចំយុទ្ធនាការស៊ីជម្រៅ និងធំធេងក្នុងចំណោមប្រជាជន និងកងទ័ពកម្ពុជា សំដៅសាប ព្រោះអរិភាពលើប្រជាជាតិវៀតណាម។ ក្នុងការឃោសនាជួរមុខ ដោយមានការរចនាមូលបង្កាច់ប្រទេស វៀតណាម និងបង្កឲ្យមានការយល់ច្រឡំជាសាធារណៈ សារព័ត៌មាន និងវិទ្យុកម្ពុជាបានបន្តផ្សព្វផ្សាយ របាយការណ៍ដែលចោទប្រកាន់ថា ប្រទេសវៀតណាមបានឈ្លានពានដោយគឃ្លើន ធ្វើអន្តរាគមន៍ និងវិទ្ធង្សនា ប្រឆាំងកម្ពុជា។

នៅចំពោះមុខការបំពានជាបន្តបន្ទាប់ទាំងនេះលើទឹកដីវៀតណាម ដោយប្រទេសកម្ពុជា ប្រជាជន និង កងកម្លាំងវៀតណាមដែលស្ថិតនៅតាមតំបន់ព្រំដែនត្រូវបង្ខំចិត្តវាយបកវិញដើម្បីការពារខ្លួន ធានាសុវត្ថិភាព អធិបតេយ្យភាពទឹកដីរបស់ខ្លួន និងការពារអាយុជីវិត ទ្រព្យសម្បត្តិ និងអត្ថិភាពដោយសន្តិភាព។

ទន្ទឹមនឹងនេះ បក្សកុម្មុយនីស្តវៀតណាម និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមបាន ទទូចជាបន្តបន្ទាប់ឲ្យមានកិច្ចចរចាជាមួយបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ សំដៅ ដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរឲ្យបានឆាប់រហ័សបំផុត។ នៅដើមខែ មេសា ឆ្នាំ ១៩៧៦ គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តវៀតណាម និងគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា បាន ព្រមព្រៀងថា មេដឹកនាំបក្សទាំងពីរ នឹងជួបប្រជុំគ្នានៅខែ មិថុនា ឆ្នាំ ១៩៧៦។ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំនេះ នៅដើមខែ ឧសភា ឆ្នាំ ១៩៧៦ ភាគីទាំងពីរបានរៀបចំកិច្ចប្រជុំត្រៀមមួយនៅទីក្រុងភ្នំពេញ។ កិច្ចប្រជុំនេះ ស្ទើរតែដំណើរការទៅហើយ ប៉ុន្តែក្រោយមក វាត្រូវបានពន្យារពេលទៅវិញដោយមានសំណើពីភាគីកម្ពុជា។ ក្រោយមកទៀត វៀតណាមបានស្នើជាច្រើនលើកច្រើនសាឲ្យរៀបចំកិច្ចប្រជុំនោះឡើងវិញ ប៉ុន្តែភាគីកម្ពុជា មិនបានឆ្លើយតបឡើយ។ នៅក្នុងកិច្ចប្រជុំរៀបចំកាលពីខែ ឧសភា ឆ្នាំ ១៩៧៦ ភាគីទាំងពីរបានព្រមព្រៀងលើ វិធានការជាក់លាក់បីសំដៅបង្កើនសាមគ្គីភាព និងដោះស្រាយជម្លោះព្រំដែន។ វិធានការទាំងនោះរួមមាន ៖ ភាគីទាំងពីរព្យាយាមអប់រំកម្មាភិបាល កងទ័ព និងប្រជាជននៅក្នុងប្រទេសរបស់ខ្លួនតាមតំបន់ព្រំដែនឲ្យពង្រឹង សាមគ្គីភាព និងចំណងមិត្តភាព និងបញ្ចៀសជម្លោះ។ រាល់ជម្លោះទាំងអស់ត្រូវដោះស្រាយ

ដោយឈរលើស្មារតីសាមគ្គីភាព មិត្តភាព និងការគោរពគ្នាទៅវិញទៅមក ហើយគណៈកម្មាធិការទំនាក់ទំនងរបស់ភាគីទាំងពីរត្រូវស៊ើបអង្កេតជម្លោះ និងជួបប្រជុំដើម្បីដោះស្រាយជម្លោះទាំងនោះ។

វៀតណាមបានអនុវត្តយ៉ាងតឹងរ៉ឹងទៅតាមវិធានការទាំងបីដែលបានព្រមព្រៀងគ្នា ប៉ុន្តែគួរឲ្យសោកស្តាយណាស់ដែលប្រទេសកម្ពុជាមិនបានអនុវត្តតាមវិធានការទាំងនេះ និងបានបន្តបំពានលើអធិបតេយ្យភាពទឹកដីវៀតណាមជាប្រព័ន្ធ និងក្នុងលក្ខណៈកាន់តែធ្ងន់ធ្ងរ។

នៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ១៩៧៧ គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តវៀតណាម និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម បានផ្ញើលិខិតមួយច្បាប់ទៀតទៅគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដោយស្នើឲ្យមានការរៀបចំកិច្ចប្រជុំនោះឲ្យបានឆាប់តាមដែលអាចធ្វើបានរវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សទាំងពីរ និងរដ្ឋាភិបាលទាំងពីរដើម្បីដោះស្រាយបញ្ហាព្រំដែនរវាងប្រជាជាតិទាំងពីរ។

ក្នុងលិខិតឆ្លើយតបរបស់កម្ពុជានៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៧៧ គណៈកម្មាធិការមជ្ឈិមបក្ស និងរដ្ឋាភិបាលកម្ពុជាបានពិចារណាថា កិច្ចប្រជុំនោះពិតជាមានសារៈសំខាន់ ប៉ុន្តែបានស្នើវិញថា ពួកគេអាចបន្តកិច្ចប្រជុំនេះឡើងវិញបាន លុះត្រាតែបន្ទាប់ពីអំឡុងពេលមួយ “ដែលស្ថានភាពប្រែជាប្រក្រតីវិញ ពោលគឺទាល់តែលែងមានជម្លោះព្រំដែនតទៅទៀត”។ យ៉ាងនេះក្តី ច្បាស់ណាស់ថា ភាគីកម្ពុជាបានបង្កើនការវាយប្រហារដោយយោធារបស់ខ្លួន ទន្ទ្រានចូលទឹកដីវៀតណាម និងសម្លាប់ជនស៊ីវិលវៀតណាម បង្កវិនាសកម្មលើប្រជាជនវៀតណាមដែលរស់នៅដោយសន្តិភាពក្នុងបណ្តាខេត្តតាមបណ្តោយព្រំដែន ជាពិសេស ខេត្ត Kien Giang, An Giang, Dong Thap, Long An និង Tay Ninh។

ការពិតស្តីពីការវិវឌ្ឍនៅតំបន់ព្រំដែន និងសកម្មភាពឧក្រិដ្ឋកម្មរបស់កម្ពុជាក្នុងរយៈពេលពីរឆ្នាំកន្លងមកបានគ្របដណ្តប់លើការមួលបង្កាច់វៀតណាមក្នុងសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ នេះជាការបំផ្លើសព័ត៌មានដ៏គឃ្លើនលើការវិវឌ្ឍនៅតាមព្រំដែនរវាងប្រទេសទាំងពីរ ជាការបំភ្លៃដែលប៉ះពាល់ធ្ងន់ធ្ងរដល់ទំនាក់ទំនងយ៉ាងជិតស្និទ្ធពីមុនមករវាងប្រជាជននៃប្រទេសទាំងពីរ។ ការមួលបង្កាច់នេះគឺផ្ទុយស្រឡះទាំងស្រុងនឹងអ្វីដែលបានរៀបរាប់យ៉ាងច្បាស់ក្នុងខ្លឹមសារកាលពីថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ដែលផ្ញើជូនដោយគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ជូនចំពោះ

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

គណៈកម្មាធិការមជ្ឈិមនៃបក្សពលករវៀតណាមថា "គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះបក្សពលករវៀតណាម និងប្រជាជនវៀតណាមដែលបានគាំទ្រ និងជួយដល់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងសង្គ្រាមបដិវត្តន៍រំដោះជាតិ និងរំដោះប្រជាជន និងក្នុងដំណាក់កាលប្រវត្តិសាស្ត្រថ្មីរបស់កម្ពុជាបន្ទាប់ពីការរំដោះ។

ដោយក្តីស្មោះត្រង់ទៅនឹងគោលនយោបាយរបស់ខ្លួន រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមបានប្រកាសជាផ្លូវការថា វៀតណាមប្តេជ្ញាការពារឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ខ្លួន ហើយទន្ទឹមនឹងនេះ តែងតែគោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា និងលះបង់អ្វីៗគ្រប់យ៉ាងដើម្បីរក្សាចំណងសាមគ្គីភាពកងទ័ព និងមិត្តភាពដ៏រឹងមាំរវាងប្រទេសវៀតណាម និងកម្ពុជា។ នេះជាគោលជំហារក្នុងគោលការណ៍ និងជាគោលជំហារដ៏យុត្តិធម៌ និងឥតងាករេរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម។

ជាថ្មីម្តងទៀត រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមបានស្នើថា ភាគីទាំងពីរគួរជួបប្រជុំឲ្យបានឆាប់បំផុត មិនថានៅកម្រិតណាក៏ដោយ ដើម្បីរួមគ្នាដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរដោយឈរលើស្មារតីភាពជាបងប្អូន។

ប្រជាជននៃប្រទេសទាំងពីរធ្លាប់បានប្រកៀកស្មាគ្នាប្រយុទ្ធតស៊ូជាច្រើនសតវត្សរ៍ប្រឆាំងនឹងការឈ្លានពានរបស់ពួកចក្រពត្តិនិយមដើម្បីទាមទារឯករាជ្យភាព និងសេរីភាពរបស់ប្រទេសនីមួយៗ និងទទួលបានជ័យជំនះប្រកបដោយផ្លែផ្កា។ ទាំងផលប្រយោជន៍ចំពោះមុខ និងយូរអង្វែងរបស់ប្រជាជនវៀតណាម និងកម្ពុជាសុទ្ធតែតម្រូវឲ្យពួកគេបន្តរក្សាចំណងសាមគ្គីភាព និងមិត្តភាពដោយឈរលើស្មារតីនៃការគោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរៀងខ្លួន និងមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង និងកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមកដោយឈរលើបុព្វហេតុនៃការការពារប្រទេសរបស់ខ្លួន និងផលប្រយោជន៍បដិវត្តន៍ដែលប្រជាជាតិនីមួយៗទទួលបាន តាមរយៈការលះបង់យ៉ាងច្រើន និងការជំនះការលំបាកយ៉ាងច្រើនលើសលប់។

ប្រជាជន និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមជឿជាក់ថា យោងតាមផលប្រយោជន៍ចំពោះមុខ និងយូរអង្វែងរបស់ប្រជាជាតិទាំងពីរ បញ្ហាព្រំដែនរវាងប្រទេសទាំងពីរប្រាកដជាអាចដោះស្រាយ

បានដោយជោគជ័យ។ នេះជាបំណងប្រាថ្នាដ៏មោះមុតរបស់ប្រជាជននៃប្រទេសទាំងពីរ និងជាក្តីសង្ឃឹមរបស់ប្រជាជនដែលស្នេហាសន្តិភាពក្នុងតំបន់ និងកន្លែងផ្សេងទៀតក្នុងពិភពលោក។ ចំណងមិត្តភាពដ៏ធំធេង និងសាមគ្គីភាពកងទ័ពរវាងប្រជាជននៃប្រទេសទាំងពីរស្ថិតនៅជាអមតៈ និងគ្មានអ្វីអាចបំបែកបំបាក់បានឡើយ។

ទីក្រុងហាណូយ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧

[កំណត់សម្គាល់សរសេរដៃមិនច្បាស់]

[ត្រា:]

[មិនច្បាស់]

ថ្ងៃទី ៧ ខែ សីហា ឆ្នាំ១៩៧៨

[មិនច្បាស់]: VD271

ស្ថានទូត GDR ប្រចាំ SRV

ទីក្រុងហាណូយ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៧៨

[ត្រា:]

ចុងបូព៌ា

ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៧៨

[មិនច្បាស់] VD 313

[មិនច្បាស់]

| ឯកសារសម្ងាត់ | | | | |
|---|---|---|---|---|
| ផ្នែកភស្តុតាង | លេខលំដាប់ | ឆ្នាំ | ចំនួនច្បាប់ឯកសារ | ចំនួនទំព័រ |
| AV ទីក្រុងហាណូយ | 81 | 78 | 2 | 1-4 |

## កំណត់សម្គាល់

ស្តីពីព័ត៌មានដែលផ្តល់ដោយទីប្រឹក្សា ជូនចំពោះរដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម សមមិត្ត Nguyen Huu Nge ពាក់ព័ន្ធនឹងស្ថានភាពក្នុងកម្ពុជាប្រជាធិបតេយ្យកាលពីថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៧៨។

---

ជាដំបូង ទីប្រឹក្សាបានគូសបញ្ជាក់ថា គាត់នឹងផ្តល់ព័ត៌មានទៅតាមសំណើរបស់ឯកអគ្គរដ្ឋទូតជាច្រើន និងភារធារីនៃបណ្តាប្រទេសសង្គមនិយម។

ទោះបីជាមានការចុះចេញយ៉ាងដំណាំក៏ដោយ ក៏បនប៉ុល ពត អៀង សារី នៅបន្តគោលនយោបាយយោធាប្រតិកិរិយាប្រឆាំងនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម។ កម្ពុជាបានពង្រាយកងកម្លាំងភាគច្រើនបំផុតរបស់ខ្លួនតាមបន្ទាត់ព្រំដែនជាមួយប្រទេសវៀតណាម (កងពលធំ ១៤/១៧ និងកងវរសេនាធំ ១៦ កង)។ កងកម្លាំងបានបើកការវាយប្រហាររួមតាមបណ្តោយព្រំដែន។ ទន្ទឹមនឹងនេះ មានបទបញ្ជាឲ្យធ្វើប្រតិបត្តិការបំផ្លិចបំផ្លាញយ៉ាងព្រៃផ្សៃក្នុងទឹកដី SRV ដោយអនុវត្តតាមឃ្លាថា “សម្លាប់មនុស្សគ្រប់រូប លួចឆក់ប្លន់អ្វីៗគ្រប់យ៉ាង ដុតកំទេចអ្វីៗទាំងអស់”។ បណ្តាខេត្តវៀតណាម ដូចជា An Giang, Tay Ninh និង Song Be ទទួលរងការវាយប្រហារធ្ងន់ធ្ងរខ្លាំងជាងគេពីប្រតិបត្តិការទាំងនេះ។ នៅអំឡុងថ្ងៃទី ២២-៣០ ខែ មេសា ឆ្នាំ ១៩៧៨ កងវរសេនាតូចចំនួន ៦ របស់កម្ពុជាបានវាយលុកចូលក្នុងទឹកដីវៀតណាមប្រមាណ ១៦ គីឡូម៉ែត្រ និងក្រុងចំនួន ៧ ក្នុងខេត្ត An Giang ដែលធ្វើឲ្យមានមនុស្សស្លាប់ និងរបួស ២.០០០ នាក់សម្រាប់ភាគីវៀតណាម។ ក្នុងភូមិមួយ ផ្ទះចំនួន ៣.៦០០ ខ្នងត្រូវបានដុតបំផ្លាញចោល។

នៅថ្ងៃទី ១០ ខែ ឧសភា វិទ្យុកម្ពុជាបានរាយការណ៍ថា កងទ័ពកម្ពុជាបានវាយលុកចូលក្នុងទឹកដីវៀតណាម។ នៅថ្ងៃតែមួយនោះ វិទ្យុដដែលបានបន្តចំអកឲ្យវៀតណាមដោយដាក់បទបញ្ជាថា

កងទ័ពកម្ពុជាម្នាក់ត្រូវប្រយុទ្ធនឹងកងទ័ពវៀតណាម ៣០ នាក់។ កម្ពុជានឹងលះបង់ប្រជាជន ២ លាននាក់ដើម្បីយកឈ្នះប្រជាជនវៀតណាម ៥០ លាននាក់។ កម្ពុជានឹងប្រយុទ្ធយកឈ្នះវៀតណាម ទោះបីជាត្រូវចំណាយពេល ៧០០ ឆ្នាំក៏ដោយ។

រហូតមកទល់បច្ចុប្បន្ននេះ បន ប៉ុល ពត-អៀង សារី បានបដិសេធដាច់ខាតមិនបើកការចរចាជាមួយ SRV។ ~~មានការរាយការណ៍ថា~~ សំណើដែលស្នើឡើងដោយ SRV ក្នុងសេចក្តីប្រកាសកាលពីថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ នៅរក្សាដដែល ប៉ុន្តែមិនទទួលបានការឆ្លើយតបឡើយ។ ~~សេចក្តីរាយការណ៍បញ្ជាក់ថា~~ នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៧៨ ភាគីកម្ពុជាបានបដិសេធអនុស្សារណៈថ្មីទៀតពី SRV ដែលបញ្ជាក់ឡើងវិញពីសំណើមុនៗ។ ~~មានការចោទប្រកាន់ថា~~ បន្ទាប់មក នៅថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៨ បន ប៉ុល ពត-អៀង សារី (មិនច្បាស់) បានដាក់លក្ខខណ្ឌបួនដែល SRV មិនអាចទទួលយកបាន។ ក្រៅពីនេះ កម្ពុជាបានបដិសេធសំណើរបស់ SRV កាលពីថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ១៩៧៨ ក្នុងការបញ្ចប់សង្គ្រាមភ្លាមៗ និងចាប់ផ្តើមចរចា។ នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៧៨ កម្ពុជាបានមួលបង្កាច់សាធារណរដ្ឋសង្គមនិយមវៀតណាមថាបានសហការជាមួយ CIA ដើម្បីផ្តួលរំលំរដ្ឋាភិបាលកម្ពុជា។ ~~មានការលើកឡើងថា~~ សាធារណរដ្ឋសង្គមនិយមវៀតណាមបានបដិសេធការមួលបង្កាច់នេះក្នុងសេចក្តីប្រកាសរបស់ខ្លួនកាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៧៨។

~~គេនិយាយថា~~ សង្គ្រាមតាមបណ្តោយព្រំដែនវៀតណាមភាគនិរតីគឺជាសង្គ្រាមដែលបង្កឡើងដោយមេដឹកនាំទីក្រុងប៉េកាំង ដើម្បីបំបែកបំបាក់ប្រជាជនក្នុងតំបន់ឥណ្ឌូចិនឲ្យឃ្លាតឆ្ងាយពីគ្នាតាមរយៈគោលនយោបាយវាតទីនិយមក្នុងតំបន់ឥណ្ឌូចិន។ សាធារណរដ្ឋប្រជាមានិតចិនបានគាំទ្រ~~មន~~កម្ពុជា តាមគ្រប់មធ្យោបាយ ~~ដើម្បីឱ្យកម្ពុជាអាចបង្កសង្គ្រាមជាមួយវៀតណាមបាន។~~ ~~មិនបានបង្កើន~~ការដឹកជញ្ជូនអាវុធ ~~រួមទាំងគ្រឿងសព្វាវុធទំនើបបំផុត~~ (ឧ. កាំភ្លើងធំទំហំ ១៣០ មីល្លីម៉ែត្រ) កេះគ្រាប់គីមី និងគ្រាប់បែកបណ្តែតទឹក។ ~~បច្ចុប្បន្ននេះ~~ មានសេចក្តីរាយការណ៍ថា មានទីប្រឹក្សាចិនចំនួន ៧.០០០ នាក់ក្នុងប្រទេសកម្ពុជា។ ពួកគេត្រូវធ្វើការបណ្តុះបណ្តាលកងកម្លាំង ទាហានជើងទឹក និងទ័ពអាកាសកម្ពុជា ហើយពួកគេក៏បញ្ជារថក្រោះ កាំភ្លើងត្បាល់ និងស្ថានីយ៍រ៉ាដាផងដែរ។ ក្រៅពីនេះ មានអង្គភាពចិនក្នុងប្រទេសកម្ពុជាដែលស្លៀកពាក់ឯកសណ្ឋានពណ៌ខៀវ បន្លំខ្លួនក្នុងចំណោមកម្មករធ្វើផ្លូវ និងផ្លូវដែក ប៉ុន្តែនឹងចូលរួមដោយផ្ទាល់ក្នុងការប្រយុទ្ធ។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

~~បន-ប៉ុល-ពត-អៀង-សារី បានប្រែក្លាយកម្ពុជាប្រជាធិបតេយ្យទៅជាទីវាលពិឃាត។~~ (មិនច្បាស់) ~~បន~~ មេដឹកនាំទាំងនេះបានធ្វើប្រតិបត្តិការដ៏ព្រៃផ្សៃក្នុងបក្ស រចនាសម្ព័ន្ធរដ្ឋ និងកងទ័ពដើម្បីបំផ្លាញកម្លាំងប្រឆាំង។ ~~ប្រតិបត្តិការទាំងនេះធ្វើឡើងភាគច្រើននៅតាមបណ្តាខេត្ត និងទីក្រុងនានា។~~ ក្នុងតំបន់បូព៌ានៃប្រទេសកម្ពុជា អង្គភាពមូលដ្ឋានទាំងមូល (Grundorganizationen) របស់បក្សត្រូវបានរំលាយចោល ហើយសមាជិកជាច្រើន [មិនច្បាស់] ត្រូវបានបណ្តេញចេញ។ មន្ត្រីប្រមាណ <u>៥០០ នាក់</u>នៃកងពលធំលេខ ២៨០ ត្រូវបានចាប់ខ្លួន។ កងវរសេនាតូចជាច្រើនត្រូវបានដកហូតអាវុធ។

~~យ៉ាងនេះក្តី~~ នៅដើមឆ្នាំ ១៩៧៦ គេឃើញមានការបះបោរប្រឆាំងនឹងរបបនេះ។ ចលនាប្រឆាំងទទួលបានកម្លាំងចលករដ៏អស្ចារ្យដោយមានពាក្យស្លោកថា “យើងចង់បានអាហារបរិភោគគ្រប់គ្រាន់” “សន្តិភាព” និង “ទុកឲ្យសមាជិកគ្រួសារទាំងអស់រួមរស់ក្រោមដំបូលតែមួយ”។ មន្ត្រីជាន់ខ្ពស់ជាច្រើន (អគ្គសេនាធិការ និងមេបញ្ជាការកងពលធំ) បានចូលរួមក្នុងប្រតិបត្តិការប្រឆាំងទន្ទឹមគ្នានឹងមន្ត្រីបក្ស និងរដ្ឋ ដូចជា អភិបាលខេត្ត។ នៅចុងខែ ឧសភា ឆ្នាំ ១៩៧៨ ចលនាបះបោរធំៗបានផ្ទុះឡើងនៅភាគខាងកើត ~~ក្នុងខេត្តព្រៃវែង កំពង់ចាម ស្វាយរៀង ក្រចេះ និងតាកែវ។ កាលពីមុន ប្រជាជនខេត្តបាត់ដំបងបានក្រោកឡើងបះបោរ។~~ មានការរាយការណ៍ថា ប្រតិបត្តិការប្រឆាំងត្រូវបានធ្វើឡើងក្នុង~~តំបន់ភាគពាយ័ព្យ ក្នុងខេត្តកោះកុង និងក្នុងខេត្តកំពង់ធំដែលជា~~តំបន់នៅចំកណ្តាលប្រទេសកម្ពុជា។

កម្មករចម្ការកៅស៊ូ និងសហគ្រាស កងទ័ពស្រួច និងកងទ័ពមូលដ្ឋាន កម្មាភិបាលមកពីភូមិភាគកងទ័ព និងមន្ត្រីជាន់ខ្ពស់របស់បក្ស និងរដ្ឋបានចូលរួមក្នុង~~ចលនាប្រឆាំងនេះ~~។ មានសេចក្តីរាយការណ៍ថា កងវរសេនាតូចទាំងមូល បានប្រឆាំងនឹងបទបញ្ជា។ នៅភាគខាងកើតនៃប្រទេស បន ប៉ុល ពត-អៀង សារី ត្រូវដាក់ពង្រាយកងពលធំចំនួន ៣ ដោយមានការគាំទ្រពីកាំភ្លើងត្បាល់ និងតាមផ្លូវអាកាសប្រឆាំងនឹងការបះបោរនេះ។

យ៉ាងនេះក្តី ពួកឧទ្ទាមដឹង~~ពីរបៀបរក្សាកម្លាំងរបស់ខ្លួន និង~~បានដកថយរត់ចូលព្រៃ។ ~~បច្ចុប្បន្ននេះ~~ មានការរាយការណ៍ថា ការវិវឌ្ឍនៃកងកម្លាំងទាំងនេះស្ថិតនៅដដែល។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

បច្ចុប្បន្ននេះ បន ប៉ុល ពត-អៀង សារី នៅតែមានកងកម្លាំងមួយចំនួន និងការគាំទ្រពីសាធារណរដ្ឋប្រជាមានិតចិន ដែលអាចបង្កការលំបាកដល់ប្រទេសវៀតណាម។ SRV ប្ដេជ្ញាធ្វើការវាយបកលើសង្គ្រាមបង្កឡើងដោយបននេះ ~~ដែលត្រូវបានការពារដោយមេដឹកនាំប្រតិកិរិយាទីក្រុងប៉េកាំង~~ រហូតដល់របបនេះដួលរលំ។ ទន្ទឹមនឹងនេះ ~~មានសេចក្ដីរាយការណ៍ថា~~ SRV ចង់ឃើញដំណោះស្រាយដោយសន្តិវិធីតាមរយៈកិច្ចចរចា។ ~~សំណើសមស្រប និងសមហេតុផលដែលដាក់ជូនដោយភាគីវៀតណាមនៅតែរក្សាដដែល។~~ ប្រជាជនកម្ពុជាផ្ទាល់នឹងរួមដៃផ្ដួលរំលំ~~មន~~មេដឹកនាំកម្ពុជា។

នៅពេលអ្នកចូលរួមម្នាក់ក្នុងការផ្ដល់ព័ត៌មានសង្ខេប សាកសួរពីភាពត្រឹមត្រូវនៃរបាយការណ៍ដែលបង្ហាញថា ~~កងកម្លាំងប្រឆាំងរំដោះបានខេត្តព្រះសីហនុ~~ ទីប្រឹក្សានោះបានឆ្លើយតបថា គាត់ក៏បានទទួលបានព័ត៌មានដូច្នេះដែរ។

<u>ចម្លងជូន:</u>

ក្រសួងការបរទេស នាយកដ្ឋានចុងបូព៌ា

<u>គណៈកម្មាធិការមជ្ឈិម/នាយកដ្ឋានទី ៤</u>

ក្រសួងការបរទេស, HAID

ទីក្រុងហាណូយ AV

[ហត្ថលេខា]

Z o r n

ឯកអគ្គរដ្ឋទូត

VD-E S+B 750/79

| ឯកសារសម្ងាត់ | | | | |
|---|---|---|---|---|
| ផ្នែកភស្តុតាង | លេខលំដាប់ | ឆ្នាំ | ចំនួនច្បាប់ឯកសារ | ចំនួនទំព័រ |
| 101 | 6 | 79 | 6 | 4 |

Adn [*Allgemeiner Deutscher Nachrichtendienst* (សេវាព័ត៌មានអាល្លឺម៉ង់ទូទៅ)] ទីក្រុងហាណូយ

[ត្រា] ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៨០
[ត្រា] ចុងប៉ូព៌ា
ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៧៩
លិខិតផ្ញើជូនលេខ: VD 51
លិខិតផ្ញើចេញលេខ: ________

[ត្រា មិនច្បាស់]
[កំណត់សម្គាល់សរសេរដៃ មិនច្បាស់]
VD 56

ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ១៩៧៩

**របាយការណ៍ចារកម្ម**

-----------------------

ជោគជ័យនៃកងកម្លាំងប្រជាជនក្នុងប្រទេសកម្ពុជា បានធ្វើឲ្យមានស្ថានភាពថ្មីមួយក្នុងតំបន់។ ជាលទ្ធផល តំបន់ឥណ្ឌូចិនទាំងមូលត្រូវបានបំបែកចេញផុតពីរង្វង់ឥទ្ធិពលជាប្រពៃណីរបស់ចិន។ សមមិត្តវៀតណាមយល់ឃើញថា លទ្ធផលនេះក៏បានផ្តល់ឱកាសថ្មីៗសម្រាប់ឲ្យរបបសង្គមនិយមក្នុងតំបន់អាស៊ីអាគ្នេយ៍ទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុផងដែរ។

យ៉ាងនេះក្តី យោងតាមទស្សនៈរបស់វៀតណាម ព្រឹត្តិការណ៍នានាបានជំរុញឲ្យមានការបែកខ្ញែកគ្នាកាន់តែខ្លាំងរវាងប្រទេសសង្គមនិយម។ អ្វីដែលនឹកស្មានមិនដល់គឺយោងតាមទស្សនៈរបស់ SRV ប្រទេសរូម៉ានីយូហ្គោស្លាវី និង DPRK បានរួមដៃជាមួយប្រទេសចិនដោយចោទប្រកាន់ថា វៀតណាមបានឈ្លានពានទៅតាមទ្រឹស្តីចក្រពត្តិនិយម។ ក្នុងបរិបទនេះ ប្រទេសទាំងនេះបានបង្កវិវាទបន្ថែមទៀតក្នុងឆាកនយោបាយអន្តរជាតិ។

ជាលទ្ធផលនៃព្រឹត្តិការណ៍ទាំងនេះ គេរំពឹងថានឹងមានការងាករេបន្ថែមទៀតក្នុងចលនារដ្ឋមិនចូលបក្សសម្ព័ន្ធ។ ការឆ្លើយតបនានាមានចាប់ពីការទទួលស្គាល់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជាចំពោះការថ្កោលទោសរបស់ SRV។ ការណ៍នេះបានបង្កើតជាបញ្ហាបន្ថែមទៀតសម្រាប់កិច្ចពិភាក្សានៅក្នុងកិច្ចប្រជុំកំពូលនៅខែកញ្ញា របស់ក្រុមប្រជាជាតិក្នុងទីក្រុង Havana។ ការងាករេទាំងនេះកើតចេញពីយុទ្ធសាស្ត្ររបស់ចិនក្នុងការ

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

បន្សាបចលនាប្រទេសមិនចូលបក្សសម្ព័ន្ធ សម្រាប់ជាផ្នែកនៃការជំទាស់ប្រទេសសង្គមនិយមចូលបក្សសម្ព័ន្ធក្នុងការប្រឆាំងនឹងរបបចក្រពត្តិនិយម និងព្យាយាមបន្តិចម្តងៗធ្វើឲ្យមានការប្រយុទ្ធប្រឆាំងនឹង "អនុត្តរភាពនិយម"។ បណ្តាប្រទេសសង្គមនិយមដែលបានលើកឡើងពីខាងដើមបានបន្តផ្តល់ការគាំទ្រដល់យុទ្ធសាស្ត្រនេះ។

ការឆ្លើយតបរបស់បណ្តាប្រទេសមូលធនដ៏មានឥទ្ធិពលបំផុតមានលក្ខណៈអវិជ្ជមានបំផុត។ ការពិតដែលជប៉ុន និងអូស្ត្រាលីបានកាត់ផ្តាច់ជំនួយសេដ្ឋកិច្ចរបស់ខ្លួនដល់ SRV មិនបានបង្កបញ្ហាធ្ងន់ធ្ងរដល់សេដ្ឋកិច្ចរបស់វៀតណាមឡើយ។

យ៉ាងនេះក្តី សមមិត្តវៀតណាមបានផ្តោតចំណាប់អារម្មណ៍លើជោគជ័យផ្នែកខ្លះក្នុងឥរិយាបថវិជ្ជមានបំផុតរបស់ FCP (បក្សកុម្មុយនីស្តបារាំង), ICP (បក្សកុម្មុយនីស្តអ៊ីតាលី) និង CPJ (បក្សកុម្មុយនីស្តជប៉ុន)។ ក្នុងទស្សនៈរបស់ពួកគេ ICP និង CPJ បានគាំទ្រវៀតណាមដោយឥតលក្ខខណ្ឌ។

<u>ស្ថានភាពក្នុងប្រទេសកម្ពុជា</u>

<u>ស្ថានភាពក្នុងប្រទេសកម្ពុជាផ្ទាល់នៅតែមានលក្ខណៈស្មុគស្មាញ និងពិបាកយល់បំផុត។ យោងតាមសមមិត្ត Hoang Tung កងកម្លាំងបដិវត្តន៍របស់កម្ពុជា និងកងទ័ពប្រជាជនវៀតណាមបានរួមគ្នាគ្រប់គ្រង</u>

ទីក្រុង ទីប្រជុំជន និងផ្លូវសំខាន់ទាំងអស់។ មានការលើកឡើងថា កងកម្លាំងរបស់ ប៉ុល ពត ត្រូវបានបំបែក និងកំពុងប្រមូលផ្តុំក្រុមឡើងវិញ និងចាប់ផ្តើមរៀបចំការវាយបកវិញ។ សកម្មភាពនេះអាចអនុវត្តទៅបានតាមរយៈការប្រើប្រាស់អាវុធ និងគ្រាប់រំសេវជាច្រើន ដែលផ្តល់ដោយប្រទេសចិនក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ និងត្រូវបានរក្សាទុកក្នុងឃ្លាំងផ្សេងៗ។ តាមរយៈការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ ១ ភាគ ៣ របស់ខ្លួន មានការរាយការណ៍ថា កងកម្លាំងប្រមាណ ២ ភាគ ៣ ទៀតបានប្រចាំការនៅព្រំដែនភាគខាងជើង ពោលគឺ SRV បានដាក់ពង្រាយកងកម្លាំងជាច្រើនក្នុងប្រទេសកម្ពុជា។ យោងតាមព័ត៌មានរបស់យើង កងទ័ព ប៉ុល ពត ដែលនៅសេសសល់មានសរុបប្រមាណ ១០.០០០ នាក់ និងធ្វើប្រតិបត្តិការជាក្រុមតូចៗ (ដែលមានកម្លាំងប្រហាក់ប្រហែលនឹងកងវរសេនាតូច)។ ការគំរាមកំហែងដ៏សំខាន់បំផុតនៃប្រតិបត្តិការរបស់ពួកគេ គឺស្ថិតនៅខេត្តមណ្ឌលគីរី តំបន់និរតី ដូចជា ខេត្តពោធិ៍សាត់ និងខេត្តកោះកុង តំបន់ជុំវិញបឹងទន្លេសាប និងតំបន់កំពត (រួមទាំងកំពង់ផែកំពង់សោម)។ យោងតាមទស្សនៈរបស់សមមិត្តវៀតណាមរបស់យើង គេប្រហែលជាត្រូវចំណាយពេលជាច្រើនខែដើម្បីលុបបំបាត់ការប្រឆាំង។ យោងតាមសមមិត្ត Hoang Tung កាំភ្លើងធំធុនធ្ងន់ដែលផ្គត់ផ្គង់ដោយប្រទេសចិនគឺជាការគំរាមកំហែងដ៏ធំបំផុត និងបានបង្កជាបញ្ហាសម្រាប់កងទ័ព និងកងកម្លាំងវៀតណាមក្នុងអំឡុងកើតមានសង្គ្រាមព្រំដែន។

យ៉ាងនេះក្តី រដ្ឋធានីភ្នំពេញលែងស្ថិតក្រោមការគំរាមកំហែងដូច្នេះទៀតហើយ ព្រោះគេអាចរុញច្រានកងកាំភ្លើងធំរបស់សត្រូវបានប្រមាណជាង ៣០ គីឡូម៉ែត្រចេញពីទីក្រុង។ ទីក្រុងភ្នំពេញនៅតែជាទីក្រុងខ្មោច។ គេមិនសូវឃើញអ្នកវិលត្រឡប់មកកាន់ទីក្រុងនេះវិញឡើយ។ នៅតែមិនមានកិច្ចពិភាក្សានៃការវិលត្រឡប់ដែលមានការរៀបចំនៅអំឡុងខែនេះ។ វិថីមួយចំនួនមានភ្លើងអគ្គិសនី និងទឹកប្រើប្រាស់ ប៉ុន្តែជារួម វិថីទាំងនោះត្រូវមានការស្តារឡើងវិញ។ ជំហាននានាដើម្បីស្តារផលិតកម្មក្នុងសហគ្រាសពីរបីក្នុងទីក្រុងភ្នំពេញ និងការវិលត្រឡប់មករកភាពប្រក្រតីវិញមិនទាន់ត្រូវបានអនុវត្តទេ។

នៅពេលបច្ចុប្បន្ននេះ ការរាយការណ៍ជាប្រចាំស្តីពីការស្តារភាពប្រក្រតីឡើងវិញក្នុងប្រទេសកម្ពុជានៅមិនទាន់អាចសម្រេចបានឡើយក្នុងកាលៈទេសៈនេះ។ ការសន្និដ្ឋានរបស់យើងគឺ ត្រូវមានការបែងចែកពេលវេលាប្រហាក់ប្រហែលគ្នាទៅនឹងអំឡុងពេលរំដោះបណ្តាខេត្តវៀតណាមខាងត្បូង ដើម្បីសម្រេចបានកម្រិតចង់បាននៃការរាយការណ៍។ ការរាយការណ៍ និងសកម្មភាពឃោសនាត្រូវបានរាំងស្ទះបន្ថែមទៀតដោយការខ្វះខាតដ៏ច្រើននៃកម្មាភិបាលខាងភាគីកម្ពុជា (ដែលមានទំហំធំធេងខ្លាំងជាងប្រទេសឡាវ)។ ក្នុងទីក្រុង

ហាណូយ អ្វីដែលសំខាន់បំផុតគឺការផ្សារភ្ជាប់ទៅនឹងការបញ្ជាក់ភាពចាំបាច់ក្នុងការផ្តួលរំលំរបបនេះ និងកេរដំណែលរបស់មេដឹកនាំថ្មីៗ។ ក្នុងបរិបទនោះ សមមិត្តដែលទទួលខុសត្រូវលើពួកយើងយល់ឃើញថា អ្វីដែលសំខាន់បំផុតគឺត្រូវធ្វើឡើងឲ្យបានឆាប់បំផុតនូវការពន្លឿនការរាយការណ៍ ស្តីពី

ការវិលត្រឡប់ទៅរកស្ថានភាពប្រក្រតីនៃជីវិតរស់នៅប្រចាំថ្ងៃ។ បញ្ហាតែមួយគត់គឺអំណាចរបស់ប្រជាជន (Volksmacht) ក្នុងប្រទេសកម្ពុជាមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ ហើយយើងមិនអាចចូលទៅដល់តំបន់ទាំងនេះបានទេ។ ដូចដែលសមមិត្ត Hoang Tung បានលើកឡើងថា "យើងមិនអាចបង្ហាញដល់តែប្រជាជនរបស់យើងបានយូរអង្វែងតទៅទៀតបានឡើយ" (ក្នុងទីក្រុងភ្នំពេញ គេមើលឃើញច្បាស់ថា កងទ័ពប្រជាជនវៀតណាមបានរៀបចំកងកម្លាំងប្រយុទ្ធ)។

បច្ចុប្បន្ន មានការគ្រោងដំណើរទស្សនកិច្ចលើកទីបីរបស់អ្នកឆ្លើយឆ្លងពីទីក្រុងហាណូយមកកាន់ទីក្រុងភ្នំពេញតាមរយៈទីក្រុងហូជីមិញ។ យោងតាមសមមិត្តដែលទទួលខុសត្រូវលើដំណើរទស្សនកិច្ចនេះ ពួកគេនឹងស្នាក់នៅក្នុងទីក្រុងភ្នំពេញត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ពោលគឺដូចគ្នានឹងករណីនៃដំណើរទស្សនកិច្ចចំនួនពីរលើកក្នុងពេលមុនដែរ។

យោងតាមសមមិត្តវៀតណាម តួនាទីសំខាន់ៗទាំងអស់របស់ក្រុមប្រឹក្សាបដិវត្តន៍ប្រជាជន និងប៉ុស្តិ៍វិទ្យុស្ថិតក្រោមកណ្តាប់ដៃរបស់សមមិត្តមកពីបក្សកុម្មុយនីស្តកម្ពុជា។ ពួកគេបានបន្តផ្តោតលើការផ្សះផ្សារសាមគ្គីភាពរវាងកងកម្លាំងស្នេហាជាតិទាំងអស់ ដែលមានសារៈសំខាន់បំផុត ប្រសិនបើស្ថានភាពនឹងវិលត្រឡប់ទៅរកភាពប្រក្រតីក្នុងអំឡុងពេលមួយឆ្នាំនេះ។ ទន្ទឹមនឹងនេះ កិច្ចខិតខំប្រឹងប្រែងនានាផ្តោតលើការរៀបចំឡើងវិញនូវបក្សជាបងប្អូន ពោលគឺការស្តារតួនាទីដឹកនាំឡើងវិញក្នុងរណសិរ្សរួបរួម។ សមមិត្ត Hoang Tung បានរៀបរាប់ ប៉ែន សុវណ្ណ ថាជាជនកុម្មុយនីស្តដ៏មានបទពិសោធន៍បំផុតដែលមានបទពិសោធន៍ក្នុងបក្សជាច្រើនឆ្នាំ។ យោងតាមព័ត៌មានរបស់យើង បច្ចុប្បន្ននេះ បក្ស (មិនច្បាស់) មានសមាជិកប្រមាណ ១.០០០ នាក់។ សមមិត្ត Hoang Tung បានបញ្ជាក់ថា មិនមានការពិចារណាពីការបង្កើតបក្សកុម្មុយនីស្តថ្មីរបស់កម្ពុជាឡើយ ប៉ុន្តែប្រពៃណីរបស់បក្សដែលកើតចេញពីបក្សកុម្មុយនីស្តឥណ្ឌូចិននៅតែបន្ត។

ដំណើរទស្សនកិច្ច ដែលបានប្រកាសជាផ្លូវការរបស់គណៈប្រតិភូ SRV ដែលដឹកនាំដោយសមមិត្ត Pham Van Dong ដែលត្រូវបានគ្រោងឡើងដំបូងសម្រាប់អំឡុងថ្ងៃទី ២៤ និង ២៥ ខែ មករា ត្រូវបានពន្យារពេលដោយសារស្ថានភាពបច្ចុប្បន្ន។ សមមិត្ត Hoang Tung បានអះអាងប្រាប់យើងថា គាត់នឹងឆ្លើយតបនឹងសំណើរបស់យើង ព្រមទាំងផ្តល់ដល់ពួកយើងនូវឯកសារសំខាន់ៗ (សន្ធិសញ្ញាស្តីពីមិត្តភាព និងកិច្ចសហប្រតិបត្តិការដោយមានខសន្យាជំនួយទៅវិញទៅមកដោយប្រយោល ដែលមានលក្ខណៈស្រដៀងគ្នានឹងសេចក្តី

ប្រកាសរួមរបស់ប្រទេសឡាវ) ដើម្បីឲ្យគេអាចយកទៅបោះពុម្ពផ្សាយក្នុងប្រទេសរបស់យើងក្នុងពេលជាមួយគ្នាដែលវាលេចឡើងក្នុងទំព័រកាសែតវៀតណាម។

<u>ក្រៅពីនេះ សមមិត្ត Hoang Tung បានកត់សម្គាល់ថា តាមរយៈជ័យជំនះក្នុងប្រទេសកម្ពុជា បច្ចុប្បន្ន ប្រជាជាតិទាំងបីក្នុងឥណ្ឌូចិនអាចចាប់ផ្តើមធ្វើអាជីវកម្មលើធនធានធម្មជាតិដ៏សម្បូរបែបក្នុងប្រទេសរបស់ខ្លួន។</u> គាត់បានផ្តោតចម្បងថា វិស័យកសិកម្មរបស់កម្ពុជាគឺជាវិស័យដ៏មានសក្តានុពលបំផុត បូករួមទាំងប្រេងឆៅ និងឧស្ម័នធម្មជាតិក្រោមដី។ ការណ៍នេះបង្ហាញថា ក្រៅពីបញ្ហាយោធារួម និងជាក់ស្តែងរបស់ប្រទេសទាំងបី សម្ព័ន្ធភាពសេដ្ឋកិច្ចជាក់ស្តែងក៏នឹងត្រូវបានបង្កើតឡើងផងដែរ។

សមមិត្តវៀតណាមសង្ឃឹមថា នឹងមានចំណុចវិវឌ្ឍបន្ថែមទៀតនៃស្ថានភាពក្នុងតំបន់ព្រំដែនភាគខាងជើង និងមិនបានច្រានចោលប្រតិបត្តិការយោធាទ្រង់ទ្រាយតូចដោយប្រទេសចិនប្រឆាំងនឹង SRV ឡើយ (ដូចជា កងទ័ពអាកាសរបស់ប្រទេសចិន)។ កំណើនភាពញឹកញាប់បច្ចុប្បន្ននៃសេចក្តីប្រកាសជាសាធារណៈ និងអនុស្សារណៈដោយក្រសួងការបរទេសរបស់ SRV ពាក់ព័ន្ធនឹងការបង្កហេតុតាមតំបន់ព្រំដែនដោយប្រទេសចិន បានជំរុញឲ្យស្ថានភាពនេះកាន់តែធ្ងន់ធ្ងរ។ ក្នុងបរិបទនេះសមមិត្ត Hoang Tung បានកត់សម្គាល់ថា សាវតាពិតនៃការបិទខ្សែផ្លូវដែកតភ្ជាប់ប្រទេសចិន និងវៀតណាមជាឯកតោភាគីដោយទីក្រុងប៉េកាំងធ្វើឡើងតាមរយៈយោធា និងសំដៅពង្រឹងការបង្កើនកម្លាំងទ័ពតាមព្រំដែនជាមួយប្រទេសវៀតណាម។ យោងតាមសមមិត្តនេះ ប្រទេសចិនត្រូវសម្រេចចិត្តរវាង "ការធ្វើទំនើបកម្ម" និងសង្គ្រាមជាមួយប្រទេសវៀតណាម ៖ តាមទស្សនៈរបស់គាត់ ការព្យាយាមសម្រេចគោលដៅទាំងពីរនេះគឺមិនអាចទៅរួចឡើយ។

[ហត្ថលេខា]/[ហត្ថលេខា]

Pflaum/Kapfenberger

[ទំព័រ 000024 ដល់ 000031 នៃភាសាអាល្លឺម៉ង់]

[ឈ្មោះសមមិត្ត ៣ នាក់ដែលសរសេរដោយដៃ និងមិនច្បាស់]
[កំណាត់សម្គាល់សរសេរដោយដៃដែលមិនច្បាស់លេខ 13/7]

# កង្វះអធិបតេយ្យភាពក្នុងតំបន់ឥណ្ឌូចិន

**Dennis Duncanson***

*ជម្លោះហិង្សារវាងប្រទេសកុម្មុយនីស្តកម្ពុជា និងវៀតណាមមានលក្ខណៈប្រហាក់ប្រហែលគ្នាច្រើនដូចនឹងជម្លោះរវាងចិន និងសូវៀត និងស្ថានភាពដែលធ្វើឱ្យមានការអនុវត្តលទ្ធិ Brezhnev ក្នុងប្រទេសឆេកូស្លូវ៉ាគី។*

នៅតែមានការរាយការណ៍ពីការប៉ះទង្គិចគ្នាផ្នែកយោធាពីតំបន់ដីសណ្តទន្លេមេគង្គចាប់តាំងពីជោគជ័យជាស្ថាពររបស់កងទ័ពកុម្មុយនីស្តក្នុងទីក្រុងភ្នំពេញ និងទីក្រុងសាយហ្គនកាលពីអំឡុងខែ មេសា ឆ្នាំ ១៩៧៥។ ដំបូងឡើយ ដោយមិនមានសេចក្តីរាយការណ៍ពីអ្នកសារព័ត៌មានបរទេស បន្ទាប់ពីពួកគេត្រូវបានជម្លៀសចេញពីតំបន់ ការប្រយុទ្ធអាចផ្តោតសំខាន់លើការបោសសម្អាតដោយកងកម្លាំងរំដោះលើអង្គភាពមិនចុះចាញ់នៃកងទ័ពដែលបរាជ័យ។ ប៉ុន្តែពាក្យចចាមអារ៉ាមនៃការប្រយុទ្ធគ្នារប៉េះរប៉ោះដែលបន្តកើតមាននៅអំឡុងឆ្នាំ ១៩៧៦ បានកើនកម្តៅនៅខែ កញ្ញា ឆ្នាំ ១៩៧៧ និងឈានដល់ចំណុចកំពូលនៅខែ ធ្នូ ក្នុងសេចក្តីរាយការណ៍ស្តីពីការចល័តកងពលធំជាច្រើនរបស់វៀតណាម និងកម្ពុជា ដែលរួមមានរថក្រោះ និងកាំភ្លើងធុនធ្ងន់ក្នុងការប្រយុទ្ធគ្នាទៅវិញទៅមក ទន្ទឹមគ្នានឹងការបោះសំដីផ្តេផ្តាគ្នាមិនចេះចប់។ ទោះបីជាកងទ័ពបច្ចាមិត្តទាំងសងខាងនៅតែបន្តប្រតិបត្តិការរបស់ខ្លួននៅអំឡុងចុងឆ្នាំនេះ បញ្ហានេះបានឈានដល់ចំណុចកំពូល និងមានការវាយលុកដោយកងទ័ពប្រជាជនវៀតណាម (PAVN) ចូលមកក្នុងទឹកដីកម្ពុជាដែលប្រៀបដូចជាការដាក់ទណ្ឌកម្ម ដោយប្រើប្រាស់កងពលធំចំនួន ៦ វាយប្រហារចូលជ្រៅប្រមាណ ៥០ ម៉ាយល៍។ យោងតាមការរៀបរាប់មួយ ដើម្បីការពារទល់នឹងការវាយប្រហារនេះ កម្ពុជាបានចល័តកងពលធំចំនួន ១៣ ក្នុងចំណោមកងពលធំ ១៧ ទៅកាន់តំបន់ព្រំដែន។ ទីក្រុងភ្នំពេញបានកាត់ផ្តាច់ចំណងទាក់ទងជាមួយទីក្រុងហាណូយ "ជាបណ្តោះអាសន្ន" និងបោះបង់

* លោក Duncanson គឺជាសាស្ត្រាចារ្យផ្នែកការសិក្សាអាស៊ីអាគ្នេយ៍នៅសាកលវិទ្យាល័យ Kent និងជាអ្នកនិពន្ធសៀវភៅ *រដ្ឋាភិបាល និងបដិវត្តន៍ក្នុងប្រទេសវៀតណាម* (ទីក្រុងឡុងដ៍ ៖ OUP សម្រាប់ RIIA ឆ្នាំ ១៩៦៨)។ អត្ថបទនេះត្រូវបានបោះពុម្ពដំណាលគ្នាជាភាសាអាល្លឺម៉ង់ក្នុង Europa-Archiv (Bonn) និងជាភាសាហូឡង់ក្នុង Internationale Spectator (The Hague)។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

[ទំព័រ 000024 ដល់ 000031 នៃភាសាអាល្លឺម៉ង់]

ចោលស្ថានទូតទីក្រុងម៉ូស្គូជាសម្ងាត់ ហាក់ដូចជាចង់គូសបញ្ជាក់ពីលក្ខណៈស្រដៀងគ្នានៃជម្លោះក្នុងតំបន់ឥណ្ឌូចិនជាមួយប្រទេសជិតខាង ទៅនឹងជម្លោះចិន និងសូវៀត។

គេអាចនឹងយល់ថា របបកុម្មុយនីស្តថ្មីទាំងពីរនេះផ្តោតសំខាន់លើភាពជាប្រទេសជិតខាងដែលមានទំនាក់ទំនងល្អនឹងគ្នា និងមានគំនិតតែមួយក្នុងការប្រើប្រាស់ធនធានរបស់ខ្លួនដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច។ ចាប់តាំងពីភាគីទាំងពីរបានរិតត្បិតព័ត៌មានជាសាធារណៈក្នុងការឃោសនា គេពិបាកនឹងស្វែងយល់ថាតើភាគីណាជាអ្នកឈ្លានពាន និងបុព្វហេតុពិតប្រាកដ។ សេចក្តីរាយការណ៍ដំបូងៗនៅខែ ឧសភា ឆ្នាំ ១៩៧៥ ដែលបញ្ជាក់ថា ពួកកុម្មុយនីស្តកម្ពុជា និងវៀតណាមសុទ្ធតែអស់ភាពអត់ធ្មត់ និងព្យាយាមគ្រប់គ្រងតំបន់ប្រជុំកោះតែមួយក្នុងឈូងសមុទ្រសៀម (ដើម្បីកាន់កាប់ធនធានប្រេង) ត្រូវបានបញ្ជាក់ក្នុងពេលថ្មីៗនេះដោយមន្ត្រីទីក្រុងហាណូយ ៖ គាត់បានអះអាងថា រដ្ឋាភិបាលរបស់គាត់បានព្យាយាមសម្រុះសម្រួលរបបទីក្រុងភ្នំពេញដោយ

ប្រគល់ឲ្យនូវ "ជនភៀសខ្លួនរាប់ពាន់នាក់" ដែលបានរត់ទៅជ្រកកោនក្នុងប្រទេសវៀតណាមនៅពេលបញ្ចប់សង្គ្រាម[១] ដើម្បីប្រឈមនឹងភាពព្រៃផ្សៃបំផុត[២]។ ប៉ុន្តែចំណុចនោះមិនទាន់អាចពន្យល់បានពីការវាយឆ្មក់ជាបន្តបន្ទាប់តាមព្រំដែនលើតំបន់ដីគោក ជនរងគ្រោះចម្បងៗដែលយ៉ាងហោចណាស់គឺខាងភាគីវៀតណាម រួមមានអ្នកភូមិដែលកំពុងលង់លក់ក្នុងដំណេករបស់ខ្លួននាពេលរាត្រី ឬអ្នកជម្លៀសចេញពីទីក្រុងហាណូយ ឬ Danang ក្នុង "តំបន់សេដ្ឋកិច្ចថ្មី" លើតំបន់ដីវាលជិតព្រំដែន[៣]។ ទោះបីជារយៈពេលជាច្រើនសតវត្សរ៍មកហើយ ដែលពួកកុម្មុយនីស្តមានគោលនយោបាយមិនអើពើចំពោះព្រំដែន ហើយភាគីទាំងពីរបានចោទប្រកាន់គ្នាទៅវិញទៅមកពីការទទួលយកផែនទីក្លែងបន្លំ ប៉ុន្តែភាពមិនប្រាកដប្រជាស្តីពីខ្សែបន្ទាត់ព្រំដែន មិនអាចត្រូវបានកំណត់ថាជាបុព្វហេតុមួយឡើយ ព្រោះថាការវាយប្រហារដ៏ឃោរឃៅភាគច្រើនបានធ្វើឡើងក្នុងតំបន់ទីប្រជុំជន ដូចជា Ha Tien និង Moc Hoa (វៀតណាម) ឬ អ្នកលឿង (កម្ពុជា) ដែលសុទ្ធតែមានទីតាំងច្បាស់លាស់ក្នុងផែនទីសូម្បីតែជនជាតិផ្សេងក៏អាចមើលឃើញច្បាស់ដែរ។ តាមពិត កម្ពុជាបានអះអាងថា ជម្លោះនេះមិនពាក់ព័ន្ធនឹងភាពមិនច្បាស់លាស់នៃខ្សែបន្ទាត់ព្រំដែន ឬការទាមទារឲ្យមានការកែតម្រូវឡើងវិញនោះទេ[៤]។

ថ្មីៗនេះ ការពិតបានចាប់ផ្តើមលេចឡើង និងដោយមានមូលដ្ឋានសម្រាប់ការសន្និដ្ឋានថា ភាគីកម្ពុជាបានចាប់ផ្តើមបាញ់ប្រហារដើម្បីបង្កភាពភ័យខ្លាចដល់កសិករវៀតណាមដោយប្រើប្រាស់អំពើហិង្សាបដិវត្តន៍តែមួយដែលពួកគេបានអនុវត្តចំពោះប្រជាជនកម្ពុជាទាំងមុនពេល និងចាប់តាំងពីពួកគេបានរំដោះប្រជាជនទាំងនោះ (ពលកម្មដោយបង្ខំ កង្វះស្បៀងអាហារ កង្វះឱសថព្យាបាល និងការសម្លាប់ចោលភ្លាមៗ)[៥]។ ភាគីកម្ពុជាបានចោទប្រកាន់ភាគីវៀតណាមថាមានគោលបំណងបង្កើតជាសហព័ន្ធឥណ្ឌូចិនឡើងវិញដូចក្នុងសម័យអាណានិគមបារាំង ដែលវៀតណាមបានចូលដៃជាមួយបារាំង និងនៅពេលដែលអគ្គលេខាធិការ ប៉ុល ពត និងសមមិត្តបក្សរបស់គាត់បានមូលមតិគ្នាដោយព្យាយាមបំផុសឲ្យមានរដ្ឋប្រហារផ្ទៃក្នុងប្រឆាំងនឹងរបបទីក្រុងភ្នំពេញ។ ពួកគេនិយាយថា ការវាយប្រហាររបស់វៀតណាមនៅអំឡុងខែ កញ្ញា និងធ្នូ គឺជាការអនុវត្តការផ្ទុះអាវុធនៅ

---

[១] វិទ្យុទីក្រុងហាណូយ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ១៩៧៨ (BBC, *សេចក្តីសង្ខេបព័ត៌មានពិភពលោក* ផ្នែកចុងបូព៌ា, ៥៧៨៩)

[២] Sau Dieu បាននិយាយនៅ Long Xuyen, *Far Eastern Economic Review*, ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៨។

[៣] ដូចខាងលើ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ១៩៧៨។

[៤] ប៉ុល ពត អគ្គលេខាធិការនៃបក្សកុម្មុនីស្តកម្ពុជា ផ្ញើជូនអ្នកសារព័ត៌មានយូហ្គោស្លាវី Tanjug ថ្ងៃទី២៤ ខែមេសា ឆ្នាំ ១៩៧៨ (SWB/FE/៥៨០១)។

[៥] វិទ្យុទីក្រុងហាណូយ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ១៩៧៨ (SWB/FE/៥៨១១)។

[ទំព័រ 000024 ដល់ 000031 នៃភាសាអាល្លឺម៉ង់]

ឥណ្ឌូចិនតាមលទ្ធិ Brezhnev នៃ "កង្វះអធិបតេយ្យភាព" ដែលអគ្គលេខាធិការ Le Duan និងសមមិត្តបក្សរបស់គាត់ មិនបានបង្កើតឡើងតាមរយៈការសមគំនិតគ្នាប្រកបដោយកលល្បិច[៦]។ ក្នុងយុទ្ធនាការឃោសនាប្រឆាំង និងសេចក្តីថ្លែងការណ៍ជាថ្មីស្តីពីប្រវត្តិពួកកុម្មុយនីស្តឥណ្ឌូចិន វៀតណាមបានចោទប្រកាន់ ប៉ុល ពត ថាមានផែនការវាយប្រហារកាន់កាប់ទីក្រុងសាយហ្គន និងតំបន់ដីសណ្តទន្លេមេគង្គ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់កម្ពុជាកាលពី ៣០០ ឆ្នាំមុន។ វៀតណាមបានបន្ថែមទៀតថា ទោះបីជាពួកគេចង់ឱ្យមានការបង្រួបបង្រួមប្រទេសក្នុងឥណ្ឌូចិនទាំងអស់ ប៉ុន្តែពួកគេបានបោះបង់គំនិតនេះតាំងពីឆ្នាំ ១៩៥១ មកម្ល៉េះ[៧]។ គេប្រហែលជាពិបាកនឹងកោតសរសើរ ប៉ុល ពត នូវការប្រកាន់ខ្ជាប់មហិច្ឆិតាដ៏អង់អាចដែលគាត់មានស្រាប់ ប៉ុន្តែគាត់ប្រាកដជាមានគោលបំណងមួយចំនួនក្នុង

[៦] វិទ្យុទីក្រុងភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ និងថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៧៨ (SWB/FE/៥៧១៥)។

[៧] ទីភ្នាក់ងារព័ត៌មានវៀតណាមថ្ងៃទី ៧ ខែ មេសា ឆ្នាំ ១៩៧៨ (SWB/FE/៥៧៨៥)។

Original DE: 00537030-00537080

Note: This Khmer translation is based on the English version which was translated from the original German text.

[ទំព័រ 000024 ដល់ 000031 នៃភាសាអាល្លឺម៉ង់]

ភាពគឃ្លើនជាបន្តបន្ទាប់ដែលគាត់បានអួតអាង[៨]។ ច្បាស់ណាស់ថា គាត់មិនអាចផ្តល់ឲ្យនូវលក្ខណៈសម្បត្តិដល់មិត្តភក្តិវៀតណាមដែល Le Duan និង Pham Van Dong ចាប់ពីថ្ងៃកើតមានសង្គ្រាម ធ្លាប់ផ្តល់ឲ្យគាត់ពីមុនមក រហូតដល់គាត់បានសងពួកគេវិញ[៩]។ ជាលទ្ធផល ការបំផ្លិចបំផ្លាញ ដែលបង្កឡើងជាបន្តបន្ទាប់លើលំនៅដ្ឋានរបស់ប្រជាជនតាមតំបន់ព្រំដែនក្នុងទឹកដីវៀតណាម ជាពិសេសនៅចំណុចដែលអតីតយោធិនមកពីរបបសាយហ្គនដែលបរាជ័យ កំពុងធ្វើប្រតិបត្តិការ[១០] ឬកំពុង "ប្រមូលផ្តុំ" ក្នុងជំរំដើម្បីការកៀរគរឡើងវិញតាមរយៈពលកម្ម[១១] គឺជាអ្វីល្អបំផុតដែល ប៉ុល ពត អាចធ្វើបាន ដើម្បីរាំងស្ទះកិច្ចខិតខំប្រឹងប្រែងរបស់ទីក្រុងហាណូយក្នុងការអនុវត្តកំណែទម្រង់របបសង្គមនិយមរបស់ខ្លួនតាមបណ្តាខេត្តថ្មីៗដែលខ្លួនវាយដណ្តើមកាន់កាប់ក្នុងដែនដីកូសាំងស៊ីន។

## សហព័ន្ធឥណ្ឌូចិន

គំនិតនៃការបង្កើតរដ្ឋតែមួយ ឬរដ្ឋសហព័ន្ធក្នុងតំបន់ឥណ្ឌូចិនមានអាយុកាលចាស់ជាងច្បាប់របស់បារាំងទៅទៀត។ កាលពី ៩០០ ឆ្នាំមុន នៅពេលដែលវៀតណាមមានទឹកដីត្រឹមតែជាតំបន់មួយប៉ុនទីក្រុងហាណូយ មេដឹកនាំវៀតណាមបានអះអាងពីការគ្រប់គ្រងបណ្តារដ្ឋក្នុងតំបន់ឥណ្ឌូចិនដោយយកគំរូតាមប្រទេសចិនដែលធ្លាប់ធ្វើលើប្រទេសជិតខាង ៖ វប្បធម៌មួយ ប៉ុន្តែមានពីររាជ្យវង្ស ខាងជើង និងខាងត្បូង។ នេះជាទ្រឹស្តីដែលវៀតណាមបានអនុវត្ត។ អធិរាជ្យវៀតណាមបានប៉ុនប៉ងជាច្រើនលើកច្រើនសាក្នុងការដាក់បញ្ចូលបណ្តាស្រុកនានារបស់ចិនដែលនៅជិតខ្លួន និងបានកំចាត់រាជាណាចក្រចម្ប៉ាយ៉ាងព្រៃផ្សៃ។ រដ្ឋឡាវត្រូវបានបង្កើតឡើង ដោយគំនិតផ្តួចផ្តើមរបស់កម្ពុជានៅអំឡុងឆ្នាំ ១៣០០ ប៉ុន្តែក្នុងរយៈពេល ៦០ ឆ្នាំ អ្នកគ្រប់គ្រងក្នុងទីក្រុងហាណូយបានទាមទារឲ្យព្រះអង្គម្ចាស់ឡាវ "ចូលរួមក្នុងទឹកដីរបស់ខ្លួន" ក្នុងនាមជា "ទឹកដីសម្គាល់" ដោយដៃទន្លេ (ling tu)។ ប្រទេសកម្ពុជាក្នុងមជ្ឈិមសម័យទទួលរងគ្រោះខ្លាំងពីវៀតណាមជាងប្រទេសឡាវទៅទៀត។ ក្រៅពីនេះ នៅពេលដែលការវាយកាន់កាប់ និងការតាំងទីលំនៅក្នុងរយៈពេលក្រោយៗមកនេះបានរីករាលដាលតាមទិសដៅរបស់ខ្លួន រដ្ឋរបស់ពួកគេបានបែងចែកជាពីរ៖ ភាគខាងជើង និងភាគខាងត្បូង។ ការបង្រួបបង្រួម

---

[៨] វិទ្យុទីក្រុងភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨ (SWB/FE/៥៨១៣)។

[៩] វិទ្យុទីក្រុងហាណូយ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨។

[១០] *Quan-doi Nhan Dan* (កងទ័ពប្រជាជន) ទីក្រុងហាណូយ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៧៨។

[១១] FEER ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៧៨។

វៀតណាមឡើងវិញនៅអំឡុងឆ្នាំ ១៨០០ គឺជាព្រឹត្តិការណ៍ដែលធ្វើឲ្យកម្ពុជាធ្លាក់ចូលក្នុងចំណាប់អារម្មណ៍វៀតណាម។ គេអាចមើលឃើញមូលហេតុដោយងាយស្រួល ៖ ក្នុងប្រទេសវៀតណាមដែលរួបរួមគ្នា ហើយប្រជាជនដ៏ច្រើនដែលស្ថិតនៅឆ្ងាយពីគ្នាក្នុងទីក្រុងហាណូយ និងទីក្រុងសាយហ្គន ត្រូវបានដាក់ឲ្យរស់នៅជាមួយគ្នាតាមបណ្ដោយទំនាបតំបន់ឆ្នេរដែលមានប្រជាជនរស់នៅតិច គេពិបាកនឹងការពារការបះបោរផ្ទៃក្នុងណាស់ ប្រសិនបើប្រជាជនទាំងនេះអាចស្វែងរកទីជម្រក ឬសម្ព័ន្ធមិត្តក្នុងប្រទេសនៅភាគខាងលិច។ ហេតុនេះវៀតណាម រិតតែចង់ឲ្យមានវិធានការមួយក្នុងការគ្រប់គ្រងបែបចក្រពត្តិលើប្រទេសឡាវ និងកម្ពុជា។

រដ្ឋាភិបាលចម្រុះនៃអាណានិគមបារាំងក្នុងតំបន់ឥណ្ឌូចិន បានសម្រេចជោគជ័យជាច្រើនក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងរដ្ឋបាលរវាងប្រទេសវៀតណាម ឡាវ និងកម្ពុជា ហើយពួកកុម្មុយនីស្តអន្តរជាតិបានចាត់ទុកសហព័ន្ធនេះថាជាប្រទេសមួយសម្រាប់ផែនការធ្វើបដិវត្តន៍។ នៅអំឡុងទសវត្សរ៍ឆ្នាំ ១៩០៨ ពួកជាតិនិយមវៀតណាមដែលព្យាយាមបញ្ចុះបញ្ចូលគ្រប់វិធីបានអះអាងដោយខ្លួនឯង និងរួមបញ្ចូលប្រទេសឡាវ និងកម្ពុជាទៅក្នុងទឹកដីវៀតណាម ហើយសិក្ខាកាមវៀតណាមមកពីសាកលវិទ្យាល័យ Communist University for Oriental Workers បានហៅបក្សរបស់ខ្លួនថា បក្សកុម្មុយនីស្តឥណ្ឌូចិននៅឆ្នាំ ១៩៣០ ទោះបីជាខ្លួនមិនសូវមានសមាជិកបក្សដែលជាជនជាតិឡាវ កម្ពុជា ឬមិនមែនជនជាតិវៀតណាមក្នុងការបង្កើត

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

របបកុម្មុយនីស្តទោលសម្រាប់តំបន់ឥណ្ឌូចិនទាំងមូលក៏ដោយ[១២]។ នៅឆ្នាំ ១៩៤៥ ហូជីមិញដែលទើបតែវិលត្រឡប់មកពីប្រទេសរុស្ស៊ី និងចិន មិនមានភ្នាក់ងារក្នុងប្រទេសកម្ពុជាឡើយ ប៉ុន្តែបានបង្ហាញខ្លួននៅចំពោះមុខ "សម្ព័ន្ធមិត្ត" អាមេរិកដែលធ្វើដំណើរទស្សនកិច្ចមកទីក្រុងហាណូយ ដើម្បីគាំទ្រជនកុម្មុយនីស្តដំបូងរបស់ឡាវគឺព្រះអង្គម្ចាស់ Souphanouvong[១៣]។ ព្រះអង្គបានផ្តល់ដល់ពួកកុម្មុយនីស្តនូវកងទ័ពរំដោះដែលមានសមាសធាតុជនជាតិវៀតណាមដែលស្លៀកពាក់ជាជនជាតិឡាវ[១៤] និងពួកកុលសម្ព័ន្ធភ្នំតុងកឹង[១៥] ដើម្បីប្រយុទ្ធឲ្យមានរដ្ឋកុម្មុយនីស្តរួមមួយក្នុងតំបន់ឥណ្ឌូចិន[១៦]។ នៅឆ្នាំ ១៩៥១ បន្ទាប់ពីរយៈពេលប៉ុន្មានឆ្នាំនៃការធ្វើពុត ត្រូវបានរំលាយចោល[១៧] បក្សកុម្មុយនីស្តឥណ្ឌូចិនបានប្រកាសក្នុងសមាជសន្និបាតលើកទីពីរ "ក្នុងព្រៃ" ថា បក្សនេះបានបង្កើតអត្ថិភាពខ្លួនឡើងវិញក្នុងបក្សពលករវៀតណាម (VWP) ហើយបក្សបដិវត្តន៍ផ្សេងៗគ្នារបស់កម្ពុជា និងឡាវ នឹងត្រូវបានបង្កើតឡើងក្រោមអំណាចរបស់បក្សនេះ។ បច្ចុប្បន្ន ទីក្រុងហាណូយបានគូសបញ្ជាក់ពីទំនាក់ទំនងឆ្នាំ ១៩៥១ ថាជាការបោះបង់ចុងក្រោយនៃគោលបំណងបង្កើតសហព័ន្ធឥណ្ឌូចិនរបស់ខ្លួន[១៨]។ គួរឲ្យសោកស្តាយ ការអះអាងនេះមិនទំនងជាការពិតនោះទេនៅពេលនោះសម្រាប់បក្សពលករវៀតណាម ដែលទើបតែបង្កើតឡើង និងអះអាងពីការបង្កើតរណសិរ្សជាតិរួមសម្រាប់កម្ពុជា និងឡាវ[១៩] ជាគោលបំណងដែលមាន

---

[១២] *រយៈពេល ៣០ ឆ្នាំនៃការតស៊ូរបស់បក្ស* (ទីក្រុងហាណូយ ៖ស្ថាប័នបោះពុម្ពផ្សាយជាភាសាបរទេស ឆ្នាំ ១៩៦០) ទំព័រ ៦៤។

[១៣] គណៈកម្មាធិការទំនាក់ទំនងបរទេសនៃព្រឹទ្ធសភាអាមេរិក *បុព្វហេតុ ប្រភពដើម និងមេរៀននៃសង្គ្រាមវៀតណាម* (រដ្ឋធានីវ៉ាស៊ីនតោន ៖ US SPO ឆ្នាំ ១៩៧៣) ទំព័រ ៣០៤-៥។

[១៤] អតីតសមមិត្ត Tran Van Dinh សរសេរក្នុង Adams និង McCoy, *ឡាវ ៖ សង្គ្រាម និងបដិវត្តន៍* (ទីក្រុងញូវយ៉ក ៖ Harper និង Row សម្រាប់គណៈកម្មាធិការបញ្ញវ័ន្តអាស៊ី ឆ្នាំ ១៩៧០) ទំព័រ ៤២៤។ ត្រូវបានបញ្ជាក់ក្នុង *Nhan Dan* (ប្រជាជន) (ទីក្រុងហាណូយ) ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៧០។

[១៥] C.Archaimbault, 'Annales de l ancien royaume de Sieng Khoung' *Bulleting de l Ecole Francaise d Extreme Orient (Hanoi)* LIII ទំព័រ ៦៦១។

[១៦] របាយការណ៍គណៈកម្មាធិការមជ្ឈិមក្នុង *Nghien-cuu Lich-su* (Historical Review) (ទីក្រុងហាណូយ) លេខ ១៤៦ ទំព័រ ៥។

[១៧] សូមមើលអ្នកឆ្លើយឆ្លងក្នុងកាសែត *The World Today* ចុះខែ សីហា ឆ្នាំ ១៩៧៥ ទំព័រ ៣៤៧-៨។

[១៨] វិទ្យុទីក្រុងហាណូយ ថ្ងៃទី ៧ ខែ មេសា ឆ្នាំ១៩៧៨ (SWB/FE/៥៧៨៥)។

[១៩] វិទ្យុសំឡេងវៀតណាម ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៥១ (SWB/FE/១០១)។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

បញ្ជាក់ក្នុងសេចក្តីថ្លែងការណ៍របស់បក្សពលករវៀតណាមថាគឺជា "សហព័ន្ធមួយដ៏ពិតប្រាកដ"[២០] យោងតាមការណែនាំសម្ងាត់របស់បក្ស ដែលតាមពិត "ស្ថិតក្រោមបក្សតែមួយ"[២១]។ គេអាចនឹងមើលឃើញច្បាស់ថា នៅពេលដែលហូជីមិញបានថ្លែងក្នុងសមាជនោះស្តីពី "ការសម្រេចបានសហព័ន្ធវៀតណាម ឡាវ និងកម្ពុជា"[២២] គាត់នៅតែស្រមៃថា គាត់នឹងក្លាយជាប្រមុខសហព័ន្ធមួយនៅថ្ងៃខាងមុខដែលស្រដៀងគ្នានឹងសាធារណរដ្ឋស្វយ័តរបស់សហព័ន្ធសាធារណរដ្ឋសង្គមនិយមសូវៀត ដែលគ្រប់គ្រងដោយបក្សតែមួយ។

ក្នុងការថ្លែងឡើងវិញជាប្រវត្តិសាស្រ្តរបស់ខ្លួននៅខែ មេសា វៀតណាមដែលបដិសេធមហិច្ឆិតារបស់ខ្លួនក្នុងការបង្កើតអំណាចសហព័ន្ធក្រោយឆ្នាំ ១៩៥១ និងការលេងឆាកល្ខោនជាការបដិសេធពីដំបូងជាច្រើនលើកច្រើនសា ពាក់ព័ន្ធនឹងការគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមក គូសបញ្ជាក់ពីការពឹងផ្អែកទាំងស្រុងលើការពង្រីកទ្រឹស្តីម៉ាក្ស-លេនីន ក្នុងតំបន់ឥណ្ឌូចិនចាប់តាំងពីអំឡុងឆ្នាំនៃកិច្ចខិតខំប្រឹងប្រែង*របស់ពួកគេ*។ ដើម្បីសម្រេចកិច្ចការនេះ ពួកគេបានធ្វើការអះអាងចាស់គំរិលថាបានបង្កើតកងកម្លាំងសេរីឡាវ និងកម្ពុជា (ដែលជាក្រុមឆ្នាំ ១៩៤៥

---

[២០] Liang Tien, *Yueh-nan Lao-chua ho Chien-pu-chai ti min-tsu chien-fang yun-tung* (ចលនារំដោះរបស់ ប្រជាជនវៀតណាម ឡាវ និងកម្ពុជា) (ទីក្រុងប៉េកាំង ឆ្នាំ ១៩៥១) ទំព័រ ៦៩។ កាសែត People's China សម្រាប់ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ១៩៥១ បានបន្ថែមពាក្យពេចន៍ "ប្រសិនប្រជាជនទាំងបីប្រទេសចង់បាន" ប៉ុន្តែមិនមានបដិញ្ញាដូច្នេះក្នុងឯកសារដើមជាភាសាចិនឡើយ។

[២១] USIS, ឯកសារ និងកំណត់សម្គាល់ស្រាវជ្រាវវៀតណាម (ទីក្រុងសាយហ្គន ឆ្នាំ ១៩៦៨) លេខ ៣៧ ផ្នែកទី ២ ទំព័រ ៦។

[២២] វិទ្យុសំឡេងវៀតណាម ថ្ងៃទី២៨ ខែ មីនា ឆ្នាំ ១៩៥១ (SWB/FE/១០២)។

[ទំព័រ 000024 ដល់ 000031 នៃភាសាអាល្លឺម៉ង់]

នៃ OSS/កងកម្លាំង ១៣៦ សេរីថៃ) ជារណសិរ្សសម្រាប់គោលបំណងបដិវត្តន៍របស់ខ្លួនមុនពេលជប៉ុនចូលរួមក្នុងសង្គ្រាម[២៣] និងដកស្រង់ការដឹងគុណជាសាធារណៈរបស់ប៉ុល ពត ឆ្នាំ ១៩៧៥ ចំពោះកងទ័ពប្រជាជនវៀតណាម ដែលបានជួយដល់កម្ពុជាយ៉ាងច្រើនបំផុតក្នុងការរំដោះប្រទេសដោយជោគជ័យ។ ក្នុងបទអត្ថាធិប្បាយនៃសេចក្តីថ្លែងការណ៍ផ្លូវការរបស់បក្ស លោក Hoang Tung និពន្ធនាយកនៃកាសែត Hanoi Daily (Nhan Dan-ប្រជាជន) បានប្រាប់អ្នកសារព័ត៌មានបរទេសថា ក្នុងរដ្ឋប្រហារទម្លាក់សីហនុនៅឆ្នាំ ១៩៧០ ដែលឈានទៅដល់ការរំដោះប្រទេសកម្ពុជា កងទ័ពប្រជាជនវៀតណាម "បានជ្រកកោនយ៉ាងច្រើន" ក្នុងតំបន់ព្រំដែនខាងកម្ពុជា ជាមូលហេតុដែលសហរដ្ឋអាមេរិកផ្តល់អន្តរាគមន៍ដែលមិនគួរឱ្យជឿ ហើយសម្រាប់សង្គ្រាមពីមុនៗក្នុងយុទ្ធនាការកម្ពុជាដែលចូលរួមប្រយុទ្ធដោយកងទ័ពកុម្មុយនីស្តវៀតណាម ដើមឡើយ ពួកខ្មែរក្រហមមានកងទ័ពប្រមាណតែ ១០០ នាក់ប៉ុណ្ណោះ និងបានទាមទារសុំជំនួយពីកងទ័ពវៀតណាមដើម្បីធ្វើការប្រយុទ្ធ និងការបណ្តុះបណ្តាលរហូតដល់ការផ្តួលរំលំរបបទីក្រុងភ្នំពេញ។ គ្រឿងសព្វាវុធដែលផ្គត់ផ្គង់ដោយប្រទេសចិនសម្រាប់យុទ្ធនាការនេះត្រូវដឹកជញ្ជូនដោយវៀតណាមដែល "ជួយដល់ការឃោសនា" និងសម្របសម្រួលជាសម្ងាត់រវាង ប៉ុល ពត រដ្ឋាភិបាលចិន និងសីហនុ[២៤]។ ក្នុងសង្គ្រាមឥណ្ឌូចិនជាលើកដំបូង គឺឧត្តមសេនីយ៍វៀតណាមដែលបានចុះហត្ថលេខាលើបទឈប់បាញ់នៅសន្និសីទក្រុងហ្សឺណែវឆ្នាំ ១៩៥៤ សម្រាប់កម្ពុជា វៀតណាម និងឡាវ ដោយសារតែកងកម្លាំងពួកកុម្មុយនីស្តដែលកំពុងធ្វើប្រតិបត្តិការក្នុងប្រទេសទាំងបីស្ថិតក្រោមបញ្ជារបស់ Vo Nguyen Giap។

ចំណុចសំខាន់នៃជម្លោះបច្ចុប្បន្នអាចបង្កការលំបាកមិនឈប់ឈរ៖ ដំបូងគឺកូមិនតឺន (Comintern) បន្ទាប់មកគឺទាយាទវៀតណាមរបស់ខ្លួន សុទ្ធតែបានជ្រើសរើសជនជាតិខ្មែរ។ រហូតដល់ចុងសង្គ្រាមលោកលើកទី ២ មេដឹកនាំវៀតណាមបានចាត់តាំងឱ្យប្រជាជនជនបទក្នុងប្រទេសឡាវ និងកម្ពុជាធ្វើជាអ្នកនាំពាក្យក្នុងរណសិរ្សរបស់ខ្លួនសម្រាប់ "ប្រជាជនជាបងប្អូន" ទាំងពីរ។ បញ្ញវន្តឡាវមួយក្រុមតូចត្រូវបានប្រមូលផ្តុំដោយហូជីមិញឱ្យស្ថិតនៅជុំវិញព្រះអង្គម្ចាស់ Souphanouvong មុនពេលបារាំងដកទ័ពចុងក្រោយចេញពីតំបន់ឥណ្ឌូចិននៅឆ្នាំ ១៩៥៥ ប៉ុន្តែពួកមេដឹកនាំនៅកម្ពុជាដែលហូជីមិញស្គាល់ នៅបន្តមានឈ្មោះជាភាសាចិន ឬ

---

[២៣] សេចក្តីថ្លែងការណ៍នេះប្រែសម្រួល Lao/Khmer Issara ថាជា "រណសិរ្សស្នេហាជាតិ" "ស្នេហាជាតិ" ដូចជា "សេរី" គឺជាការដាក់ការឃោសនាត្រឡប់វិញដោយសារកាលៈទេសៈនេះ។

[២៤] *Le Monde* ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៧៨ និង *FEER* ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៨។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

វៀតណាមថា (Yang Siu-heng, Son Ngoc Minh)[២៥] និងសមាជិកធម្មតាមួយ ឬពីរពាន់នាក់ទៀត ដែលរួមមានជនជាតិចាម ម៉ាឡេ និងជនជាតិភាគតិចកុលសម្ព័ន្ធភ្នំដែលរស់នៅសងខាងព្រំដែនវៀតណាម និងឡាវ[២៦]។ ភាពស្ថិតនៅឆ្ងាយរបស់ប្រទេសកម្ពុជាពីចំណុចកណ្តាលនៃអំណាចរបស់ពួកកុម្មុយនីស្តក្នុងតំបន់ឥណ្ឌូចិន បូករួមនឹងបញ្ហាទំនាក់ទំនងនៃចលនាសម្ងាត់ ប្រហែលជាបានរាំងស្ទះបន្ថែមទៀតលើការជ្រើសរើសដោយផ្ទាល់ ហើយធ្វើឱ្យហូជីមិញ និងសមមិត្តរបស់គាត់កោតសរសើរ "អ្នកជាតិនិយមគហបតី" របស់សម្តេចសីហនុ និងក្រុមបញ្ញវ័ន្តដែលបង្កើតជារដ្ឋាភិបាល "ព្រះពុទ្ធសាសនាសង្គមរាជានិយម" ក្នុងគោលបំណងបញ្ចូលពួកគេ

---

[២៥] ដូចជា *ព័ត៌មានវៀតណាម* (រ៉ង់ហ្គូន) ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ១៩៥១ និង W. Burchett, ទឹកទន្លេមេគង្គលើ (ទីក្រុងហាណូយ ៖ ស្ថាប័នបោះពុម្ពផ្សាយជាភាសាបរទេស ឆ្នាំ ១៩៥៧) ទំព័រ ១១៣។ Son Ngoc Minh ក៏បានបង្ហាញខ្លួនក្នុងសន្និសីទក្រុងហ្សឺណែវផងដែរ។

[២៦] M. Laurent, *l Armee au Cambodge* (ទីក្រុងប៉ារីស ៖ Armand Colin ឆ្នាំ ១៩៦៨) ទំព័រ ៤៥។

បន្តិចម្តងៗឱ្យសម្របតាមរបបទីក្រុងហាណូយ និង "សហព័ន្ធស្វយ័ត" នៅចុងបញ្ចប់។ ដូច្នេះ មេដឹកនាំកុម្មុយនីស្តបច្ចុប្បន្នក្នុងទីក្រុងភ្នំពេញ មិនបានទទួលពិធីទទួលស្គាល់ក្នុងចលនានេះពីកណ្តាប់ដៃដែលប្រគល់ការស្នងតំណែងពីកូមិនតឺនចាស់ ដូចគ្នានឹងពួកម៉ាក្សលេនីនផ្សេងទៀតដែលកាន់អំណាចនៅឥណ្ឌូចិនឡើយ ប៉ុន្តែហាក់ដូចជា "ពួកកុម្មុយនីស្តមនោគមវិជ្ជា" ដែលផ្លាស់ប្តូរដោយខ្លួនឯង ជាជាងដួលរលំ ខណៈដែលសិស្សនិសិត្សក្នុងប្រទេសបារាំងកាលពី ២០ ឆ្នាំមុន ដែលយល់ថាមានភាពងាយស្រួលក្នុងការចូលរួមក្នុងក្រុមនានាក្នុងប្រទេសក្រោមរបបដែលមានក្តីត្រាប្រណីរបស់សម្តេចសីហនុ ទន្ទឹមនឹងក្តីសុបិន្តថា ពួកគេនឹងបានឡើងកាន់អំណាច និងរង់ចាំឱកាសមកដល់[២៧]។ ប៉ុល ពត បានអះអាងថា គាត់បានបង្កើតបក្សកុម្មុយនីស្តកម្ពុជាបច្ចុប្បន្នដោយមិនដាក់ឈ្មោះតាមគេនៅឆ្នាំ ១៩៦០ និងបានគ្រប់គ្រងតំណែងជាអគ្គលេខាធិការក្នុងតំបន់ព្រំដែនដែលគ្រប់គ្រងដោយកងទ័ពប្រជាជនវៀតណាមដែលជួយផ្គត់ផ្គង់កងទ័ពដល់ផ្លូវលំហូជីមិញនៅឆ្នាំ ១៩៦៣ បន្ទាប់ពីការសម្លាប់បុព្វការីរបស់គាត់ក្នុងពេលបោសសម្អាត[២៨]។ យើងអាចជឿជាក់បានថា បក្សរបស់គាត់មិនមែនជាបក្សប្រជាជន ដែលបង្កើតឡើងដោយបក្សកុម្មុយនីស្តឥណ្ឌូចិន/បក្សពលករវៀតណាមនៅឆ្នាំ ១៩៥១ ឡើយ និងត្រូវបានជេរប្រមាថដោយសម្តេចសីហនុនៅពេលទ្រង់នៅកាន់អំណាច ព្រោះថាបក្សកុម្មុយនីស្តឥណ្ឌូចិន/បក្សពលករវៀតណាមគឺជាបក្សផ្សេងគ្នា ប៉ុន្តែគឺជា "អង្គការ" ដែលជាប្រភពសម្ងាត់នៃលំហូរអំណាចទាំងអស់បន្ទាប់ពីផ្តួលរំលំរបបទីក្រុងភ្នំពេញ និងរហូតដល់ខែ កញ្ញា ឆ្នាំ១៩៧៧[២៩]។

## វៀតណាម និងលទ្ធិ Brezhnev

ទោះបីជាគេពិបាកបង្ហាញព័ត៌មានពិតក៏ដោយ ក៏តំណែងរបស់ ប៉ុល ពត ហាក់ដូចជាត្រូវបានផ្តល់ឱ្យដោយ Le Duan ប៉ុន្តែបានបដិសេធចោលនូវសន្និសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការដោយមានលក្ខខណ្ឌដែលឡាវបានចូលរួមនៅខែ កក្កដា ឆ្នាំ ១៩៧៧ ៖ "ការគោរពយ៉ាងតឹងរ៉ឹងចំពោះអធិបតេយ្យភាពជាតិ" ប៉ុន្តែផ្តល់លទ្ធភាពក្នុងការប្រើប្រាស់ទឹកដីរបស់រដ្ឋតូចមួយសម្រាប់សមយុទ្ធកងទ័ពរបស់រដ្ឋធំជាង និងការរួមបញ្ចូល

---

[២៧] F. Debre, *Cambodge, revolution de la foret* (ទីក្រុងប៉ារីស ៖ Flammarion ឆ្នាំ ១៩៧៦) ទំព័រ ៧៧-៩៥។ លើកលែងដែលព័ត៌មានលម្អិតមួយចំនួនតូច ការពន្យល់នេះផ្តល់ដោយរឿងរ៉ាវរបស់ ប៉ុល ពត ចំពោះប្រព័ន្ធផ្សព្វផ្សាយរបស់គាត់នៅទីក្រុងភ្នំពេញកាលពីថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ (SWB/FE/៥៧៧២)។

[២៨] សេចក្តីថ្លែងការណ៍ស្តីពីការធ្វើទស្សនកិច្ចរបស់អ្នកសារព័ត៌មានយូហ្គោស្លាវី Tanjug ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៨។

[២៩] "អង្គការ" ក៏ជារហស្សនាមរបស់បក្សកុម្មុយនីស្តឥណ្ឌូចិនដែរចាប់ពីឆ្នាំ ១៩៤៥ រហូតដល់ឆ្នាំ ១៩៥១។ បក្សកុម្មុយនីស្តកម្ពុជាត្រូវបានហៅឈ្មោះដំបូងដោយវិទ្យុទីក្រុងភ្នំពេញនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៧ (SWB/FE/៥៦២៤)។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

[ទំព័រ 000024 ដល់ 000031 នៃភាសាអាល្លឺម៉ង់]

បទបញ្ញាជាន់ខ្ពស់ពីរស្តីពីមាត្រាកតិកាសញ្ញាវ៉ាសូវី (The Warsaw Pact)[៣០] ដោយផ្អែកតាមការវិនិច្ឆ័យលើការលើកសរសើរហួសហេតុពីសាមគ្គីភាពកងទ័ព។ ឥទ្ធិពលជាក់ស្តែងនៃសន្ធិសញ្ញាឡាវឆ្នាំ ១៩៧៧ រួមមានការដាក់កងទ័ពប្រជាជនឲ្យប្រចាំការនៅតំបន់ទំនាប Jars ភាគខាងកើតប្រទេសឡាវ ជាការគ្រប់គ្រងទឹកដីដែលស្ទើរតែបន្តក្នុងរយៈពេល ២៥ ឆ្នាំ ដែលគេរាយការណ៍ថា មានកងទ័ពមិនតិចជាង ១០០.០០០ នាក់ ក្រៅពីកសិករវៀតណាមដែលចូលមកតាំងទីលំនៅថ្មីប្រមាណ ៥០.០០០ នាក់[៣១]។ បច្ចុប្បន្ននេះ មិនមានការគំរាមកំហែងផ្ទៃក្នុងចំពោះប្រទេសឡាវទេ និងរិតតែមានការគំរាមកំហែងផ្ទៃក្នុងតិចតួចសម្រាប់ប្រទេសវៀតណាមដោយប្រទេសឡាវ។ ដូច្នេះ យោងតាមភាពចាំបាច់នៃសន្តិសុខផ្ទៃក្នុងរួម យើងត្រូវសន្និដ្ឋានថាសន្ធិសញ្ញានោះត្រូវបានសំអាងដោយវត្តមានរបស់ហត្ថលេខីពីររូប។ ទោះបីជាជនជាតិឡាវរាប់រយពាន់នាក់បានគេចខ្លួនទៅបរទេសចេញពីរបបកុម្មុយនីស្ត និងមានប្រជាជនប្រមាណ ២០០.០០០ នាក់ត្រូវបានឃុំខ្លួន

[៣០] ទោះបីជាបានចុះហត្ថលេខានៅទីក្រុងវៀងច័ន្ទនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ១៩៧៧ និងផ្តល់សច្ចាប័នដោយសាធារណរដ្ឋសង្គមនិយមវៀតណាមនៅថ្ងៃទី ១៥ ខែ កញ្ញា ប៉ុន្តែអត្ថបទនោះមិនត្រូវបានបោះពុម្ពផ្សាយដល់សាធារណជនឡើយ។

[៣១] តួលេខក្នុងផ្នែកនេះ និងក្នុងប្រយោគជាបន្តបន្ទាប់ត្រូវបានដកស្រង់ចេញពី *Le Figaro* ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៨។

Original DE: 00537030-00537080

Note: This Khmer translation is based on the English version which was translated from the original German text.

[ទំព័រ 000024 ដល់ 000031 នៃភាសាអាល្លឺម៉ង់]

ប៉ុន្តែការប្រឆាំងក្នុងពេលចុះហត្ថលេខាសន្ធិសញ្ញានេះ នៅតែតម្រូវឲ្យមានការការពារតឹងរ៉ឹងនៅតាមអគារ និងការដ្ឋានការងារ ខណៈដែលកងទ័ពប្រចាំការក្នុងផ្ទៃប្រទេសមិនអាចទុកចិត្តបានថាមិនចូលទៅក្នុងកិច្ចព្រមព្រៀងមិនឈ្លានពានជាលក្ខណៈឯកជនជាមួយអ្នកប្រឆាំង[៣២]។ ការចុះសន្ធិសញ្ញាជាច្រើនរវាងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម រួមបញ្ចូលចំណុចមួយស្តីពីការអភិវឌ្ឍ និងជំនួយ។ សាធារណរដ្ឋសង្គមនិយមវៀតណាមគ្រប់គ្រងការធ្វើអាជីវកម្មរ៉ែនៅឆ្នាំ ១៩៧៥ និងចំណុច ១ ភាគ ៣ ស្តីពីការគោរពព្រំដែនគ្នាទៅវិញទៅមក។ សន្ធិសញ្ញាទាំងនេះមិនត្រូវបានចុះផ្សាយឡើយ ប៉ុន្តែនៅពេលមិនមានអត្ថបទ គេមានហេតុផលក្នុងការរំពឹងទុកថា យោងតាមករណីយុត្តិសាស្ត្រ Comecon ផ្ទុះបញ្ចាំងពីតថភាពនៃការគ្រប់គ្រងរបស់វៀតណាម និងការពឹងផ្អែករបស់ឡាវ យ៉ាងហោចណាស់លើការផ្គត់ផ្គង់ស្បៀងអាហារមូលដ្ឋាន[៣៣] និងផ្តល់ប្រយោជន៍ដល់ Kaysone Phomvihan ដែលជាអគ្គលេខាធិការបក្ស និងជានាយករដ្ឋមន្ត្រី តាមរយៈការការពារដោយកងទ័ពប្រចាំការជាបងប្អូន។ ផ្ទុយទៅវិញ អត្តសញ្ញាណរបស់ប្រទេសឡាវ ក្នុងនាមជារដ្ឋបំបែកខ្លួន បានផ្តល់សំឡេងបន្ថែមដល់ឥណ្ទាចិនក្នុងកិច្ចការពិភពលោក (ជាឧទាហរណ៍ SRV ត្រូវបានទទួលស្គាល់ក្នុងអង្គការសហប្រជាជាតិ ចំណែក Kaysone គ្រប់គ្រងអាសនៈរាជវង្សឡាវនៅឆ្នាំ ១៩៧៣) និងបណ្តាញទីពីរសម្រាប់លទ្ធកម្មជំនួយ និងស្បៀងអាហារពីបស្ចិមប្រទេស។ វាជាបញ្ហានៃការសន្និដ្ឋានថាតើវៀតណាមទំនងជាស្វែងរកឱកាសអនុវត្តលទ្ធិ Brezhnev ក្នុងប្រទេសឡាវដែរឬទេ។ នោះគឺ “ប្រសិនបើមានការគំរាមកំហែងដល់ការស្តាររបបមូលធននិយមឡើងវិញ” ប៉ុន្តែនៅពេលគេរំលឹកឡើងវិញពីគោលនយោបាយចម្រុះដែលទំនងជាប៉ះពាល់ដោយពាក្យពេចន៍ទាំងនោះក្នុងប្រទេសចិនក្នុងអំឡុងបដិវត្តន៍វប្បធម៌ ប៉ុល ពត ប្រហែលជាបានវិនិច្ឆ័យថា ការប្រឈមមុខដោយឃោរឃៅមានសុវត្ថិភាពសម្រាប់របបរបស់គាត់ ជាជាងកិច្ចសហប្រតិបត្តិការជាបងប្អូនដោយយកគំរូតាមប្រទេសឡាវ។

មិនថាសន្ធិសញ្ញាព្រំដែនប្រទេសឡាវ ពាក់ព័ន្ធនឹងការកែតម្រូវទៅតាមផលប្រយោជន៍របស់វៀតណាមដែលទាមទារជាយូរមកហើយ មិនអាចបញ្ជាក់អះអាងបាន ឬយ៉ាងណានោះទេ ប៉ុន្តែ ប៉ុល ពត ប្រហែលជាបានដឹងចំណុចនេះ។ គាត់ប្រហែលជាដឹងពីលក្ខខណ្ឌដែលស្រដៀងគ្នានឹងសម្បទានរបស់ប្រទេសឆេកូស្លូវ៉ាគីចំពោះសហព័ន្ធសាធារណរដ្ឋសង្គមនិយមសូវៀត និងការយល់ដឹងរបស់គាត់ នៅពេលគាត់បដិសេធសំណើរបស់

---

[៣២] Siang Pasason (សំឡេងប្រជាជន) ដកស្រង់វិទ្យុទីក្រុងវៀងច័ន្ទ នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៧ (SWB/FE/៥៥៩៣)។

[៣៣] មានការរំពឹងទុកថា ៦០% នៃឱនភាពស្រូវ ១០០.០០០ តោននឹងត្រូវបានផ្គត់ផ្គង់ដោយបស្ចិមប្រទេសតាមរយៈកម្មវិធីស្បៀងអាហារពិភពលោក (មិនមែនផ្តល់ដោយអំណាចពួកកុម្មុយនីស្ត) ៖ *FEER* ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ១៩៧៨។

SRV ក្នុងការចរចាសន្ធិសញ្ញាព្រំដែនជាមួយប្រទេសកម្ពុជា ព្រោះគាត់បានពន្យល់ពីភាពមានះរបស់គាត់ បន្ទាប់ពីកិច្ចចរចាដំបូងក្នុងអំឡុងឆ្នាំ ១៩៧៥ និង ១៩៧៦ តាមរយៈការមិនទុកចិត្តចំពោះសម្ព័ន្ធមិត្តវៀតណាមដែលជួយឲ្យគាត់បានឡើងកាន់អំណាច។ ពួកគេបានចោទប្រកាន់គាត់ថាបានបំបែកចេញដោយឡែកសម្រាប់ការជម្រះបញ្ជីពួកខ្មែរក្រហមដែលបានខិតខំប្រឹងប្រែងជួយដល់គាត់[៣៤]។ កត្តាជាច្រើនបានធ្វើឲ្យគាត់រក្សាគោលជំហរនៃជ័យជំនះដោយឯករាជ្យ ទោះបីជាមានការពឹងផ្អែកលើការតស៊ូក៏ដោយ។ កត្តាមួយក្នុងចំណោមកត្តាទាំងនោះគឺកាតព្វកិច្ចរបស់ Le Duan ក្រោមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសសម្រាប់វៀតណាម ប្រសិនបើមតិសាធារណៈរបស់អាមេរិក មិនត្រូវបានគិតគូរឡើងវិញ ដើម្បីដកអង្គភាពទ័ពប្រយុទ្ធ PAVN ចេញពីប្រទេសឡាវ និងកម្ពុជានៅអំឡុងឆ្នាំ ១៩៧៣។ ដោយសារតែមិនមានកម្មាភិបាលពួកកុម្មុយនីស្តកម្ពុជាណាអាចគ្រប់គ្រងតំបន់ដណ្តើមបានជាបន្តបន្ទាប់នៅកម្ពុជា និងបរាជ័យរបស់ទីក្រុងហាណូយក្នុងការទទួលបានការទទួលស្គាល់រួមជាអន្តរជាតិចំពោះរដ្ឋាភិបាលនិរទេសខ្លួនក្នុងទីក្រុងប៉េកាំងរបស់សីហនុ

---

[៣៤] វិទ្យុទីក្រុងហាណូយ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៧៨ (SWB/FE/៥៨១១)។

[ទំព័រ 000024 ដល់ 000031 នៃភាសាអាល្លឺម៉ង់]

ដែលផ្ទេរអំណាចរាជានិយមទៅឲ្យពួកកុម្មុយនីស្តតាមរយៈព្រះអង្គដោយមន្រ្តីរាជការក្រោមរបប លន់ នល់[៣៥] ប៉ុល ពត ដែលពឹងផ្អែកលើយុវជនកំណាចឃោរឃៅយ៉ាងច្រើនរបស់ខ្លួន[៣៦] គឺជាមនុស្សតែម្នាក់ដែលនៅសេសសល់ និងជាអ្នកគ្រប់គ្រងប្រទេសតែមួយគត់។

## តុល្យភាពអំណាចរបស់ពួកកុម្មុយនីស្ត

គោលនយោបាយការបរទេសរបស់ ប៉ុល ពត ហាក់មានលក្ខណៈអវិជ្ជមានដូចគ្នានឹងគោលនយោបាយក្នុងប្រទេសរបស់គាត់ក្នុងការប្រកាន់អំណាចផ្ដាច់ការអធន និងរបបប្រជាធិបតេយ្យប្រមូលផ្ដុំ និងមានលក្ខណៈជាអ្នកមូលដ្ឋាននិយមជាងរដ្ឋបាលម៉ៅសេទុង (គ្មានរដ្ឋបាលសាធារណៈ គ្មានសេវាសាធារណៈ[៣៧] គ្មានសាច់ប្រាក់ គ្មានការចម្អិនអាហារគ្រួសារ)៖ គាត់បានដកស្រង់ការបោះបង់ជាក់លាក់មួយនៃសហព័ន្ធឥណ្ឌូចិនពីសាធារណរដ្ឋសង្គមនិយមវៀតណាម ទោះបីជាមិនមែនជាការលះបង់លទ្ធិ Brezhnev[៣៨] ប៉ុន្តែមិនបានស្នើសុំប្រព័ន្ធទំនាក់ទំនងជាជម្រើសឡើយ។ អំណាចពួកកុម្មុយនីស្តផ្សេងទៀត បង្ហាញពីការមិនយល់ស្របចំពោះការប្រយុទ្ធតាមព្រំដែន ទោះបីជាមានតែភាគីវៀតណាមប៉ុណ្ណោះ ដែលបានថ្កោលទោសការសម្លាប់ប្រជាជនក្នុងមូលដ្ឋាន ដើម្បីបន្ថែមលក្ខណៈសម្បត្តិដល់ការរិះគន់របស់ពួកគេស្ដីពីភាពឃោរឃៅតាមព្រំដែន ខណៈដែលរុស្ស៊ីបានទាត់ចោលចំណុចនេះថា មិនពិត[៣៩]។ ទោះបីជាមានការបដិសេធ ប៉ុន្តែ រុស្ស៊ី និងចិន ហាក់ប៉ុនប៉ងផ្សះផ្សារ ហើយនៅពេលថ្មីៗនេះ រដ្ឋមន្រ្តីការបរទេសយូហ្គោស្លាវី M. Minic បានព្យាយាមក្នុងស្លាក "មិនចូលបក្ស

---

[៣៥] សូមមើល Dennis J. Duncanson "រយៈពេលមួយឆ្នាំនៃសន្តិភាពក្នុងតំបន់ឥណ្ឌូចិន" កាសែត *The World Today* ខែ មីនា ឆ្នាំ ១៩៧៤ ទំព័រ ៩៨។

[៣៦] គាត់បានអួតអាងថា ពួកគេបានកើនឡើងចំនួន ៤ ដងក្នុងរយៈពេល ៤ ខែ មិនមានការដាក់បញ្ហាស្មុគស្មាញ និងដឹកនាំដោយ "កម្មាភិបាល" (ប្រហែលជាមន្រ្តី) ដែលអាចឡើងកាន់តំណែងបន្ទាប់ពីការលត់ដំនៅវាលស្រែរយៈពេល ១ ខែ ៖ រយៈពេល ២ ខែ ប្រសិនបើពួកគេត្រូវដឹកនាំកងពលធំ ៖ វិទ្យុទីក្រុងភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨ (SWB/FE/៥៨១៣)។

[៣៧] កុមារជីក និងរែកដីនៅពេលយប់ ប៉ុន្តែមិនបានសិក្សាទេ ៖ ខៀវ សំផន ត្រូវបានដកស្រង់សំដីក្នុងកាសែត *The Time* ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៨។ "វេជ្ជបណ្ឌិត" រៀនសូត្រពីការអនុវត្តព្យាបាលអ្នកជំងឺ ៖ ប៉ុល ពត ក្នុងវិទ្យុទីក្រុងភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៧៧ (SWB/FE/៥៦៣២)។

[៣៨] វិទ្យុទីក្រុងហាណូយ ថ្ងៃទី ៧ ខែ មេសា ឆ្នាំ ១៩៧៨ (SWB/FE/៥៧៨៥)។

[៣៩] នេះជាបញ្ហាឲ្យដកគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិចេញពីតំបន់ឥណ្ឌូចិន។ សូមមើលកាសែត *The Times* ថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៧៨។

សម្ព័ន្ធ"[៦០] ប៉ុន្តែប្រែជាអសារបង់។ ខណៈដែលប្រទេសមហាអំណាចទាំងពីរផ្តោតលើកម្មវិធីជំនួយរបស់ខ្លួន សហព័ន្ធសាធារណរដ្ឋសង្គមនិយមសូវៀតដែលគាំទ្រវៀតណាម និងឡាវ និងសាធារណរដ្ឋប្រជាមានិតចិន ដែលគាំទ្រកម្ពុជា (ទោះបីជាគម្រោងធ្វើសង្គ្រាមមិនពេញលេញរបស់ចិនក្នុងប្រទេសឡាវ និងវៀតណាម[៦១] នៅបន្តក៏ដោយ) គេមានមូលហេតុដើម្បីដាក់ការសង្ស័យថា មេដឹកនាំចិនចង់ឲ្យមានភាពតានតឹងរវាងវៀតណាម និងកម្ពុជា និងមានចំណងមិត្តភាពរវាងកម្ពុជា និងថៃ ដើម្បីបង្កើនអនុភាពសង្គ្រាមរបស់វៀតណាម ដែលថ្មីនេះបានផ្ទុះឡើងតាមបណ្តោយព្រំដែនចិន[៦២]។ ទោះជាយ៉ាងនេះក្តី សម្រាប់ SRV ប្រហែលជាមិនមានការបញ្ចប់ការវាយឆ្មក់តាមព្រំដែនឡើយ ប្រសិនបើមិនមានការដោះស្រាយបញ្ហាកម្ពុជា។ នៅពេលតំបន់ពាក់កណ្តាលចំនួនពីរដងទៀតរបស់វៀតណាមត្រូវបានបែងចែក វៀតណាមមិនមានភាពចាំបាច់ ឬត្រូវចំណាយធនធានដើម្បីគ្រប់គ្រងប្រទេសឡាវ និងកម្ពុជាឡើយ ប៉ុន្តែភូមិសាស្ត្របានធ្វើឲ្យមានការផ្លាស់ប្តូរមនោគមវិជ្ជា និងដើរតាមគន្លងចាស់នៃព្រឹត្តិការណ៍សំខាន់ៗក្នុងប្រវត្តិសាស្ត្រ៖ ក្នុងប្រទេសវៀតណាមដែលបានរួបរួមមួយ ការគ្រប់គ្រងដោយទីក្រុងហាណូយលើទីក្រុងសាយហ្គន និងតំបន់ដីសណ្តទន្លេមេគង្គ មិនអាចធានាបានឡើយប្រសិនបើកម្ពុជានៅតែបង្កទំនាស់នឹងវៀតណាម ចំណែកបក្សពលករវៀតណាម ក៏មិនអាចបំពេញបេសកកម្មដែលខ្លួនបានប្រកាសដើម្បីពន្លឿនបដិវត្តន៍បន្តទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍បានដែរ[៦៣] និងតាមរយៈវិធានការដែលប្រឆាំងនឹងប្រទេសថៃបែបនេះ បក្សនេះនៅទីបំផុត ក៏មិនអាចបដិសេធទឹកដីមួយផ្នែកទៀតនោះជាមួយអ្នកប្រឆាំងឡាវដែរ[៦៤]។

[៦០] Tanjug ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៨ (SWB/FE/៥៨០៣)។

[៦១] ចិនបានប្រកាសថា ពួកគេបានដកទីប្រឹក្សាជំនាញការទាំងអស់របស់ខ្លួនចេញពីប្រទេសវៀតណាមនៅថ្ងៃទី ១៩ ខែ ឧសភា។

[៦២] ផ្ទុយទៅវិញ រយៈពេល ១៥ ឆ្នាំមកហើយ ដែល Chou En-lai បានប្រាប់ឯកអគ្គរដ្ឋទូតប៉ូឡូញ Mieczyslaw Maneli ថា គាត់ចាត់ទុកគោលបំណងនៃកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវថាជាការបង្រួបបង្រួមប្រទេសទាំងបី។ សូមមើល Maneli *សង្គ្រាមយកឈ្នះ* (ទីក្រុងញូវយ៉ក ៖ Harper និង Row ឆ្នាំ ១៩៧១) ទំព័រ ៨០។

[៦៣] សេចក្តីថ្លែងការណ៍រួមរវាងប្រទេសឡាវ និងវៀតណាម ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។

[៦៤] Kaysone Phomvihan វិទ្យុទីក្រុងវៀងច័ន្ទ ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩៧៨ (SWB/FE/៥៧៦៥)។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

[កំណត់សម្គាល់សរសេរដៃមិនច្បាស់]

ការបកប្រែក្រៅផ្លូវការ

## សេចក្ដីប្រកាស

### របស់រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្ដីពីទំនាក់ទំនងរវាងប្រទេសវៀតណាម និងកម្ពុជា

---

នៅក្នុងសេចក្ដីប្រកាសរបស់ខ្លួននៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានស្នើឱ្យភាគីទាំងពីរ គឺវៀតណាម និងកម្ពុជា ជួបគ្នាភ្លាមៗ ដោយមិនគិតពីកម្រិតថ្នាក់ ដើម្បីឱ្យប្រទេសទាំងពីរ អាចដោះស្រាយបញ្ហាព្រំដែនជាមួយគ្នាបាននៅក្នុងស្មារតីមិត្តភាពភាតរភាព។ សំណើនេះត្រូវបានឆ្លើយតបជាមួយសមានចិត្ត និងការគាំទ្រពីសំណាក់រដ្ឋាភិបាលនានា និងប្រជាជនរបស់ប្រទេសដែលស្រលាញ់សន្តិភាព និងយុត្តិធម៌ ព្រមទាំងពីមតិសាធារណៈអន្តរជាតិជាទូទៅ។ ប្រជាជនវៀតណាម និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដឹងគុណដល់បងប្អូន និងមិត្តរបស់ខ្លួននៅទូទាំងពិភពលោកសម្រាប់ក្ដីអាណិតអាសូរ និងការគាំទ្រនេះ។

ប្រការដែលគួរឱ្យសោកស្ដាយបំផុតនោះគឺថា រហូតមកដល់ពេលបច្ចុប្បន្ននេះ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានច្រានចោលយ៉ាងដាច់ខាតនូវសំណើសុំចរចារបស់រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ផ្ទុយទៅវិញ ភាគីកម្ពុជា បន្តដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធរបស់ខ្លួននៅតាមបណ្ដោយព្រំដែនទាំងមូល ជាពិសេសនៅក្នុងខេត្ត Kien Giang ខេត្ត An Giang និងខេត្ត Tay Ninh ដើម្បីវាយប្រហារទីក្រុងមួយចំនួននៅក្នុងដែនដីរបស់វៀតណាម ដោយបន្តអនុវត្តសកម្មភាពឃោរឃៅប្រឆាំងនឹងប្រជាជនវៀតណាម។ កម្ពុជាកំពុងប្រើប្រាស់គ្រប់មធ្យោបាយដែលខ្លួនមាន ដើម្បីចូលរួមក្នុងយុទ្ធនាការបង្ខូចកេរ្តិ៍ឈ្មោះ ដើម្បីបំផុសឱ្យមានការស្អប់ខ្ពើមជាលក្ខណៈជាតិប្រឆាំងនឹងវៀតណាម ក្នុងគោលបំណងចោទប្រកាន់សាធារណរដ្ឋសង្គមនិយមវៀតណាមក្នុងលក្ខណៈមួលបង្កាច់ថា វៀតណាមឈ្លានពាន

កម្ពុជា ជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន និងប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាលរបស់ខ្លួន ដោយអះអាងថា សាធារណរដ្ឋសង្គមនិយមវៀតណាមកំពុងបង្ខំឲ្យកម្ពុជាចូលរួមក្នុង “សហព័ន្ធឥណ្ឌូចិន” ដែលស្ថិតក្រោមអនុត្តរភាពរបស់វៀតណាម...រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម សូមច្រានចោលយ៉ាងដាច់ខាតនូវការអះអាងបែបមួលបង្កាច់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនេះ។ ច្បាស់ណាស់ថា រដ្ឋាភិបាលកម្ពុជា កំពុងមានចេតនាធ្វើឲ្យភាពតានតឹងទាក់ទងនឹងបញ្ហាព្រំដែនរវាងវៀតណាម និងកម្ពុជាកាន់តែកើនឡើង កំពុងធ្វើឲ្យទំនាក់ទំនងរវាងវៀតណាម និងកម្ពុជាកាន់តែធ្ងន់ធ្ងរ និងកំពុងកាន់តែធ្វើឲ្យមានភាពច្របូកច្របល់ និងរារាំងមិនឲ្យមានដំណោះស្រាយបញ្ហារវាងប្រទេសទាំងពីរ។

ដោយហេតុនេះ រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងប្រជាជនវៀតណាម បន្តជាថ្មីនូវតួនាទីជាគោលការណ៍មិនប្រែប្រួលរបស់ខ្លួន ដែលមានការការពារយ៉ាងមោះមុតនូវឯករាជ្យភាព សេរីភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់វៀតណាម ព្រមទាំងគោរពឯករាជ្យភាព សេរីភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា និងប្រទេសផ្សេងទៀត ដោយរក្សាសាមគ្គីភាពជាមួយប្រជាជនកម្ពុជាមិនផ្លាស់ប្តូរ និងប្រឹងប្រែងជាប់ជានិច្ចឆ្ពោះទៅរកដំណោះស្រាយបញ្ហាបន្ទាន់ទាក់ទងនឹងទំនាក់ទំនងរវាងប្រទេសទាំងពីរតាមរយៈការចរចា។

វៀតណាម និងកម្ពុជាគឺជាប្រទេសជិតខាងនឹងគ្នា។ ប្រជាជនរបស់ប្រទេសទាំងពីរមានទំនាក់ទំនងជាមួយគ្នាដ៏យូរលង់មកហើយតាមរយៈការវាយប្រយុទ្ធប្រឆាំងនឹងសត្រូវរួមគ្នា និងពួកចក្រពត្តិឈ្លានពានក្នុងការតស៊ូដើម្បីឯករាជ្យភាព និងសេរីភាព ហើយនៅថ្ងៃនេះ ប្រជាជនទាំងពីរមានសេចក្តីប៉ងប្រាថ្នាយ៉ាងមោះមុតរួមគ្នា ដើម្បីពង្រឹងសាមគ្គីភាព កិច្ចសហប្រតិបត្តិការរយៈពេលវែង និងការជួយគ្នាទៅវិញទៅមករបស់ពួកគេតាមរយៈការកសាងទឹកដីកំណើតដ៏រុងរឿងរបស់ខ្លួន ស្របតាមកាលៈទេសៈជាក់លាក់របស់ប្រទេសនីមួយៗ។ រដ្ឋាភិបាលនៃ

សាធារណរដ្ឋសង្គមនិយមវៀតណាមមើលឃើញថា បញ្ហារវាងប្រទេសវៀតណាម និងកម្ពុជា អាចត្រូវបានដោះស្រាយដោយសមស្របតាមរយៈការចរចា ដែលត្រូវបានធ្វើឡើងក្នុងស្មារតីសាមគ្គីភាពប្រឆាំងនឹងចក្រពត្តិនិយមនៃចលនារដ្ឋមិនចូលបក្សសម្ព័ន្ធ ក្នុងស្មារតីធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ក្នុងអត្ថប្រយោជន៍របស់ប្រជាជនទាំងពីរប្រទេស និងក្នុងអត្ថប្រយោជន៍នៃសន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ីអាគ្នេយ៍ និងពិភពលោក។

ដោយសារសេចក្តីប៉ងប្រាថ្នាដោះស្រាយបញ្ហាភ្លាមៗ ទាក់ទងនឹងទំនាក់ទំនងរវាងប្រទេសវៀតណាម និងកម្ពុជា រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមសូមស្នើថា៖

១. ប្រតិបត្តិការយោធាឈ្លានពានទាំងអស់នៅតំបន់ព្រំដែន ត្រូវផ្អាកភ្លាមៗ ដោយកងកម្លាំងប្រដាប់អាវុធរបស់ភាគីទាំងពីរដែលឈរជើងជ្រៅនៅទឹកដីរៀងៗខ្លួន ត្រូវដកថយចម្ងាយប្រាំគីឡូម៉ែត្រពីព្រំដែន។

២. ភាគីទាំងពីរជួបប្រជុំភ្លាមនៅទីក្រុងហាណូយ ទីក្រុងភ្នំពេញ ឬនៅទីកន្លែងណាមួយនៅតាមព្រំដែនរវាងប្រទេសទាំងពីរ ដើម្បីរៀបចំការប្រឹក្សាយោបល់ និងសម្រេចឲ្យបាននូវសន្ធិសញ្ញាមួយ ដែលភាគីទាំងពីរត្រូវអនុវត្ត ដើម្បីគោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់គ្នាទៅវិញទៅមក មិនវាយប្រហារគ្នាទៅវិញទៅមក មិនប្រើអំពើហិង្សា ឬគំរាមកំហែងដោយប្រើអំពើហិង្សាទៅលើទំនាក់ទំនងទៅវិញទៅមករបស់ខ្លួន មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក និងមិនរៀបចំរដ្ឋប្រហារប្រឆាំងគ្នាទៅវិញទៅមក ប្រព្រឹត្តិចំពោះគ្នាទៅវិញទៅមកដោយស្មើភាពគ្នា និងរស់នៅជាមួយគ្នាដោយសន្តិភាព និងរាក់ទាក់ក្នុងនាមជាអ្នកជិតខាងដ៏ល្អ។

ភាគីទាំងពីរសម្រេចបានកិច្ចព្រមព្រៀងស្តីពីព្រំដែនមួយ ដោយផ្អែកលើការគោរពបូរណភាពទឹកដីរវាងគ្នាទៅវិញទៅមកស្ថិតក្នុងព្រំដែនដែលមានស្រាប់។

៣. ភាគីទាំងពីរព្រមព្រៀងលើទម្រង់សមស្របមួយនៃការធានា និងការពិនិត្យតាមដានជាលក្ខណៈអន្តរជាតិ។

ដើម្បីជំរុញលក្ខខណ្ឌនានាឲ្យឆ្ពោះទៅរកការចរចារវាងប្រទេសទាំងពីរ ការឃោសនាដែលជំរុញឲ្យមានការស្អប់ខ្ពើមជាលក្ខណៈជាតិ និងរាល់សកម្មភាពទាំងអស់ដែលធ្វើឡើងក្នុងគោលបំណងបំបែកបំបាក់ប្រជាជនវៀតណាម និងកម្ពុជា ដែលធ្វើឲ្យប៉ះពាល់ដល់សាមគ្គីភាពប្រកបដោយមេត្រីភាពដែលមានស្រាប់រវាងប្រទេសទាំងពីរ ត្រូវតែបញ្ចប់។

រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឆ្លើយតបប្រកបដោយវិជ្ជមានទៅនឹងសំណើដ៏សមហេតុផលដែលបានលើកឡើងមុននេះ ដែលស្ថិតក្នុងអត្ថប្រយោជន៍បច្ចុប្បន្ន និងរយៈពេលវែងរវាងប្រជាជនកម្ពុជា និងប្រជាជនវៀតណាម និងស្ថិតក្នុងអត្ថប្រយោជន៍ជាមិត្តភាពរវាងប្រជាជនរបស់ប្រទេសទាំងពីរ។

រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមអំពាវនាវឲ្យរដ្ឋាភិបាលនានា និងប្រជាជនរបស់បណ្តាប្រទេស ដែលមានទំនាក់ទំនងមិត្តភាពជាមួយវៀតណាម និងកម្ពុជា អំពាវនាវដល់អង្គការអន្តរជាតិនានា និងប្រទេសដែលស្រលាញ់សន្តិភាព និងយុត្តិធម៌នៅក្នុងពិភពលោកឲ្យគាំទ្រដល់សំណើរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងដើរតួនាទីមួយផ្នែកដ៏សកម្មក្នុងការសម្របសម្រួលការចាប់ផ្តើមកិច្ចចរចាររវាងប្រទេសវៀតណាម និងកម្ពុជា ដើម្បីជាប្រយោជន៍នៃសន្តិភាព និងសន្តិសុខក្នុងតំបន់អាស៊ីអាគ្នេយ៍ និងពិភពលោក។

ទីក្រុងហាណូយ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៨

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

<u>**សន្និសីទសារព័ត៌មាន**</u>

នៅស្ថានទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ទីក្រុង
ប៊ែរឡាំង ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ស្តីពី
"ទំនាក់ទំនងរវាងវៀតណាម និងកម្ពុជា"

---

សុន្ទរកថាដោយ

AB [មិនស្គាល់អក្សរកាត់] ឯកអគ្គរដ្ឋទូត SRV ប្រចាំ GDR សមមិត្ត Hoang Tun។

មិត្ត និងសមមិត្តទាំងអស់ជាទីស្នេហា

ខ្ញុំមានសេចក្តីរីករាយណាស់ដែលបានស្វាគមន៍លោកអ្នកជាអ្នកតំណាងស្ថាប័នព័ត៌មាន និងឃោសនាការនៃសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់មកកាន់ស្ថានទូតរបស់យើងជាថ្មីម្តងទៀត។ មានការវិវឌ្ឍថ្មីៗជាច្រើនទាក់ទងនឹងទំនាក់ទំនងរវាងប្រទេសវៀតណាម និងកម្ពុជាក្នុងរយៈពេលបីសប្តាហ៍ចុងក្រោយនេះ។ ក្នុងអំឡុងពេលនេះ <u>រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមបានចេញផ្សាយសេចក្តីប្រកាសដ៏មានសារៈសំខាន់មួយនៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ដែលត្រូវបានជំរុញដោយបំណងប្រាថ្នា</u>ចង់បានដំណោះស្រាយបន្ទាន់មួយ ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងទំនាក់ទំនងរវាងប្រទេសវៀតណាម និងប្រទេសជិតខាងរបស់ខ្លួនគឺប្រទេសកម្ពុជា។

ដូចដែលលោកអ្នកដឹងហើយ <u>សេចក្តីប្រកាសរបស់រដ្ឋាភិបាលរបស់យើងនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ទទួលបានសមានចិត្ត និងការគាំទ្រពីប្រជាជន និងរដ្ឋាភិបាលនៃប្រទេសដែលស្រលាញ់សន្តិភាព</u> និងយុត្តិធម៌យ៉ាងច្រើននៅក្នុងពិភពលោក និងមតិសាធារណៈអន្តរជាតិជាទូទៅ រួមទាំងប្រជាជន និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ជាមិត្តផងដែរ។ មេដឹកនាំរបស់ប្រទេសកម្ពុជាបានខកខានក្នុងការឆ្លើយតបទៅនឹងសុឆន្ទៈនៃរដ្ឋាភិបាលរបស់យើង ហើយជំនួសមកវិញ ពួកគេបានបើកប្រតិបត្តិការយោធា ហើយបន្តចាត់វិធានការវាយប្រហារដោយយោធា ដោយពួកគេចូលជ្រៅមកក្នុងទឹកដីរបស់យើង

ហើយប្រព្រឹត្តអំពើឃោរឃៅដែលមិនអាចរៀបរាប់បានប្រឆាំងនឹងប្រជាជនរបស់យើង។ ពួកគេបើកការវាយប្រហារនៅតាមបណ្ដោយព្រំដែនទាំងមូលរវាងប្រទេសទាំងពីរ ព្រមទាំងបង្កើនយុទ្ធនាការឃោសនាបង្ខូចកេរ្តិ៍ឈ្មោះប្រឆាំងនឹងប្រទេសរបស់យើង និងប្រជាជនវៀតណាម បំផុសឲ្យមានការស្អប់ខ្ពើមជាលក្ខណៈជាតិតាមរយៈការចោទប្រកាន់ប្រជាជន និងរដ្ឋាភិបាលរបស់យើងថាបានបង្កើតគម្រោង “ឈ្លានពាន” និង “ជ្រៀតជ្រែក និងប៉ុនប៉ងធ្វើរដ្ឋប្រហារ” និងអះអាងដោយមិនត្រឹមត្រូវថា វៀតណាមកំពុង “បង្ខិតបង្ខំឲ្យកម្ពុជាចូលរួមក្នុងសហព័ន្ធឥណ្ឌូចិន”។

នៅក្នុងសន្និសីទសារព័ត៌មាននេះ ខ្ញុំមើលឃើញពីភាពចាំបាច់ដែលត្រូវបញ្ជាក់ដោយគ្មានលក្ខខណ្ឌជាក់លាក់ថា នៅក្នុងការចុះផ្សាយនេះ រដ្ឋាភិបាលរបស់យើងប្រកាន់គោលជំហររបស់ខ្លួនយ៉ាងច្បាស់៖ បញ្ហាអធិបតេយ្យភាព និងបូរណភាពទឹកដី គឺជារឿងសំខាន់ខ្លាំងណាស់ចំពោះប្រទេសនីមួយៗ។ ទោះជាយ៉ាងណាបញ្ហាព្រំដែន និងទឹកដីជាញឹកញាប់ពោរពេញទៅដោយជម្លោះ ហើយជួនកាលពោរពេញទៅដោយបញ្ហាដែលជាកេរដំណែលប្រវត្តិសាស្ត្រ។ ដោយហេតុនេះ ប្រទេសនានាដែលមានក្តីបារម្ភ ត្រូវតែពិនិត្យមើល និងវិភាគឲ្យបានម៉ត់ចត់ចំពោះបញ្ហានេះ ក្នុងស្មារតីស្មើភាព គោរពគ្នាទៅវិញទៅមក មិត្តភាព និងទំនាក់ទំនងអ្នកជិតខាងល្អដើម្បីរួមគ្នាដោះស្រាយបញ្ហានេះតាមរយៈការចរចា។ នេះគឺជាបំណងប្រាថ្នារបស់បក្សកុម្មុយនីស្តវៀតណាម និងរដ្ឋាភិបាល និងប្រជាជននៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ប្រការដ៏គួរឲ្យសោកស្តាយនោះគឺថា មេដឹកនាំកម្ពុជាបដិសេធយ៉ាងដាច់ខាតទៅនឹងការចរចាណាមួយ។ ច្បាស់ណាស់ចំពោះគោលបំណងដែលទស្សនៈពិភពលោកយល់ឃើញថា តាមរយៈការបដិសេធកិច្ចចរចា និងការពង្រាយកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនក្នុងការវាយប្រហារ និងក្នុងការបំផ្លិចបំផ្លាញតំបន់នានាក្នុងដែនដីរបស់វៀតណាម

មេដឹកនាំកម្ពុជាកំពុងបង្កើតផែនការដ៏គួរឲ្យសង្ស័យមួយ ដើម្បីអនុវត្តផែនការដែលបានបង្កើតឡើងជាយូរមក ហើយ ដើម្បីបង្កអន្តរាយជាបន្តបន្ទាប់ដល់ទំនាក់ទំនងនានារវាងប្រទេសវៀតណាម និងកម្ពុជា និងធ្វើឲ្យទំនាក់ទំនងទាំងនោះកាន់តែស្ថិតក្នុងហានិភ័យ។

បើទោះជាបច្ចុប្បន្ន កម្ពុជាកំពុងបង្កើនការឃោសនាបង្កូចកេរ្តិ៍ឈ្មោះដោយគ្មានមូលដ្ឋាន ប្រកាន់ដោយគំនិតព្យាបាទ និងទុទិដ្ឋិនិយមប្រឆាំងនឹងសាធារណរដ្ឋសង្គមនិយមវៀតណាមក្តី ក៏រដ្ឋាភិបាលរបស់យើង ដោយផ្អែកលើហេតុផល និងកម្លាំងសាមគ្គីរវាងប្រទេសវៀតណាម និងកម្ពុជា បានចុះផ្សាយសេចក្តីប្រកាសថ្មីមួយនៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ទាក់ទងនឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ ដែលរដ្ឋាភិបាលរបស់យើងបានដាក់សំណើដ៏រឹងមាំ ដើម្បីឲ្យមានដំណោះស្រាយបញ្ហានានាជាបន្ទាន់រវាងប្រទេសទាំងពីរ និងសម្រាប់ការលើកកម្ពស់ទំនាក់ទំនងក្នុងនាមជាប្រទេសជិតខាង និងទំនងទំនងដ៏យូរអង្វែងរវាងប្រទេសទាំងពីរ។ សំណើទាំងនោះមានចែងយ៉ាងច្បាស់ដូចខាងក្រោម៖

១. បញ្ឈប់ជាបន្ទាន់នូវប្រតិបត្តិការយោធាឈ្លានពានទាំងអស់នៅក្នុងតំបន់ព្រំដែន។ ការឈរជើងរបស់កងកម្លាំងប្រដាប់អាវុធរបស់ភាគីទាំងសងខាង ត្រូវចូលជ្រៅទៅក្នុងដែនដីរៀងៗខ្លួនប្រហែលប្រាំគីឡូម៉ែត្រពីព្រំដែន។

២. ភាគីទាំងពីរជួបប្រជុំភ្លាមនៅទីក្រុងហាណូយ ទីក្រុងភ្នំពេញ ឬនៅទីកន្លែងណាមួយនៅតាមព្រំដែនរវាងប្រទេសទាំងពីរ ដើម្បីរៀបចំការប្រឹក្សាយោបល់ និងសម្រេចឲ្យបានសន្ធិសញ្ញាមួយ ដែលភាគីទាំងពីរត្រូវអនុវត្ត ដើម្បីគោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់គ្នាទៅវិញទៅមក មិនវាយប្រហារគ្នាទៅវិញទៅមក មិនប្រើអំពើហិង្សា ឬគំរាមកំហែងប្រើអំពើហិង្សាទៅលើទំនាក់ទំនងទៅវិញទៅមករបស់ខ្លួន មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក និងមិនរៀបចំរដ្ឋប្រហារប្រឆាំងគ្នាទៅវិញទៅមក ប្រព្រឹត្តិចំពោះគ្នាទៅវិញទៅមកដោយស្មើភាពគ្នា និងរស់នៅជាមួយគ្នាដោយសន្តិភាព និងរាក់ទាក់ក្នុងនាមជាអ្នកជិតខាងដ៏ល្អ។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

ភាគីទាំងពីរសម្រេចបានកិច្ចព្រមព្រៀងស្តីពីព្រំដែនមួយ ដោយផ្អែកលើការគោរពអធិបតេយ្យភាពទឹកដីរវាងគ្នាទៅវិញទៅមកស្ថិតក្នុងព្រំដែនដែលមានស្រាប់។

៣. ភាគីទាំងពីរព្រមព្រៀងលើទម្រង់សមស្របមួយនៃការធានា និងការពិនិត្យតាមដានជាលក្ខណៈអន្តរជាតិ។

តាមរយៈសំណើខាងលើ រដ្ឋាភិបាលរបស់យើងចង់បង្ហាញឱ្យបានច្បាស់លាស់អំពីភាពស្មោះត្រង់ និងសុឆន្ទៈរបស់ខ្លួន បើទោះជាមានការបង្ខូចកេរ្តិ៍ឈ្មោះដោយគ្មានមូលដ្ឋានពីសំណាក់មេដឹកនាំកម្ពុជាក្តី។ ចំពោះការចោទប្រកាន់មួលបង្កាច់អំពី "ការឈ្លានពានទឹកដីកម្ពុជា" ពីសំណាក់មេដឹកនាំកម្ពុជា យើងសូមឆ្លើយតបតាមរយៈការប្រកាសពីបំណងរបស់យើង ក្នុងការសម្រេចឱ្យបានកិច្ចព្រមព្រៀងមួយជាមួយពួកគេ ដែលភាគីទាំងពីរនឹងឈរជើងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនជ្រៅនៅក្នុងទឹកដីរបស់ខ្លួនប្រវែងប្រាំគីឡូម៉ែត្រពីព្រំដែន។ ចំពោះការចោទប្រកាន់មួលបង្កាន់បង្ខូចកេរ្តិ៍ឈ្មោះរបស់ពួកគេដែលថា យើងមានការពាក់ព័ន្ធទៅនឹង "ការប៉ុនប៉ងធ្វើរដ្ឋប្រហារ" នោះ យើងសូមឆ្លើយតបតាមរយៈសំណើសុំឱ្យមានការពិភាក្សាជាបន្ទាន់ និងសម្រេចឱ្យបានសន្ធិសញ្ញាមួយ ដែល "ពួកគេត្រូវអនុវត្តដើម្បីគោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់គ្នាទៅវិញទៅមក"។

តាមរយៈការចោទប្រកាន់មួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់យើងថាបង្ខំឱ្យពួកគេ "ចូលរួមក្នុងសហព័ន្ធឥណ្ឌូចិន" ពួកគេបានពាក់ព័ន្ធនឹងការបំភ្លៃប្រវត្តិសាស្ត្រទាំងស្រុង។ តើអ្វីដែលបានបង្កើតឱ្យមានពាក្យថា "សហព័ន្ធឥណ្ឌូចិន" និងតើនៅពេលណាដែលពាក្យនេះត្រូវបានគេបោះបង់ចោល? នៅពេលនេះ ខ្ញុំសូមពន្យល់អំពីប្រធានបទនេះចាប់តាំងពីដើមទីមក។

កាលពីអតីតកាល អាណានិគមជនបារាំងបានបំបែកប្រទេសទាំងបីនៅឧបទ្វីបឥណ្ឌូចិនទៅជាប្រាំតំបន់សម្រាប់ជាប្រយោជន៍នៃគោលនយោបាយរបស់ពួកគេ ដើម្បី "បំបែក និងគ្រប់គ្រង" (ដោយប្រទេសវៀតណាមខ្លួនឯងផ្ទាល់ ត្រូវបានបំបែកចេញជាបីតំបន់)។ តំបន់នីមួយៗត្រូវបានគ្រប់គ្រងទៅតាមរបបដាច់ដោយឡែកពីគ្នា។ បក្សកុម្មុយនីស្តឥណ្ឌូចិន

ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៣០ បានចូលរួមពាក់ព័ន្ធយ៉ាងខ្លាំងក្នុងការតស៊ូរបស់ប្រជាជនរបស់ប្រទេសទាំងបី។ ក្នុងឆ្នាំ ១៩៥១ នៅក្នុងសមាជលើកទីពីររបស់បក្សកុម្មុយនីស្តឥណ្ឌូចិន ដែលមានការចូលរួមដោយគណៈប្រតិភូពីប្រទេសទាំងបី គឺវៀតណាម ឡាវ និងកម្ពុជា សេចក្តីសម្រេចមួយត្រូវបានធ្វើឡើងទៅតាមសំណើរបស់មេដឹកនាំវៀតណាម ដើម្បីបង្កើតបក្សចំនួនបីចេញពីបក្សមួយនេះ ដែលបក្សនីមួយៗ នឹងទទួលខុសត្រូវលើការដឹកនាំប្រជាជនរបស់ប្រទេសរបស់ពួកគេក្នុងការតស៊ូរំដោះប្រទេស។ ដោយហេតុនេះ សេចក្តីប្រកាសចុងក្រោយនៃសន្និសីទទីក្រុងហ្សឺណែវស្តីពីឥណ្ឌូចិនក្នុងឆ្នាំ ១៩៥៤ រដ្ឋនានាដែលបានចូលរួមបានសន្យាគោរពអធិបតេយ្យភាព ឯករាជ្យភាព សាមគ្គីភាព និងបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា ឡាវ និងវៀតណាម។ សិទ្ធិជាមូលដ្ឋានទាំងនេះត្រូវបានធានាសាជាថ្មីក្នុងកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវនៅឆ្នាំ១៩៦២ ស្តីពីប្រទេសឡាវ។ ទៅតាមសំណើរបស់ព្រះប្រធានប្រមុខរដ្ឋ សម្តេច សីហនុ រណសិរ្សជាតិរំដោះវៀតណាមខាងត្បូងបានប្រកាសនៅក្នុងខែ ឧសភា ឆ្នាំ ១៩៦៧ ហើយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមខាងត្បូងបានប្រកាសនៅក្នុងខែ មិថុនា ឆ្នាំ ១៩៦៧ ថា ពួកគេទទួលស្គាល់បូរណភាពទឹកដីរបស់ប្រទេសកម្ពុជាស្ថិតក្នុងព្រំដែនបច្ចុប្បន្ន ហើយបានសន្យាគោរពព្រំដែនដែលបានលើកឡើងនេះ។ សន្និសីទកំពូលរបស់ប្រជាជនឥណ្ឌូចិនក្នុងឆ្នាំ ១៩៧០ បានគូសបញ្ជាក់ថា៖ "បក្សទាំងបីអះអាងពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការរក្សា និងបង្កើតមិត្តភាពភាតរភាព និងទំនាក់ទំនងជាអ្នកជិតខាងល្អរវាងប្រទេសទាំងបី ដោយមានទស្សនៈគាំទ្រគ្នាទៅវិញទៅមកក្នុងការតស៊ូប្រឆាំងនឹងសត្រូវរួមគ្នា និងសហប្រតិបត្តិការនាពេលអនាគតដ៏យូរអង្វែងក្នុងការកសាងប្រទេសនីមួយឡើងវិញតាមវិធីរៀងៗខ្លួន។ បក្សទាំងបីបានប្តេជ្ញាចិត្តគោរពតាមគោលការណ៍សហត្ថិភាពប្រកបដោយសន្តិភាពចំនួនប្រាំចំណុច...និងអះអាងថា រាល់បញ្ហាដែលកើតមានឡើងក្នុងទំនាក់ទំនងរវាងប្រទេសទាំងបី អាចត្រូវបានដោះស្រាយបានតាមរយៈការចរចាក្នុងស្មារតីគោរពគ្នាទៅវិញទៅមក យោគយល់គ្នាទៅវិញទៅមក និងជួយគ្នាទៅវិញទៅមក"។

កិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីប្រទេសវៀតណាម និងសេចក្តីថ្លែងការណ៍ផ្លូវការអន្តរជាតិចុងក្រោយក្នុងឆ្នាំ ១៩៧៣ បានធានាជាថ្មីថា ឯករាជ្យភាព អធិបតេយ្យភាព សាមគ្គីភាព និងបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា និងឡាវ នឹងត្រូវបានគោរព។ សមាជលើកទីបួនរបស់បក្សកុម្មុយនីស្តវៀតណាមក្នុងឆ្នាំ ១៩៧៦ បានអះអាងជាថ្មីអំពីគោលនយោបាយរបស់វៀតណាមចំពោះប្រទេសឡាវ និងកម្ពុជា។ ការពិតទាំងនេះបញ្ជាក់ពីការបន្តគោរពឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ដែលត្រូវបានបង្ហាញដោយបក្សកុម្មុយនីស្តវៀតណាម និងរដ្ឋាភិបាល និងប្រជាជននៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ការភូតភរទាំងស្រុងថា "វៀតណាមកំពុងបង្ខំឱ្យកម្ពុជាចូលរួមក្នុងសហព័ន្ធឥណ្ឌូចិនស្ថិតក្រោមអនុត្តរភាពវៀតណាម" ប្រែក្លាយទៅជាការបំភ្លៃដែលមិនគួរឱ្យចូលចិត្តចំពោះផ្នែកខ្លះនៃមេដឹកនាំកម្ពុជា និងត្រឹមតែបម្រើផលប្រយោជន៍ដល់ពួកចក្រពត្តិនិយម និងក្រុមពួកប្រតិកិរិយាប៉ុណ្ណោះ។

ប្រសិនបើអាជ្ញាធរកម្ពុជា ពិតជាមិនចង់ប្រើអំពើហិង្សាដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសវៀតណាមមែននោះ ប្រសិនបើពួកគេពិតជាមិនចង់ចាត់ទុកសាធារណរដ្ឋសង្គមនិយមវៀតណាមជាសត្រូវចម្បងរបស់ពួកគេ ដូចដែលពួកគេអះអាងជារៀងរាល់ថ្ងៃមែននោះ ហើយប្រសិនបើពួកគេមិនចង់ដឹកនាំប្រទេសរបស់ពួកគេឱ្យធ្លាក់ចូលក្នុងផ្លូវអមិត្តភាពប្រឆាំងនឹងប្រជាជនរបស់ប្រទេសជាបងប្អូន ដែលបច្ចុប្បន្នគ្មានប្រាថ្នាចង់បានអ្វីក្រៅពីសភាពជាប្រទេសបងប្អូនរបស់ប្រជាជនកម្ពុជាមែននោះ ពួកគេត្រូវពិចារណាឡើងវិញអំពីតួនាទីរបស់ពួកគេចំពោះសំណើថ្មីៗរបស់រដ្ឋាភិបាលវៀតណាម និងអង្គុយនៅតុចរចាជាមួយវៀតណាម។ ការច្រានចោលសំណើនេះ នឹងត្រឹមតែអូសបន្លាយពេលវេលា និងកាន់តែបង្កឱ្យមានភាពតានតឹងបន្ថែមទៀតតែប៉ុណ្ណោះ។ ស្ថានភាពកិច្ចការបែបនេះត្រឹមតែផ្តល់ប្រយោជន៍ដល់ពួកចក្រពត្តិនិយម និងក្រុមពួកប្រតិកិរិយាតែប៉ុណ្ណោះ ដែលពួកទាំងនេះគឺជាសត្រូវរួមគ្នារបស់ប្រជាជនវៀតណាម និងប្រជាជនកម្ពុជា។

ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីសម្តែងការដឹងគុណយ៉ាងស្មោះស្ម័គ្ររបស់ខ្ញុំចំពោះសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតក្នុងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ដែលបានចំណាយពេលវេលារបស់ខ្លួនមកតាមដានហេតុការណ៍នេះ និងសម្រាប់ការគាំទ្រទាក់ទងនឹងបញ្ហាព្រំដែននេះ។

ក្តីសង្ឃឹមរបស់ខ្ញុំគឺថា រដ្ឋាភិបាល ស្ថាប័នផ្សព្វផ្សាយ និងសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ដែលជាប្រទេសបងប្អូនរបស់យើង នឹងស្វាគមន៍យ៉ាងកក់ក្តៅចំពោះសេចក្តីប្រកាសរបស់រដ្ឋាភិបាលយើងកាលពីថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ និងសំណើដ៏រឹងមាំទាំងបីរបស់រដ្ឋាភិបាលយើង ដូចដែលបានលើកឡើងខាងលើ។

ក្រសួងការបរទេស នាយកដ្ឋានចុងបូព៌ា ទីក្រុងប៉ែរឡាំង ថ្ងៃទី ១៧/០១/១៩៧៨

ចារកម្ម

(ប្រភព៖ ព័ត៌មានពី AV [មិនស្គាល់អក្សរកាត់] របាយការណ៍សារព័ត៌មាន)

គោលជំហរអន្តរជាតិពាក់ព័ន្ធនឹងជម្លោះព្រំដែនរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

---

ប្រទេសសង្គមនិយមជាបងប្អូន ដូចជា USSR [សហភាពនៃសាធារណរដ្ឋសង្គមនិយមរុស្ស៊ី] GDR [សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់] CSR [សាធារណរដ្ឋសង្គមនិយមឆេកូស្លូវ៉ាគី] សាធារណរដ្ឋប្រជាមានិតប៉ូឡូញ សាធារណរដ្ឋប្រជាមានិតហុងគ្រី សាធារណរដ្ឋប្រជាមានិតប៊ុលហ្គារី សាធារណរដ្ឋប្រជាមានិតម៉ុងហ្គោលី និងប្រទេសគុយបា បានគាំទ្រសេចក្តីប្រកាសរបស់រដ្ឋាភិបាល SRV នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ដែលឯកអគ្គរដ្ឋទូត ឬភារធារីបណ្តោះអាសន្ននៃ SRV ផ្តល់ជូនបណ្តាក្រសួងការបរទេសពាក់ព័ន្ធ។ ស្ថានទូតនៃបណ្តាប្រទេសទាំងនេះនៅក្នុងទីក្រុងប៉េកាំង លើកលែងតែ ស្ថានទូតប្រទេសគុយបា បានបញ្ជូនត្រឡប់មកកម្ពុជាវិញនូវសេចក្តីប្រកាសបង្កាច់បង្ខូចនាថ្ងៃដដែលនោះ។ រដ្ឋាភិបាលគុយបាមិនចង់ផ្តល់ឲ្យមូលហេតុណាមួយដែលឈានទៅដល់ការបិទស្ថានទូតរបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញឡើយ។

អនុរដ្ឋមន្ត្រីការបរទេសទីមួយនៃសហភាពសូវៀត Malzew បានទទួលភារធារីបណ្តោះអាសន្ននៃ SRV ក្នុងគោលបំណងទទួលយកសេចក្តីប្រកាសរបស់ SRV និងបានបញ្ជាក់អះអាងថា USSR នឹងគាំទ្រគោលជំហរដ៏ត្រឹមត្រូវរបស់ SRV ពាក់ព័ន្ធនឹងដំណោះស្រាយបញ្ហាព្រំដែនរវាងកម្ពុជា និងវៀតណាមតាមរយៈការចរចា។ មិនមានសេចក្តីថ្លែងការណ៍ ឬសេចក្តីប្រកាសផ្លូវការ ត្រូវបានធ្វើឡើងនៅក្នុងពេលនេះឡើយ។

*Pravda* បានចុះផ្សាយសម្រង់នៃសេចក្តីប្រកាសរបស់ SRV ដោយសង្កត់ធ្ងន់លើការរាំងស្ទះដែលបានលើកឡើងដោយរដ្ឋាភិបាល SRV រហូតមកដល់ពេលនេះ និងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការស្វែងរកដំណោះស្រាយដោយសន្តិវិធី។

Original DE: 00537030-00537080
Note: This Khmer translation is based on the English version which was translated from the original German text.

អនុរដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ E. Moldt បានទទួលភារធារីបណ្ដោះអាសន្ននៃ SRV នៅថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៧៨ និងបានបញ្ជាក់ថា GDR គាំទ្រដល់សេចក្ដីប្រកាសរបស់ SRV។ GDR យល់ឃើញថា បញ្ហាព្រំដែនរវាង SRV និងកម្ពុជាប្រជាធិបតេយ្យ អាចត្រូវបានដោះស្រាយតាមរយៈការចរចាបិទទ្វារតែប៉ុណ្ណោះ។

បទអត្ថាធិប្បាសារព័ត៌មានមួយកំពុងត្រូវបានរៀបចំ។

អនុរដ្ឋមន្ត្រីការបរទេសទីមួយនៃសាធារណរដ្ឋសង្គមនិយមឆែកូស្លូវ៉ាគី Krajcir Lors បានទទួលឯកអគ្គរដ្ឋទូតនៃ SRV នៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨។ *Rude Pravo* បានរាយការណ៍ពីព័ត៌មាននេះនៅក្នុងសេចក្ដីប្រកាសមួយ។ សមមិត្ត Krajcir Lors បានថ្លែងថា គាត់ជឿថា បញ្ហានេះនឹងត្រូវបានដោះស្រាយនៅក្នុងស្មារតីនៃសំណើរបស់ SRV តាមរយៈការចរចា។ នៅថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៨

កាសែតដដែលនេះបានចុះផ្សាយបទអត្ថាធិប្បាយមួយស្តីពីគោលនយោបាយការបរទេស។

អនុរដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាមានិតប៉ូឡូញ Spasowski បានទទួលឯកអគ្គរដ្ឋទូត SRV នៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨ និងបានថ្លែងថា៖ យើងគាំទ្រគោលជំហរសុឆន្ទៈដូចដែលបានបញ្ជាក់នៅក្នុងសេចក្តីប្រកាសរបស់រដ្ឋាភិបាលរបស់អ្នក និងយល់ឃើញថា បញ្ហាព្រំដែនត្រូវដោះស្រាយក្នុងស្មារតីនៃមិត្តភាពជាបងប្អូន។ កាសែត *Tribuna Ludu* បានចុះផ្សាយបទអត្ថាធិប្បាយមួយរបស់ទីភ្នាក់ងារ PAP [ទីភ្នាក់ងារសារព័ត៌មានប៉ូឡូញ] នៅថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៧៨ ដែលបានគូសបញ្ជាក់ថា មតិសាធារណជនប៉ូឡូញគាំទ្រដល់គោលជំហរដ៏ត្រឹមត្រូវរបស់ SRV ចំពោះដំណោះស្រាយដោយសន្តិវិធី។ ការមិនយល់អំពីគោលជំហរកម្ពុជាក្នុងការច្រានចោលដំណោះស្រាយនេះ ត្រូវបានលើកឡើង។

រដ្ឋលេខាធិការនៃក្រសួងការបរទេសរបស់សាធារណរដ្ឋប្រជាមានិតហុងគ្រី Racz បានទទួលឯកអគ្គរដ្ឋទូត SRV នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៧៨។ គាត់បានបញ្ជាក់ថា រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតហុងគ្រី គាំទ្រដល់គោលជំហររបស់ SRV។ នៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៨ សេចក្តីប្រកាសស្តីពីជម្លោះនេះ ត្រូវបានចុះផ្សាយនៅក្នុងសារព័ត៌មាន។

នៅថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៧៨ បទអត្ថាធិប្បាយមួយត្រូវបានចុះផ្សាយនៅក្នុង *Nepszabadsag* ដោយគាំទ្រការប្តេជ្ញាចិត្តក្នុងការពារប្រឆាំងនឹងការញុះញង់របស់កម្ពុជាព្រមទាំងគូសបញ្ជាក់ពីការទទួលខុសត្រូវយ៉ាងធំធេងរបស់ SRV ចំពោះជោគវាសនានៃប្រទេសជាតិទាំងពីរ។

នៅក្នុងសាធារណរដ្ឋប្រជាមានិតប៊ុលហ្គារី

នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៧៨ *Rabotnitscheskoje Delo* (អ្នកអង្កេតការណ៍នយោបាយរបស់ BTA [ទីភ្នាក់ងារសារព័ត៌មានប៊ុលហ្គារី] បានគូសបញ្ជាក់ថា មតិសាធារណជនប៊ុលហ្គារីស្វាគមន៍គំនិតផ្តួចផ្តើមរបស់ Pham Van Dong នាយករដ្ឋមន្ត្រីរបស់ SRV ឱ្យមានការចរចាជាបន្ទាន់ក្នុងគោលបំណងដោះស្រាយជម្លោះ និងការបន្តទំនាក់ទំនងជាបងប្អូន។ មានតែកិច្ចពិភាក្សាគ្នារវាងភាគីទាំងពីរនឹងធ្វើឱ្យមានការចូលរួមចំណែកយ៉ាងពិតប្រាកដក្នុងការស្តារសន្តិសុខឡើងវិញនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

ក្នុងអំឡុងពេលនៃកិច្ចពិភាក្សារវាងរដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាមានិតម៉ុងហ្គោលី Dugersuren និងឯកអគ្គរដ្ឋទូត SRV នៅថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៧៨ ការគាំទ្រចំពោះគោលជំហររបស់ SRV ដែលទាក់ទងទៅនឹងដំណោះស្រាយជម្លោះព្រំដែនដោយសន្តិវិធី ត្រូវបានលើកឡើង។ នៅក្នុងរបាយការណ៍សារព័ត៌មានមួយនៅក្នុង *Unen* នាថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៨ ស្តីពីកិច្ចប្រជុំនេះ គោលជំហររបស់ Dugersuren ត្រូវបានចាត់ទុកថាជាគោលជំហរផ្លូវការរបស់ប្រទេស និងប្រជាជនម៉ុងហ្គោលី។

នៅក្នុងប្រទេសគុយបា *Granma* បានចុះផ្សាយអត្ថបទនៃសេចក្តីប្រកាសរបស់ SRV ដោយប្រើពាក្យពេចន៍ត្រង់ៗ នៅថ្ងៃទី ២ ខែ មករា ឆ្នាំ ១៩៧៨។ ក្រសួងការបរទេសបានចេញសេចក្តីប្រកាសមួយនៅថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៧៨ ដោយបានរៀបរាប់ពីទស្សនៈយ៉ាងមុតមាំថា ការលំបាកនាពេលបច្ចុប្បន្នក្នុងទំនាក់ទំនងនានា នឹងត្រូវបានដោះស្រាយតាមរយៈការដាក់ការជឿទុកចិត្តចំពោះវឌ្ឍនភាពរបស់ប្រជាជនវៀតណាម និងប្រជាជនកម្ពុជា និងនៅក្នុងផលប្រយោជន៍នៃការតស៊ូរួមគ្នាប្រឆាំងនឹងចក្រពត្តិនិយម អាណានិគមនិយមចាស់ និងអាណានិគមនិយមថ្មី។

គោលជំហរផ្លូវការរបស់ SRR [សាធារណរដ្ឋសង្គមនិយមរ៉ូម៉ានី] គឺមិនគាំទ្រភាគីណាមួយឡើយ។ ចំពោះហេតុផលនេះ ប្រព័ន្ធផ្សព្វផ្សាយ បានចុះផ្សាយសម្រង់នៃសេចក្តីប្រកាសរបស់ SRV និងកម្ពុជាប្រជាធិបតេយ្យដោយគ្មានសេចក្តីអត្ថាធិប្បាយបន្ថែម (យោងតាម VNA [ទីភ្នាក់ងារសារព័ត៌មានវៀតណាម] និងវិទ្យុទីក្រុងភ្នំពេញ) *។

បន្ទាប់ពីបានទទួលសេចក្តីប្រកាសរបស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម Phoune Sipaseuth ដែលជាសមាជិកនៃគណៈកម្មាធិការប្រធានផ្នែកនយោបាយ និងប្រតិបត្តិនៃគណៈកម្មាធិការមជ្ឈិម ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ បានសម្តែងក្តីសង្ឃឹមថា ជម្លោះនេះនឹងត្រូវបានដោះស្រាយដោយសន្តិវិធី។ នៅចំពោះមុខឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំទីក្រុងវៀងច័ន្ទ លោកឧបនាយករដ្ឋមន្ត្រី បានថ្លែងថា៖ "ព្រឹត្តិការណ៍ទាំងនេះ កំពុងបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់ទំនាក់ទំនងមិត្តភាពយូរអង្វែងក្នុងចំណោមប្រទេសជិតខាងជាបងប្អូនទាំងពីរ។ ប្រជាជនរបស់បក្សបដិវត្តន៍ រដ្ឋាភិបាលឡាវ និងជាតិឡាវទាំងមូល មានបំណងប្រាថ្នាយ៉ាងជ្រាលជ្រៅថា រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលវៀតណាម នឹងចាប់ផ្តើមចរចាដោយគ្មានការពន្យារពេលដើម្បីដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធី និងដោយអនុលោមតាមគោលការណ៍នៃការគោរពអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសទាំងពីរ។

---

* **នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៧៨ *Scintea* បានចុះផ្សាយអត្ថបទវែងមួយ ដោយគូសបញ្ជាក់ពីតម្រូវការនៃដំណោះស្រាយដោយសន្តិវិធី។ តាមសេចក្តីរាយការណ៍ SRR នៅតែមានការប្តេជ្ញាចិត្តក្នុងការបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធនៃកិច្ចសហប្រតិបត្តិការមិត្តភាព និងកិច្ចសហប្រតិបត្តិការពហុភាគីជាមួយប្រទេសទាំងពីរ។**

វាមិនមែនជាការសម្ងាត់នោះទេដែលថារដ្ឋាភិបាលនៃ SRV ជាញឹកញាប់ បានបញ្ចាក់ពីឆន្ទៈរបស់ខ្លួនក្នុងការចាប់ផ្ដើមការចរចាជាមួយកម្ពុជាភ្លាមៗនៅកន្លែងណាមួយ និងនៅកម្រិតណាមួយ។ ប៉ុន្តែទីក្រុងភ្នំពេញបានបដិសេធការផ្ដួចផ្ដើមនេះ។

SFRY [សាធារណរដ្ឋសង្គមនិយមសហព័ន្ធយូហ្គោស្លាវី] យល់ឃើញថា "ជម្លោះសោកនាដកម្ម" នេះគឺជាការសោកស្ដាយ និងចាត់ទុកជម្លោះនេះថាជាភស្ដុតាងដែលសណ្ដាប់ធ្នាប់សង្គមនៃប្រទេសសង្គមនិយមមិនបានទប់ស្កាត់សង្គ្រាម។ ប្រសិនបើជម្លោះនេះត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស ប្រការចាំបាច់គឺមិនត្រូវមានការជ្រៀតជ្រែកពីខាងក្រៅឡើយ។

ភាគីវៀតណាមបានគោរពយ៉ាងតឹងរឹងដោយគោលនយោបាយនៃយុទ្ធសាមគ្គីភាពជាមួយប្រជាជនកម្ពុជា "ទោះជាយ៉ាងនេះក្តី មានការព្រួយបារម្ភថា កម្ពុជាគឺជាប្រភពនៃភាពតានតឹងដែលបានកើនឡើងនៅតាមព្រំដែន ដែលធ្វើឱ្យទំនាក់ទំនងរវាងប្រទេសទាំងពីរស្ថិតក្នុងគ្រោះថ្នាក់ធ្ងន់ធ្ងរ" ។

ក្រសួងការបរទេសបានប្រគល់ភារកិច្ចឱ្យ *Tanjug* ដោយបានច្រានចោលនូវរបាយការណ៍របស់ AP ថា ប្រេសិតរបស់ SRV បានជួបជាមួយរដ្ឋមន្ត្រីក្រសួងការបរទេសយូហ្គោស្លាវី នៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៨។ រដ្ឋមន្ត្រីក្រសួងការបរទេសយូហ្គោស្លាវី មិនបានទទួលប្រេសិត ឬឯកអគ្គរដ្ឋទូត SRV នោះឡើយចាប់តាំងពីជម្លោះរវាងវៀតណាម និងកម្ពុជាបានផ្ទុះឡើង។

ក្នុងប្រទេសអាល់បានី សម្រង់នៃសេចក្តីប្រកាសដែលមានប្រវែងស្មើគ្នារបស់កម្ពុជា និងវៀតណាមត្រូវបានចុះផ្សាយ។ នៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៨ បក្សពលករអាល់បានី បានអំពាវនាវដល់ប្រទេសទាំងពីរ (យោងតាមរបាយការណ៍របស់ AFP នៅថ្ងៃទី ៥ ខែ មករា) ឱ្យធ្វើការចរចាសន្តិភាព។ វិចារណកថារបស់អង្គការបក្សយល់ឃើញថា ជម្លោះនេះគឺគួរឱ្យសោកស្តាយ និងបង្ហាញពីការភ័យខ្លាចថាវាអាចរីករាលដាល។ វិចារណកថានេះពិពណ៌នាជម្លោះនេះថាជា "ការងាររបស់ខ្មាំងរបស់ប្រជាជនកម្ពុជា និងប្រជាជនវៀតណាម" "នៃចក្រពត្តិសង្គមនិយមសូវៀត និងចក្រពត្តិអាមេរិច ដែលស្វែងរកឧត្តមភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍"។ នៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៨ *ZIP* បានចុះផ្សាយអត្ថបទមួយដែលមានចំណងជើងថា "ជម្លោះគឺមិនមែនជាអត្ថប្រយោជន៍ដ៏ចម្បងរបស់ប្រជាជនវៀតណាម និងប្រជាជនកម្ពុជានោះឡើយ"។ បក្សពលករ រដ្ឋាភិបាល និងប្រជាជនអាល់បានី ចង់ឃើញការបញ្ចប់ជាបន្ទាន់នូវអរិភាព និងការបង្ហូរឈាមនេះ។ នៅក្នុងស្ថានភាពនេះ "យើងមិនចង់គាំទ្រភាគីណាមួយឡើយ ..., យើងក៏សង្ឃឹមដែរថា ប្រទេសចិនដែលជាបងប្អូន... នឹងធ្វើការសម្រុះសម្រួលក្នុងពេលបច្ចុប្បន្ននេះ ... យើងជឿជាក់យ៉ាងមុតមាំថា ជម្លោះនេះគឺជាការងាររបស់ពួកខ្មាំងនៃជាតិទាំងពីរនេះ"។

ឯកអគ្គរដ្ឋទូតនៃ SRV ប្រចាំ DPRK [សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ] ដែលមានភារកិច្ចក្នុងការនាំសេចក្តីថ្លែងការណ៍ទៅឱ្យរដ្ឋមន្ត្រីក្រសួងការបរទេស DPRK ឈ្មោះ Ho Dam ថា រដ្ឋាភិបាល SRV មិនអាចយល់ពីហេតុផលចំពោះការចុះផ្សាយដោយលម្អៀងនូវសេចក្តីប្រកាសរបស់រដ្ឋាភិបាលកម្ពុជានៅក្នុង DPRK។ គាត់បានផ្តល់ឱ្យអនុរដ្ឋមន្ត្រីក្រសួងការបរទេសនូវលិខិតជំនួយស្មារតីសមស្របមួយ។ អនុរដ្ឋមន្ត្រីក្រសួងការបរទេសបានធានាថា គាត់នឹងប្រគល់លិខិតនេះទៅថ្នាក់លើបន្តទៀត។

ឯកអគ្គរដ្ឋទូតនៃ SRV បានរៀបរាប់ពីគោលជំហររបស់ DPRK ថាមិនត្រឹមត្រូវ និងផ្ទុយទៅនឹងទំនាក់ទំនងរវាងប្រទេសសង្គមនិយមជាបងប្អូន។

នៅក្នុងគំនិតរបស់គាត់ គោលជំហររបស់ DPRK អាចត្រូវបានចាត់ទុកថាស្ថិតក្រោមឥទ្ធិពល និងសម្ពាធរបស់ចិន។

អង្គការចាត់តាំងផ្លូវការរបស់បក្សពលករ WPK [បក្សពលករកូរ៉េ] បានចុះផ្សាយសារលិខិតផ្ទាល់ខ្លួនរបស់ខៀវ សំផន ផ្ញើជូន Kim Il Sung ដោយប្រើពាក្យពេចន៍ត្រង់ៗ នៅថ្ងៃទី ២ ខែ មករា ឆ្នាំ ១៩៧៨ នៃសម្រង់ចេញពីសេចក្តីប្រកាសរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ (កន្លះទំព័រ) និងសម្រង់ចេញពីសេចក្តីប្រកាសរបស់រដ្ឋាភិបាល SRV នៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨ (មួយភាគបួននៃទំព័រ) ។

<u>សាធារណរដ្ឋប្រជាមានិតចិន</u> (PRC) មិនទាន់បានចេញសេចក្តីថ្លែងការណ៍ផ្លូវការស្តីពីជម្លោះរវាងកម្ពុជា និង SRV នៅឡើយទេ។ នៅថ្ងៃទី ១៤ និង ១៥ ខែ មករា ឆ្នាំ ១៩៧៨ *Süddeutsche Zeitung* បានរាយការណ៍ដូចខាងក្រោម៖ ឧបនាយករដ្ឋមន្ត្រីចិន Tschi Teng-Kwei បានជូនដំណឹងដល់សមាជិករដ្ឋសភាជប៉ុន Chuji Kuno នៅទីក្រុងប៉េកាំងថា ប្រទេសចិនចាត់ទុកការដកកងទ័ពរបស់វៀតណាមចេញពីកម្ពុជាថាជាបុរេលក្ខខណ្ឌចំពោះដំណោះស្រាយនៃជម្លោះ រវាងប្រទេសទាំងពីរតាមរយៈការចរចា។ Tschi បានមានប្រសាសន៍ថា ដូចដែលភាគីជប៉ុនត្រូវបានជូនដំណឹង ទីក្រុងប៉េកាំងយល់ឃើញថា មានបីដំណាក់កាលចាំបាច់សម្រាប់ដោះស្រាយជម្លោះនេះ៖ "ភាគីទាំងពីរត្រូវបញ្ឈប់អរិភាព។ កងទ័ពដែលបានឆ្លងព្រំដែន ត្រូវដកចេញពីទឹកដីដែលពួកគេបានកាន់កាប់។ ដូច្នេះ ការចរចាលើដំណោះស្រាយបញ្ហាដែលមានវិវាទខ្លាំងដោយសន្តិវិធី ត្រូវចាប់ផ្តើម"។ គ្មានព័ត៌មានស្តីពីសកម្មភាពការទូតពិសេស ត្រូវបានរៀបចំឡើងដោយប្រទេសចិនពាក់ព័ន្ធនឹង SRV ឬកម្ពុជានោះទេ។ សកម្មភាពរបស់ស្ថានទូត PRC ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺមិនត្រូវបានដឹងឡើយ។ របាយការណ៍ដាច់ដោយឡែកនៅក្នុងសារព័ត៌មានបស្ចិមប្រទេសបានថ្លែងថា មេដឹកនាំចិន នឹងដើរតួជាអ្នកសម្របសម្រួល។ នៅពេលចាប់ផ្តើមនៃជម្លោះបើកចំហនេះ សារព័ត៌មានចិនបានគាំទ្រភាគីកម្ពុជាយ៉ាងច្បាស់។ ជាដំបូង នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ សេចក្តីប្រកាសរបស់កម្ពុជាបានធ្វើការផ្សព្វផ្សាយយ៉ាងស៊ីជម្រៅ។ មានតែរបាយការណ៍ខ្លីមួយប៉ុណ្ណោះដែលត្រូវបានចុះផ្សាយស្តីពីសេចក្តីប្រកាសរបស់ SRV នៅថ្ងៃទី ២ ខែ មករា ឆ្នាំ ១៩៧៨ ដោយបានបកស្រាយបំផ្លែងទស្សនៈរបស់វៀតណាមអំពីព្រឹត្តិការណ៍នានា។ ឯកអគ្គរដ្ឋទូតនៃ SRV ប្រចាំទីក្រុងប៉េកាំងបានធ្វើការតវ៉ាប្រឆាំងនឹងការចុះផ្សាយនោះជាមួយក្រសួងការបរទេសរបស់ PRC។ ចាប់តាំងពីពេលនោះមក PRC បានផ្លាស់ប្តូរវិធីឆ្លើយតបតាមសារព័ត៌មាន។ នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៧៨ *Renmin Ribao* បានចុះផ្សាយសេចក្តីប្រកាស ដែលបានចេញដោយទីក្រុងហាណូយ និងទីក្រុងភ្នំពេញ

នៅថ្ងៃទី ៦ ខែ មករា ដោយផ្តល់ឲ្យភាគីទាំងពីរនូវការចុះផ្សាយព័ត៌មានស្មើភាពគ្នា។ ទោះជាយ៉ាងនេះក្តី សារព័ត៌មានផ្លូវការរបស់ PRC កម្របានលើកឡើងពីកិច្ចខិតខំប្រឹងប្រែងរបស់ SRV ក្នុងការចរចាជាមួយកម្ពុជា។ រហូតមកដល់ពេលនេះ មិនទាន់មានសេចក្តីប្រកាសផ្លូវការទាក់ទងទៅនឹងការកាត់ផ្តាច់ជាបណ្តោះអាសន្ននៃទំនាក់ទំនងការទូតជាមួយ SRV ។

ការពិតដែលថាការធ្វើរបាយការណ៍ដែលមានភាពលម្អៀងនៅតែបន្តដោយប្រទេសចិនមិនបានបញ្ជាក់ពីគោលជំហររបស់ខ្លួនឱ្យសាធារណជនបានដឹង បង្ហាញយ៉ាងច្បាស់ថា ប្រទេសចិនបានគាំទ្រដល់ភាគីកម្ពុជា។ នៅពេលជាមួយគ្នានេះដែរ កិច្ចខិតខំប្រឹងប្រែងនានា កំពុងត្រូវបានធ្វើឡើងយ៉ាងពិតប្រាកដ ដើម្បីរក្សាភាពខុសគ្នានេះ ដោយ SRV ស្ថិតក្រោមការរិតត្បិត។

យោងតាមរបាយការណ៍របស់ *TASS* នៅថ្ងៃទី ១០ ខែ មករា លោក Brzezinski ដែលជាទីប្រឹក្សារបស់ប្រធានាធិបតីសហរដ្ឋអាមេរិក បានអះអាងថា ជម្លោះរវាងវៀតណាម និងកម្ពុជា សមស្របទៅនឹងផលប្រយោជន៍នៃគោលនយោបាយសហរដ្ឋអាមេរិក និង "ជាខណៈពេលដំបូងបំផុតនៃការប្រឈមមុខគ្នាដោយប្រយោលរវាងចិន និងសហភាពសូវៀត"។

តំណាងផ្លូវការម្នាក់នៃគណៈកម្មាធិការគោលនយោបាយការបរទេសរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក បានបដិសេធមិនគាំទ្រសេចក្ដីថ្លែងការណ៍នេះ។ កាសែត The *Washington Post* បានរាយការណ៍ថាវាជាការគិតចង់បាននៅលើផ្នែករបស់ Brzezinski ។ យោងតាមកាសែត The *Washington Post* តំណាងផ្លូវការផ្សេងទៀត នឹងផ្ដល់ការវាយតម្លៃប្រកបដោយការប្រុងប្រយ័ត្នបន្ថែមទៀតលើស្ថានភាពនេះ។ សារព័ត៌មានសហរដ្ឋអាមេរិកបានរាយការណ៍ថា បញ្ហាត្រូវបានទទួលយកតាមរយៈការវាយតម្លៃរបស់ Brzezinski នៅក្នុងទីក្រុងវ៉ាស៊ីនតោន (ប្រភព: *Pravda* ថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៧៨)។ ដូចដែលបានរាយការណ៍ដោយ UPI ពីទីក្រុងវ៉ាស៊ីនតោន ការគាំទ្ររបស់ចិនសម្រាប់កម្ពុជា "យោងតាមការវិភាគរបស់សហរដ្ឋអាមេរិកនៃព័ត៌មានពីតំបន់ជម្លោះនេះ" គឺមានលក្ខណៈនយោបាយ និងយោធា។ លិខិតឆ្លើយឆ្លងផ្លូវការនេះបានបញ្ជាក់ថា ៖ "មន្ត្រីសហរដ្ឋអាមេរិក ស្ទើរតែមិនអាចលាក់បាំងបាននូវការពេញចិត្តរបស់ពួកគេចំពោះព្រឹត្តិការណ៍នៅក្នុងតំបន់ឥណ្ឌូចិន"។

មិនទាន់មានសេចក្ដីថ្លែងការណ៍ផ្លូវការណាមួយស្ដីពីគោលជំហររបស់ <u>FRG</u> [សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់] នៅឡើយទេ។ ការចុះផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ មានភាពលម្អៀង និងផ្ដោតលើការបង្កឱ្យមានការភ្ញាក់ផ្អើល និងអ្វីដែលគេហៅថាជាការភ័យខ្លាចជាប្រវត្តិសាស្ត្ររបស់កម្ពុជាចំពោះ "ការវាតទីនិយមរបស់វៀតណាម"។

កាសែតបារាំង *Figaro* បានរាយការណ៍កាលពីថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨ ថា ក្រសួងការបរទេសបារាំង បានសំដែងការសោកស្តាយចំពោះអរិភាពជាថ្មីរវាងប្រទេសទាំងពីរ និងគាំទ្រសន្តិភាពផ្អែក "លើសមភាព ការគោរពអធិបតេយ្យភាព និងបំណងប្រាថ្នាក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី"។ នៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨ ឯកអគ្គរដ្ឋទូត SRV ប្រចាំទីក្រុងប៉ារីស មានឱកាសក្នុងការពន្យល់យ៉ាងលម្អិតពីគោលជំហររបស់ប្រទេសគាត់ទាក់ទងនឹងជម្លោះនេះ តាមរយៈប៉ុស្តិ៍ទីពីរនៃទូរទស្សន៍បារាំង។

គោលជំហររបស់រដ្ឋាភិបាលជប៉ុនគឺមិនត្រូវបានដឹងនោះទេ។ សេចក្តីរាយការណ៍របស់ AFP ត្រូវបានចុះផ្សាយឡើងវិញដោយគ្មានការអត្ថាធិប្បាយក្នុងសារព័ត៌មាន។ (អ្នកសារព័ត៌មានរបស់កាសែត *The Asahi* នៅក្នុងទីក្រុងបាងកក មិនបានច្រានចោលជម្លោះអូសបន្លាយនេះឡើយ)។

ប្រទេសស៊ុយអែត: នៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨ *Dagens Nyheter* រាយការណ៍ថា៖ "អ្វីដែលជាសោកនាដកម្មបំផុតអំពីជម្លោះនេះ គឺវាអាចបង្កឲ្យមានផលវិបាកនយោបាយសំខាន់ៗ។ នៅក្នុងតំបន់ បន្ទាប់ពីសហរដ្ឋអាមេរិកបានដួលរលំ ការប្រើល្បិចកលសម្រាប់សម្ព័ន្ធភាពថ្មីកំពុងដំណើរ ដោយមានការមើលឃើញថា វៀតណាមគឺជាសម្ព័ន្ធមិត្តប្រកបដោយគ្រោះថ្នាក់ និងគួរឲ្យទាក់ទាញ"។

ហ្វាំងឡង់: សារព័ត៌មានទទួលស្គាល់ដោយផ្នែកថាមានការប៉ះទង្គិចធ្ងន់ធ្ងរ “ដែលអាចមានផលវិបាក” ពោលគឺប្រកាន់យកគោលជំហរនៃ “សង្គ្រាមជំនួស (Proxy War)”។

ចក្រភពអង់គ្លេស: បន្ទាប់ពីទទួលបានសេចក្តីប្រកាសរបស់រដ្ឋាភិបាល SRV រដ្ឋមន្ត្រីការបរទេសនៃចក្រភពអង់គ្លេស ព្រះអង្គម្ចាស់ Gorowny-Roberts បានសម្តែងក្តីសង្ឃឹមថា បញ្ហាព្រំដែនអាចត្រូវបានដោះស្រាយដោយសន្តិវិធី។

គោលជំហរ និងខ្លឹមសាររបស់សារព័ត៌មានចក្រភពអង់គ្លេស ពិពណ៌នា SRV ថាជាអ្នកបង្កជម្លោះនេះ។

ឥណ្ឌា: ឯកអគ្គរដ្ឋទូតនៃ SRV ដែលបានរៀបរាប់ប្រាប់រដ្ឋមន្ត្រីការបរទេស Vajpayee យ៉ាងលម្អិត។ ឥណ្ឌាបានយល់ព្រមចំពោះសំណើរបស់ SRV ក្នុងការដោះស្រាយជម្លោះនេះ។

តាមការវាយតម្លៃរបស់ស្ថានទូត ឥណ្ឌាទំនងជាជ្រើសយកគោលជំហររបស់ SRV។ សេចក្តីថ្លែងការណ៍ជាផ្លូវការនឹងមិនត្រូវបានធ្វើនោះឡើយ។

អ៊ីរ៉ង់: នៅពុំទាន់មានប្រតិកម្មជាផ្លូវការនៅឡើយទេ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានពឹងផ្អែកលើទីភ្នាក់ងារសារព័ត៌មានសហរដ្ឋអាមេរិក។ ជាលក្ខណៈក្រៅផ្លូវការ ការសប្បាយរីករាយនៅក្នុងសង្គ្រាមរវាងប្រទេស "កុម្មុយនីស្ត" ទាំងពីរ និងការព្រួយបារម្ភចំពោះជម្លោះកាន់តែរីកធំជាងមុនរវាងសហភាពសូវៀត និងចិន ត្រូវបានស្តែងឡើង (មន្ត្រីក្រសួងការបរទេស CD [មិនស្គាល់អក្សរកាត់] និងអ្នកកាសែត)។

Jana បានរាយការណ៍នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៧៨ ថា តាមរយៈបណ្តាស្ថានទូតនានា លោក Gaddafi ប្រមុខរដ្ឋលីប៊ី បានចេញសេចក្តីអំពាវនាវបន្ទាន់មួយទៅប្រមុខរដ្ឋកម្ពុជា និងវៀតណាម ដើម្បីបញ្ឈប់ការប្រើអំពើហិង្សាក្នុងការដោះស្រាយជម្លោះនេះ។

រដ្ឋមន្ត្រីក្រសួងការបរទេសស៊ីរីបានទទួលឯកអគ្គរដ្ឋទូត SRV នៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៧៨ និងបានគាំទ្រគោលជំហររបស់ SRV ។ គោលជំហរអព្យាក្រឹតមួយកំពុងត្រូវបានទទួលយកនៅក្នុងបទអត្ថាធិប្បាយក្នុងសារព័ត៌មាន និងនៅតាមវិទ្យុ ប៉ុន្តែ ខណៈនោះដែរ ក៏មានការបញ្ជាក់ថា ជម្លោះនេះត្រូវដោះស្រាយដោយសន្តិវិធី និងតាមរយៈការចរចា។ កាសែត *Al Baath* និង *Tischrin* របស់ប្រទេសស៊ីរី បានយោងជាចំបងលើសេចក្តីប្រកាសរបស់ SRV។ ផ្ទុយទៅវិញ កាសែត *Al Thaura* មានអត្ថបទមួយចំនួនប្រកាន់យកគោលជំហរប្រឆាំងនឹង SRV ។ ប្រការនេះឆ្លុះបញ្ចាំងពីភាពមិនស៊ីសង្វាក់គ្នានៅក្នុងរបបដឹកនាំរបស់ Baath ។ នៅក្នុងគំនិតរបស់ឯកអគ្គរដ្ឋទូត SRV ការធ្វើរបាយការណ៍អវិជ្ជមានបែបនេះ អាចត្រូវបានញុះញង់ដោយ PRC និងកូរ៉េខាងជើង។

ឯកអគ្គរដ្ឋទូត ឬនិយាយឲ្យបានច្បាស់លាស់ជាងនេះថាជាភារធារីនៃ SRV ប្រចាំនៅប្រទេសយេម៉ែន និងនៅម៉ូសំប៊ិក បានប្រគល់សេចក្តីប្រកាសរបស់រដ្ឋាភិបាលទៅឲ្យតំណាងរបស់បណ្តាប្រទេសទាំងនេះ។ រហូតមកដល់ពេលនេះ មិនទាន់មានប្រតិកម្មណាមួយរបស់រដ្ឋាភិបាលទាំងនេះនៅឡើយទេ។

ឥណ្ឌូនេស៊ី: សេចក្តីថ្លែងការណ៍ផ្លូវការ (ដោយរដ្ឋមន្ត្រីក្រសួងការបរទេស និងជាប្រធានសភា) បានយល់ឃើញថាជម្លោះប្រដាប់អាវុធនេះគឺជារឿងគួរឲ្យសោកស្តាយ និងបានបញ្ចេញទស្សនៈដូចខាងក្រោម៖

សង្ឃឹមថាជម្លោះនេះនឹងត្រូវបានដោះស្រាយយ៉ាងឆាប់រហ័សតាមរយៈការចរចា។

ភ័យខ្លាចចំពោះផលវិបាកអវិជ្ជមានលើបណ្តារដ្ឋសមាជិកអាស៊ាននៅក្នុងលក្ខខណ្ឌនៃស្ថិរភាព និងសន្តិសុខក្នុងតំបន់។

ស្ថានភាពដែលត្រូវបានសម្របសម្រួលដោយកិច្ចខិតខំប្រឹងប្រែងក្រោមឥទ្ធិពលរបស់ PRC និងសហភាពសូវៀតស្តីពីការអភិវឌ្ឍនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

ឧបសគ្គចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ SRV ឆ្ពោះទៅរកទំនាក់ទំនងល្អជាមួយបណ្តារដ្ឋជិតខាងទាំងអស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

មានបទអត្ថាធិប្បាយខុសគ្នានៅក្នុងសារព័ត៌មាន រួមទាំងការសោកស្តាយ ការព្រួយបារម្ភ និងការសប្បាយរីករាយបែបលាក់លៀមលើជម្លោះរវាង "រដ្ឋកុម្មុយនីស្តទាំងពីរ ដែលឆ្លុះបញ្ចាំងពីកំណើននៃការប្រកួតប្រជែងរវាងប្រទេសចិន និងសហភាពសូវៀត និងធ្វើឲ្យចុះខ្សោយនូវ "កម្លាំងជំរុញវាតទីនិយម" នៅឥណ្ឌូចិនដែលមានការរួបរួមគ្នាជាមួយនឹងបណ្តារដ្ឋសមាជិកអាស៊ាន។

ជម្លោះដោយបើកចំហនេះ នឹងមិនមានរយៈពេលយូរនោះឡើយ។ SRV ត្រូវប្រឈមនឹងបញ្ហារយៈពេលវែង។ ទុនបម្រុងរបស់កម្ពុជាគឺមិនចេះរីងស្ងួតឡើយ។

ប៉ាគីស្ថាន: គ្មានសេចក្ដីថ្លែងការណ៍ស្ដីពីគោលជំហរផ្លូវការឡើយ។ សារព័ត៌មានពាក់កណ្ដាលផ្លូវការធ្វើការដកស្រង់ទ្រឹស្ដីជាតិនិយម និងការវិវឌ្ឍជាប្រវត្តិសាស្ត្រថាជាជាមូលហេតុនៃជម្លោះនេះ។